សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ធាតុផ្សំ នៃបទល្មើស

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


រៀបរៀងដោយ

និស្សិតឈ្មោះ ៖ **កញ្ញា ស៊ីម ចាយ**

**កញ្ញា ភ័ណ្ឌ ស្រីលីស**

ណែនាំដោយ

លោកគ្រូ **សៅ ស៊ីមុន្ធា**


ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឥណ្ឌា ស្រីលីស** និងឈ្មោះ **ស៊ីវ ចាយ** ជានិស្សិត នីតិសាស្ត្រ **នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា** ២០២០-២០២៤ ជំនាន់ទី ២៤។

ជាដំបូងនាងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណចំពោះ **លោកឪពុក អ្នកម្ដាយ** ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ នឹងឱ្យកូនបានរៀនសូត្រមានចំណេះដឹងរហូតដល់បញ្ចប់ ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។

គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបាន របស់លោកអ្នកមានគុណទាំងពីរ ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមាន ទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឱ្យកូនៗចងចាំជានិច្ច គ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗ ជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ។

នាងខ្ញុំទាំងពីរទាំងពីរនាក់ក៏សូមថ្លែងអំណរគុណចំពោះ **ឯកឧត្ដម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្ដល់នូវពុទ្ធិល្អៗយ៉ាងពិតប្រាកដសម្រាប់ជាប្រទីបបំភ្លឺជីវិតនាងខ្ញុំទាំងពីរ នៅក្នុងថ្នាក់បរិញ្ញាបត្រនេះ។

ជាពិសេសនាងខ្ញុំទាំងពីរសូមថ្លែងអំណរគុណចំពោះលោកគ្រូ **សៅ ស៊ីវុត្ថា** ដែលលោគ្រូណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយជោគជ័យ។ ជាពិសេសលោកគ្រូបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការខិតខំ ប្រឹងប្រែងពន្យល់ណែនាំ តម្រង់ទិស ផ្ដល់ឯកសារពាក់ព័ន្ធ និងសារណា ផ្ដល់អនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើយ៉ាងណាឱ្យសារណានាងខ្ញុំទាំងពីរបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងបញ្ចប់ នាងខ្ញុំទាំងពីរទាំងពីរនាក់សូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ *លោកអ្នកមាន គុណទាំងពីរ ឯកឧត្ដម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ* ទាំងអស់សូមបានប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀង ឃ្លាតឡើយ

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងរយៈពេល ៤ឆ្នាំនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំទាំងពីរក៏សម្រេចចិត្ត ជ្រើសរើសយកប្រធានបទស្តីពី "**ធាតុផ្សំនៃបទល្មើស**" ដែលដឹកនាំដោយលោកគ្រូ **សៅ ស៊ីខុន្ថា** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ការជ្រើសរើសយកប្រធាននេះមកធ្វើការស្រាវជ្រាវ ពុំមែនជារឿងចៃដន្យនោះទេ ប៉ុន្តែជាការពិចារណាយ៉ាងហ្មត់ចត់តាមរយៈការសិក្សាលើអត្ថបទច្បាប់ដែលពាក់ព័ន្ធ គឺដោយសារតែយល់ឃើញថាធាតុផ្សំ នៃបទល្មើសដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ទន្ទឹមនឹងនេះ ប្រធានបទនេះក៏បានឆ្លងកាត់ពិគ្រោះ និងផ្តល់យោបល់ពីសំណាក់សាស្ត្រាចារ្យ មេធាវី ក្រឡាបញ្ជី បងប្អូនមិត្តនិស្សិតរួមជំនាន់ដើម្បី សរសេរសារណានេះ។

នាងខ្ញុំទាំងពីរពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានសរសេរសារណាដែលស្តីអំពី ធាតុផ្សំនៃបទ ល្មើស ដោយមានណែនាំដោយលោកគ្រូ **សៅ ស៊ីខុន្ថា** ដែលបានផ្តល់យោបល់ណែនាំ ផ្តល់ឯកសារដល់យើងទាំងពីរនាក់ ដើម្បីអាចសរសេរសារណានេះទៅដោយរលូនបានល្អ។ សង្ឃឹមថាសារណានេះនឹងក្លាយជាឯកសារស្រាវជ្រាវដល់សិស្ស និស្សិតជំនាន់ក្រោយៗ ដើម្បីសិក្សាស្រាវជ្រាវពីការធាតុផ្សំនៃបទល្មើសឱ្យបានលម្អិត។

បើទោះបីជាមានការខិតខំសិក្សាស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយក៏ការសរសេរសារណានេះពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះនាងខ្ញុំទាំងពីរនាក់រង់ចាំទទួលការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិតផ្សេងៗទៀតដើម្បី កែលម្អសារណានេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ

# មាតិកា

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**
**ធាតុផ្សំនីត្យានុកូល**

**ផ្នែកទី១ គោលការណ៍នីត្យានុកូលភាព** ........ ៤

**កថាខណ្ឌទី១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងកាលវេលា** ........ ៦

១. ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ ........ ៧

១.១. គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ........ ៧

១.២. គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាង ........ ៨

២. ច្បាប់ទម្រង់ ឬច្បាប់នីតិវិធី ........ ៨

**កថាខណ្ឌទី២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ** ........ ៩

១. បទល្មើសប្រព្រឹត្ត ឬចាត់ថាប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា ........ ១០

២. បទល្មើសប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ........ ១០

៣. បត្យាប័ន ........ ១១

**ជំពូកទី២**
**ធាតុផ្សំសត្យានុម័ត**

**ផ្នែកទី១ សញ្ញាណទូទៅ និងប្រភេទផ្សេងៗ នៃអំពើដែលជាធាតុផ្សំសត្យានុម័ត** . ១២

១. សញ្ញាណទូទៅ ........ ១២

២. ប្រភេទផ្សេងៗនៃអំពើដែលជាធាតុផ្សំសត្យានុម័ត ........ ១២

**ផ្នែកទី២ ការប៉ុនប៉ង** ........ ១៣

១. ធាតុផ្សំនៃការប៉ុនប៉ងមានទោស ........ ១៤

ក. ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ........ ១៤

ខ. ការប៉ុនប៉ងក្នុងបទមជ្ឈិម ........ ១៤

គ. ការប៉ុនប៉ងក្នុងបទលហុ ........ ១៦

១.១. ការចាប់ផ្ដើមអនុវត្ត និងការអាក់ខានទៅវិញដោយអឆន្ទៈ ........ ១៦

២. ការផ្ដើមគំនិត និងការសមគំនិត ........ ១៧

២.១. លក្ខខណ្ឌនៃការផ្ដើមគំនិត និងការសមគំនិត ........ ១៩

២.២. អំពើចម្បងមានទោស ..................................................................................១៩
២.៣. ធាតុផ្សំសត្យានុម័តនៃការផ្ដើមគំនិត និងការសមគំនិត .............................១៩
២.៤. ធាតុផ្សំអត្តនោម័ត នៃការផ្ដើមគំនិត និងការសមគំនិត............................. ២០
២.៥. ការដាក់ទណ្ឌកម្មលើការផ្ដើមគំនិត និងការសមគំនិត.............................. ២០

## ជំពូកទី៣
## ធាតុផ្សំអត្តនោម័ត

**ផ្នែកទី១ កំហុសចេតនា** ......................................................................................... ២២
១. ប្រភេទផ្សេងៗនៃចេតនាទុច្ចរិត ......................................................................២៣
១.១. ចេតនាដោយចំពោះ.....................................................................................២៣
១.២. ចេតនាដោយមិនចំពោះ...............................................................................២៣
១.៣. ចេតនាទុច្ចរិតទូទៅ.......................................................................................២៣
១.៤. ចេតនាទុច្ចរិតមិនច្បាស់លាស់ ..................................................................... ២៤
១.៥. ចេតនាទុច្ចរិតពិសេស.................................................................................. ២៤
១.៦. ចេតនាទុច្ចរិតធ្ងន់ធ្ងរ ..................................................................................... ២៤
២. ភាពខុសគ្នារវាងចេតនាទុច្ចរិត និងមូលហេតុនៃការប្រព្រឹត្តបទល្មើស................... ២៥
**ផ្នែកទី២ កំហុសអចេតនា** ...................................................................................... ២៥
១. ការខ្ជីខ្ជា ......................................................................................................... ២៦
២. ការមិនប្រុងប្រយ័ត្ន.......................................................................................... ២៦
៣. ការធ្វេសប្រហែស ............................................................................................ ២៧
៤. ការមិនគោរពកាតព្វកិច្ចដែលច្បាប់តម្រូវ ............................................................. ២៧
**ផ្នែកទី៣ ការវាយតម្លៃកំហុសចេតនា និងកំហុសអចេតនា** ........................................ ២៨
១. ភាន់ច្រឡំអំពីច្បាប់.......................................................................................... ២៨
២. ភាន់ច្រឡំពីអំពើ ឬពីអង្គហេតុ ..........................................................................២៩
**សេចក្ដីសន្និដ្ឋាន** .......................................................................................................... ៣០
**អនុសាសន៍** ...............................................................................................................៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ជាការពិតណាស់តាំងពីបុរាណកាលរហូតដល់ពេលបច្ចុប្បន្នកាលនេះ សង្គមនីមួយៗ តែងតែមានការផ្លាស់ប្តូរ មិនថានៅក្នុងសង្គមដែលមានការរីកចម្រើន ឬសង្គមដែលមានការអភិវឌ្ឍតិចតួចនោះទេ គឺតែងតែមានការប្រែប្រួល និងវិវត្តទោះតិច ឬច្រើននៅតែមាន។ ទន្ទឹមនឹងការរីកចម្រើន ក៏មានការផ្លាស់ប្តូរនូវរូបរាង ក៏ដូចជាមានការរីកចម្រើននូវ បទល្មើសថ្មីៗ បន្ថែមទៀតផងដែរ។ ហើយសព្វថ្ងៃនេះប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលមានការវិវត្តតិចតួច ក៏មានការប្រែប្រួលផងដែរ។ ហេតុដូច្នេះហើយក៏មានអំពើល្មើសផ្សេងៗ ក៏កើតមានផងដែរ។ ជាហេតុធ្វើឱ្យមានការប៉ះពាល់ទៅដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់ទ្រព្យសម្បត្តិ កិត្តិយស និងសេចក្តីថ្លៃថ្នូរ ជាពិសេសនោះគឺមានការប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋទៀតផង។ បទល្មើសទាំងអស់នេះវាអាចកើតឡើងគ្រប់ទីកន្លែងមិនថានៅទីក្រុង តាមជនបទតំបន់ទីប្រជុំជន ឬតំបន់ដាច់ស្រយាលនោះទេ វាគ្រាន់តែមានលក្ខណៈខុសគ្នាពាក់ព័ន្ធទៅនឹងចំនួន និងស្ថានភាពនៃបទល្មើសតែប៉ុណ្ណោះ។ ដោយសារតែបានសង្កេតយ៉ាងយកចិត្តទុកដាក់ឃើញនូវផលវិបាកដែលជះឥទ្ធិពលអាក្រក់ដល់ប្រជាពលរដ្ឋ ក៏ដូចជាសង្គមជាតិទាំងមូលផងដែរនោះ ទើបប្រទេសកម្ពុជាបានបង្កើតនូវច្បាប់ជាច្រើនដើម្បីធ្វើការបង្ក្រាប និងដាក់ទណ្ឌកម្មទៅលើជនដែលបានប្រព្រឹត្តបទល្មើសដោយកំណត់ទៅតាមកម្រិតនៃអំពើល្មើសនោះ។ ចំពោះច្បាប់ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រងទៅលើអំពើល្មើសនោះមានច្រើនទៅតាម ប្រភេទនៃបទល្មើស ក៏ដូចជាអាស្រ័យទៅតាមវិស័យផ្សេងៗគ្នា ប៉ុន្តែក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់មួយដែលមានកំណត់អំពីបទល្មើសច្រើនជាងច្បាប់ដទៃទៀត។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងឡាយដែលទាក់ទងទៅ និងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ដូច្នេះសិទ្ធិសេរីភាព និងអាយុជីវិតមនុស្សម្នាក់ៗ គឺត្រូវបានធានាដោយច្បាប់ ពោលគឺមនុស្សម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការរស់រានមានជីវិត និងសន្តិសុខផ្ទាល់ខ្លួន។ ក៏ប៉ុន្តែក្នុងសង្គមនីមួយៗ តែងតែមាននូវអំពើរំលោភបំពានទៅលើសិទ្ធិក៏ដូចជា អំពើដែលប៉ះពាល់ដល់សន្តិសុខរបស់បុគ្គលណាមួយផ្សេងទៀត ដែលយើងអាចហៅបានថាជាបទល្មើស។ ប៉ុន្តែស្ថាប័នតុលាការជាអ្នកមានសិទ្ធិអំណាច នៅក្នុងការផ្តន្ទាទោសទៅលើជនទាំងឡាយណា ដែលបានប្រព្រឹត្តនូវបទល្មើសដែលនាំឱ្យប៉ះពាល់ដល់អ្នកដទៃ ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។ នៅពេលណាដែលមានរឿងក្តីមួយបានកើតឡើង ហើយជាប្រភេទរឿងក្តីព្រហ្មទណ្ឌផង គឺប្រាកដណាស់ទាមទារឱ្យអ្នកអនុវត្តច្បាប់ ដែលមានសិទ្ធិអំណាចអនុវត្តសិទ្ធិអំណាចរបស់ខ្លួនឱ្យត្រឹមត្រូវ និងមានមូលដ្ឋានច្បាប់ច្បាស់លាស់។

យើងដឹងហើយថាមនុស្សគ្រប់រូប មិនសូវមានការយល់ដឹងពីបទល្មើសព្រហ្មទណ្ឌបែបនេះហើយ ទើបបណ្ដាប្រទេសនៅលើសកលលោកបានបង្កើតច្បាប់ព្រហ្មទណ្ឌនេះឡើង ក្នុងគោលបំណងដើម្បីឱ្យមនុស្សនៅក្នុងសង្គមកុំឱ្យប្រព្រឹត្តនូវអំពើខុសច្បាប់ និងដើម្បីឱ្យមនុស្សមានការយល់ដឹង និងចេះគោរពគ្នាដោយសេចក្ដីថ្លៃថ្នូរ ហើយសង្គមនឹងមានសណ្ដាប់ធ្នាប់សន្តិសុខ និងស្ថេរភាពល្អសម្រាប់រស់នៅរបស់មនុស្សក្នុងសង្គមនីមួយៗ ចំណែកឯការប្រព្រឹត្តបទល្មើសផ្សេងៗនោះវិញក៏មិនសូវមានធ្ងន់ធ្ងរអ្វីដែរ ឬបើមានក៏មានលក្ខណៈតិចតួចតែប៉ុណ្ណោះ។ ទោះបីជាមានច្បាប់យ៉ាងសម្បូរបែបក៏ដោយ ក៏សង្គមមនុស្សនៅតែរំលោភបំពានទៅលើច្បាប់នេះដដែរ។ ហើយធាតុផ្សំនៃការប្រព្រឹត្តបទល្មើស របស់មនុស្សតែងតែមានជានិច្ច គ្រាន់តែថាការប្រព្រឹត្តនោះមានលក្ខណៈទ្រង់ទ្រាយតូច ឬធំទៅតាមលក្ខណៈនៃការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ។ ពេលខ្លះមនុស្សតែងប្រើធាតុផ្សំ នៃការប្រព្រឹត្តបទល្មើសនោះមានដូចជា ៖ ដំបង កាំបិត ដុំថ្ម កាំភ្លើង ឡាន ម៉ូតូ ចារី ឬសហចារី។ ហើយប្រជាជននៅបណ្ដាប្រទេសទាំងអស់ត្រូវតែចូលរួមទប់ស្កាត់ពីបទល្មើសព្រហ្មទណ្ឌនេះឱ្យបានតឹងរឹង ហើយមនុស្សនៅក្នុងសង្គមត្រូវតែសិក្សាដើម្បីធ្វើការស្វែងយល់អំពីធាតុផ្សំ នៃបទល្មើសព្រហ្មទណ្ឌឱ្យបានស៊ីជម្រៅពីច្បាប់ ព្រហ្មទណ្ឌនេះ ដើម្បីកុំឱ្យមនុស្សប្រព្រឹត្តអំពើផ្ទុយ និងច្បាប់ដែលអំពើបានកើតឡើងនោះ មានលក្ខណៈយ៉ាងឃោរឃៅដាក់គ្នាទៅវិញទៅមកនាំឱ្យអស្ថេរភាព និងខុសច្បាប់សង្គម។ ដែលអ្នកគ្រប់គ្រងប្រទេសបានបង្កើតច្បាប់នេះឡើងដើម្បីការពារ និងសុខមាលភាពរបស់មនុស្សទាំងប្រុសស្រី ធ្វើឱ្យមានជីវិតស្រស់ត្រកាលរស់នៅពោរពេញទៅដោយភាពបរិបូរណ៍យ៉ាងល្អប្រសើរឡើងនៅក្នុងពិភពលោកយើងនេះ និងដើម្បីពង្រឹងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់នានាជាច្រើនទៀតឱ្យមានប្រសិទ្ធភាព ក្នុងការអនុវត្តច្បាប់របស់ប្រទេសនីមួយៗ។ ដូច្នេះទើបសង្គមមនុស្សមានស្ថេរភាព និងសម្បូរសប្បាយជាពិសេសសង្គមពិតជាមានមនុស្សមានការចេះដឹង និងសម្បូរទៅដោយធនធានមនុស្សពិតប្រាកដក្នុងការលើកស្ទួយប្រទេសជាតិឱ្យមានភាពរីកចម្រើន និងល្បីល្បាញនៅលើសកលលោកនេះ។

ចំណុចសំខាន់ដែលគួរសិក្សាស្រាវជ្រាវបានផ្ដោតទៅលើចម្ងល់មួយចំនួនទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។ នាងខ្ញុំទាំងពីរសូមលើកយកនូវចំណោទបញ្ហាមួយចំនួនខាងក្រោមនេះ ៖

- តើអ្វីទៅជាធាតុផ្សំ នៃបទល្មើសព្រហ្មទណ្ឌ?
- តើធាតុផ្សំ នៃបទល្មើសព្រហ្មទណ្ឌមានអ្វីខ្លះ?
- តើធាតុផ្សំ នៃបទល្មើសព្រហ្មទណ្ឌនីមួយៗមានលក្ខណៈយ៉ាងដូចម្ដេច?

ក្នុងគោលបំណងដើម្បីជម្រុញឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ គឺចាំបាច់ទាមទារនូវការសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន នៃការស្រាវជ្រាវប្រធានបទខាងលើ។ និងការប្រមូលព័ត៌មាន ដែលមានការពាក់ព័ន្ធសម្រាប់ធ្វើជាមូលដ្ឋាន ដូចនេះការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលពីប្រភព

ឯកសារពីរប្រភេទគឺ ឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។ រចនាសម្ព័ន្ធនៃការស្រាវជ្រាវចែកចេញជា ៣ ជំពូក ដូចជា ៖

- **ជំពូកទី១ ធាតុផ្សំនីត្យានុកូល**
- **ជំពូកទី២ ធាតុផ្សំសត្យានុម័ត**
- **ជំពូកទី៣ ធាតុផ្សំអត្តនោម័ត**

# ជំពូកទី១

# ធាតុផ្សំនីត្យានុកូល

# ជំពូកទី១

# ធាតុផ្សំនីត្យានុកូល

ធាតុផ្សំនីត្យានុកូលបានសេចក្តីថា ដើម្បីកំណត់អំពើណាមួយជាបទល្មើសបានលុះត្រាតែមានចែងក្នុងច្បាប់បើពុំមានច្បាប់ចែងនោះទេមិនអាចកំណត់ថាអំពើនោះជា បទល្មើសបានឡើយ។

ជាគោលការណ៍បទល្មើសឧក្រិដ្ឋ និងបទល្មើសមជ្ឈិម ត្រូវមានប្រភពចេញពីច្បាប់ ចំណែកបទលហុអាចចេញពីអំណាចនីតិប្រតិបត្តិ ឬមកពីអាជ្ញាធរសាធារណៈ។ ដើម្បីផ្តន្ទាទោសលើអំពើល្មើសណាមួយបានលុះត្រាតែមានច្បាប់ចែងប៉ុន្តែនៅក្នុងករណីមួយចំនួនថ្វីត្បិតតែច្បាប់ចែងហើយក៏ដោយក៏គេពុំទទួលខុសត្រូវខាងព្រហ្មទណ្ឌដូចជា ៖

- វិបល្លាស្មារតី (មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា)
- ការអនុញ្ញាតដោយច្បាប់ ឬដោយអាជ្ញាធរស្របច្បាប់ (មាត្រា ៣២)
- ការការពារស្របច្បាប់ (មាត្រា ៣៣)
- ស្ថានភាពចាំបាច់ (មាត្រា ៣៥)
- អានុភាពនៃកម្លាំង ឬការបង្ខំ (មាត្រា ៣៦)
- អនីតិភាព (មាត្រា ៣៨)

## ផ្នែកទី១ គោលការណ៍នីត្យានុកូលភាព

គោលការណ៍នេះត្រូវបានគេចាត់ទុកថាជាធាតុបឋម ឬជាលក្ខខណ្ឌបឋមនៃបទល្មើសក្នុងធាតុផ្សំទាំងបី។ មានន័យថាបើពុំមានច្បាប់ព្រហ្មទណ្ឌចែងនោះទេ អំពើមួយមិនត្រូវចាត់ទុកជាបទល្មើសឡើយ។ ដើម្បីស្តែងឡើងនូវធាតុផ្សំនេះមាត្រា ៣ នៃក្រមព្រហ្មទណ្ឌបានបង្កប់នូវ "គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស"។ ដើម្បីធានានូវការអនុវត្តគោលការណ៍នេះឱ្យបានត្រឹមត្រូវមាត្រា ៥ នៃក្រមព្រហ្មទណ្ឌកំណត់ថា ច្បាប់ព្រហ្មទណ្ឌត្រូវបកស្រាយយ៉ាងតឹងរឹង ហើយមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។ យោងតាមកថាខណ្ឌទី១ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួល ស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។[1]

[1] មាត្រា ៣១ រដ្ឋធម្មនុញ្ញ នៃព្រះរាជជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

នៅក្នុងគោលការណ៍គ្រឹះនេះគឺត្រូវបានគេយល់មកពីពាក្យថា "គ្មានបទល្មើសគ្មានទោស បើគ្មានច្បាប់ចែង"។ យោងទៅតាមអត្ថន័យនៃពាក្យនេះ យើងអាចបែងចែកជាពីរប្រភេទផ្សេងទៀត នៃគោលការណ៍ នីត្យានុកូលភាព គឺគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស។

នីត្យានុកូលភាពនៃបទល្មើស ៖ គឺសំដៅលើអំពើណាមួយ ដែលគេអាចចាត់ទុកថាជាបទល្មើសបាន លុះត្រាតែអំពើនោះមានចែងជាមុនយ៉ាងច្បាស់លាស់ថាជាបទល្មើស បើមិនដូច្នេះទេតុលាការមិនអាចផ្តន្ទាទោសជនប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាមានគោលការណ៍មួយកំណត់ថា "គ្មានបទល្មើសណាដែល ច្បាប់មិនបានចែងឡើយ"។

នីត្យានុកូលភាពនៃទោស ៖ ដើម្បីយកទោសណាមួយទៅផ្តន្ទាលើជនណាមួយបានលុះត្រាតែ ទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នេះទេគេមិនអាចអនុវត្តទោសទៅលើបុគ្គលណាម្នាក់បានឡើយ។ ដូចនេះគឺដាច់ខាតត្រូវតែតម្រូវឱ្យមានចែងពីបទប្បញ្ញត្តិនៃទោស បើមិនដូច្នេះទេចៅក្រមមិនអាចប្រកាសលើជនណាមួយបានឡើយ គឺមិនអាចបង្កើតទោសទណ្ឌដោយខ្លួនឯងទេ ទោះជាច្បាប់បានកំណត់ថាអំពើនោះជាបទល្មើសណាក៏ដោយ។

**ឧទាហរណ៍** នៅក្នុងមាត្រា ៧៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា ការមិនព្រមបង់អាហារកិច្ច ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនិងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ប៉ុន្តែមិនមានបទបញ្ញត្តិណាមួយ ដែលចែងអំពីទោស ដែលត្រូវអនុវត្តចំពោះបទល្មើសដែលកើតឡើងពីការមិនព្រមបង់អាហារកិច្ចនេះឡើយ។[2] ហេតុនេះទើបបានជាច្បាប់ព្រហ្មទណ្ឌមាត្រា ៣២៤ បានកំណត់បទល្មើសមួយឈ្មោះថា បទបោះបង់គ្រួសារ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២០០.០០០ (ពីរសែន) រៀល។[3]

**ឧទាហរណ៍** អំពើទទួលផលចោរកម្មតាមមាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ ប្រសិនបើបុគ្គលណាម្នាក់បានប៉ុនប៉ងធ្វើនូវសកម្មភាពដូចមានចែងក្នុងមាត្រានេះ អំពើនេះគេមិនអាចចាត់ជាបទល្មើបានឡើយ។ ព្រោះនៅក្នុងបទប្បញ្ញត្តិនៃអំពើទទួលផលចោរកម្ម មិនបានចែងទុកពីទោសនៃការប៉ុនប៉ងនោះទេ។ ដូច្នេះជនដែលប៉ុនប៉ុងក្នុងអំពើនេះ មិនត្រូវបានចាត់ទុកជាបទល្មើសឡើយព្រោះមិនមានបទប្បញ្ញត្តិ ដែលចែងពីទោសនៃសកម្មភាពនោះទេ។ នេះជាការបញ្ជាក់ពីការគ្មានបទល្មើស គឺមិនអាចដាក់ទណ្ឌកម្មទេ ដូចបានបកស្រាយជូនខាងលើ លើកលែងតែករណីមួយចំនួន ដែលជាអញ្ញត្រកម្មនៃច្បាប់។

---

[2] មាត្រា ៧៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩

[3] មាត្រា ៣២៤ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

## កថាខណ្ឌទី១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងកាលវេលា

បទប្បញ្ញត្តិថ្មី ដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តនៅមុនបទបញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ឡើយ។ ការចោទប្រកាន់ដែលកំពុងតែប្រព្រឹត្តទៅនោះនឹងត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរ ត្រូវបានប្រកាសរួចហើយទោសដែលចេញពីការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។[4]

តាមខ្លឹមសារនៃមាត្រា ៩ នៃក្រមព្រហ្មទណ្ឌចែងថា បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះនឹងត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវបានចោទប្រកាន់ឡើយ។ ករណីនេះការចោទប្រកាន់នោះត្រូវបានបញ្ចប់។ ប្រសិនបើមានការផ្តន្ទាទោសស្ថាពរត្រូវបានប្រកាសរួចហើយ ទោសដែលចេញពីការផ្តន្ទាទោសនោះមិនត្រូវអនុវត្តទេ ឬត្រូវបញ្ចប់។ បានសេចក្តីថាគោលបំណងនៃមាត្រានេះ មានគោលបំណងបញ្ជាក់ថា បើច្បាប់នេះ (ច្បាប់ព្រហ្មទណ្ឌ) ចូលជាធរមានរួចហើយច្បាប់ចាស់គឺមិនអាចមានអានុភាពអនុវត្តបានឡើយ ប្រសិនបើបទល្មើសនោះត្រូវបានចោទប្រកាន់តាមច្បាប់ចាស់ខណៈដែលច្បាប់ថ្មីចូលជាធរមាននោះ ការចោទប្រកាន់ត្រូវបានកែតម្រូវតាមខ្លឹមសារនៃច្បាប់ថ្មីវិញ។ ប្រសិនបើការផ្តន្ទាទោសទោះបីចូលជាស្ថាពរក៏ដោយក៏មិនអាចមានសុពលភាពអនុវត្តដែរ ពោលគឺទោសដែលត្រូវអនុវត្តនោះនឹងត្រូវលុបចោល ឬបញ្ឈប់នូវការអនុវត្តតែម្តងព្រោះតែអានុភាពនៃច្បាប់ថ្មីនោះដូចមានបញ្ជាក់ក្នុងខ្លឹមសារ នៃមាត្រាខាងលើ។

ម្យ៉ាងទៀតបទប្បញ្ញត្តិ ដែលចែងពីទោសដែលស្រាលជាងត្រូវបានអនុវត្តភ្លាមប៉ុន្តែការផ្តន្ទាទោសដែលស្ថាពរហើយនោះត្រូវអនុវត្តទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញាត្តិ ដែលចែងពីទោសដែលធ្ងន់ធ្ងរជាងនឹងត្រូវអនុវត្តតែលើអំពើដែលបានប្រព្រឹត្ត ក្រោយចូលជាធរមាននៃបទបញ្ញត្តិនោះ។[5]

ខ្លឹមសារនេះបញ្ជាក់គោលការណ៍២ គឺគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និងគោលការណ៍ប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌស្រាលជាង។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ត្រូវផ្អែកលើគោលការណ៍ពីរផ្ទុយពីគ្នាប៉ុន្តែមិនដាច់ដោយឡែកពីគ្នានោះទេ ពោលគឺគោលការណ៍ប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង និងគោលការណ៍ប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង។

ដូចនេះមាត្រា ១០ នៃច្បាប់ព្រហ្មទណ្ឌថ្មី ត្រូវអនុវត្តភ្លាមធ្វើយ៉ាងណាឱ្យអំពើដែលប្រព្រឹត្តមុនពេលច្បាប់នេះចូលជាធរមានពុំអាចចោទប្រកាន់បានឡើយ។ ប្រសិនបើការចោទប្រកាន់ទាំងឡាយពុំទាន់ចាប់ផ្តើមទេនោះ

---

[4] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៩ ឆ្នាំ២០០៩

[5] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ ទំព័រទី ២៥ រៀបរៀងដោយ សាស្ត្រាចារ្យ អៀង សំណាង បោះពុម្ពលើកទី១ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

ការចោទប្រកាន់ទាំងនោះពុំត្រូវចាប់ផ្តើមធ្វើឡើយទេ តែបើសិនការចោទប្រកាន់បានចាប់ផ្តើមដំណើការរួចហើយ ត្រូវតែបញ្ឈប់ភ្លាមៗ។

**ឧទាហរណ៍ ក** ត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសមួយ តាមច្បាប់ចាស់ក្រោយមកបទល្មើសមួយនេះ ត្រូវបានវិសោធនកម្មដោយច្បាប់ថ្មីមានន័យថា អំពើនោះលែងមានទោសហើយ។ ដូចនេះតាមអានុភាព នៃច្បាប់ថ្មីចំពោះការចោទប្រកាន់តាមច្បាប់ចាស់ពុំត្រូវចាប់ផ្តើមធ្វើឡើយ តែប្រសិនបើការចោទប្រកាន់នេះបានចាប់ផ្តើមដំណើរការរួចហើយ ត្រូវតែបញ្ឈប់ភ្លាមដោយសារអានុភាព នៃច្បាប់ថ្មីនោះតែម្តង។

ដូចនេះនៅពេល ដែលច្បាប់ថ្មីលុបបំបាត់បទល្មើសណាមួយនោះគេហៅថា ជាច្បាប់ថ្មីស្រាលជាង។ តាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌច្បាប់ថ្មី ត្រូវអនុវត្តភ្លាមធ្វើយ៉ាងណាឱ្យអំពើដែលត្រូវបានប្រព្រឹត្តមុនពេលច្បាប់នេះ ចូលជាធរមានពុំអាចចោទប្រកាន់បានឡើយ។[6] ព្រោះវាអាចផ្ទុយអំពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើសមានច្បាប់ចែងទើបមានទោស។

## ១. ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ

ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ ជាច្បាប់ដែលកំណត់បទល្មើស និងអំពីទោសដែលត្រូវអនុវត្តលើបទល្មើស និងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ចារី។ ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុមានច្បាប់ព្រហ្មទណ្ឌជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានអានុភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។[7] ការអនុវត្តក្នុងពេលវេលានៃច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុមានគោលការណ៍ពីគឺ ៖

១. គោលការណ៍មិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌថ្មីធ្ងន់ជាងច្បាប់ចាស់

២. គោលការណ៍មិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌថ្មីស្រាយជាងច្បាប់ចាស់

### ១.១ គោលការណ៍មិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ

**គោលការណ៍មិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ** ជាភាពមិនអាចអនុវត្តថយក្រោយនៃច្បាប់ ដើម្បីផ្តន្ទាទោសនូវអំពើ ដែលកើតឡើងមុនច្បាប់ចូលជាធរមានបានឡើយ។ គោលការណ៍មិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ មានគោលបំណងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការធ្វើអំពើផ្សេងៗ ដែលច្បាប់មិនទាន់ចាត់ទុកជាបទល្មើសទោះបីជាថ្ងៃក្រោយមានច្បាប់កំណត់អំពីបទល្មើសនោះក៏ដោយ ក៏អ្នកប្រព្រឹត្តដែលកើតឡើងចាប់ពីថ្ងៃដែលច្បាប់ចូលជាធរមានប៉ុណ្ណោះ។

[6] មាត្រា ១០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[7] មាត្រា ៩៣ថ្មី រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

យោងមាត្រា ១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ១១ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ៖ គ្មានជនណាម្នាក់ត្រូវមានទោសពីបទល្មើសព្រហ្មទណ្ឌឡើយចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែន ជាបទល្មើសព្រហ្មទណ្ឌ ដែលមាននៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

សរុបមកតាមគោលការណ៍មិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ អាចអនុវត្តបានតែចំពោះអំពើល្មើសបានប្រព្រឹត្តចាប់ពីថ្ងៃ ដែលច្បាប់ថ្មីចូលជាធរមានតែប៉ុណ្ណោះ។ ចំណែកអំពើប្រព្រឹត្តមុននោះរួមទាំងអំពើដែលពុំទាន់បានជំនុំជម្រះជាស្ថាពរនៅឡើយ។ ច្បាប់ថ្មីគ្មានអានុភាពអនុវត្តទេ មិនត្រូវដាក់ទោសធ្ងន់ជាងទោសដែលបានកំណត់នៅខណៈពេល ដែលបទល្មើសព្រហ្មទណ្ឌបានប្រព្រឹត្តឡើយ។

### ១.២ គោលការណ៍ប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌស្រាលជាង

**គោលការណ៍ប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ** ជាការអនុវត្តច្បាប់មានអានុភាពគតិយុត្ត គឺក្នុងអំឡុងពេលដែលច្បាប់នៅជាធរមានមានន័យថា ចាប់ពីពេលដែលច្បាប់បានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម ហើយចូលជាធរមាននៅក្នុងរាជធានីភ្នំពេញរយៈពេល ១០ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើប្រាស់ និងនូវទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែបើច្បាប់ប្រកាសឱ្យប្រើជាប្រញាប់ត្រូវចូលជាធរមានភ្លាមៗនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។

យោងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌបានចែងថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្ដន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្តទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្ត តែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៥ ចែងថាក្នុងរឿងព្រហ្មទណ្ឌច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជា បានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។ ច្បាប់ព្រហ្មទណ្ឌស្រាលជាងមាន អានុភាពអនុវត្តចំពោះបទល្មើសទាំងឡាយដែលបានកើតឡើងមុនពេលដែលច្បាប់ថ្មីចូលជាធរមាន ហើយពុំត្រូវបានវិនិច្ឆ័យជាស្ថាពរឡើយ។ ប្រសិនបើមានសាលក្រម ឬសាលដីកាស្ថាពរហើយពុំអាចសើរើកែប្រែបានឡើយ។ លើកលែងតែទណ្ឌិតត្រូវបានដាក់ទោសដោយហេតុផលថាបានប្រព្រឹត្តអំពើណាមួយ ដែលច្បាប់ថ្មីពុំបានចាត់ទុកថាជាបទល្មើស។

## ២. ច្បាប់ទម្រង់ ឬច្បាប់នីតិវិធី

ច្បាប់ទម្រង់ ឬច្បាប់នីតិវិធី ជាច្បាប់ដែលពាក់ព័ន្ធទៅនឹងការរៀបចំប្រព័ន្ធតុលាការសមត្ថកិច្ចតុលាការ នីតិវិធីព្រហ្មទណ្ឌ ផ្លូវនៃបណ្ដឹង ឬផ្លូវតវ៉ា ការអនុវត្តទោសអាជ្ញាយុកាល នៃបណ្ដឹងអាជ្ញា និងអាជ្ញាយុកាលនៃ

ទោស។ ច្បាប់នេះត្រូវអនុវត្តភ្លាមៗចាប់ពីពេលដែលច្បាប់ចូលជាធរមាន ទោះជាត្រូវអនុវត្តទៅលើបទល្មើស ដែលបានប្រព្រឹត្តមុនពេលច្បាប់ចូលក៏ដោយ។

នៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ១១ បានចែងថា ការអនុវត្តនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទបញ្ញត្តិចាស់ឡើយ។

## កថាខណ្ឌទី២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ នៅពេលកើតមានវិវាទជាតិ បរទេស ចូលរួមដោយវិវាទនេះ។ ក្នុងករណីនេះក្រមព្រហ្មទណ្ឌបានកំណត់លើការអនុវត្ត ៖

គោលការណ៍ ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា បើបទល្មើសបានប្រព្រឹត្តនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។ សំដៅដល់ដែនដីដែលស្ថិតនៅក្រោមអធិបតេយ្យ នៃព្រះរាជាណាចក្រកម្ពុជា ដោយរួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ។[8] ហើយដែនដីក៏សំដៅដល់ស្ថានទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ប៉ុន្តែមិនមែនជាសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាទៀតឡើយ បើបទល្មើសនោះបានប្រព្រឹត្តលើស្ថានទូត ឬស្ថានកុងស៊ុលបរទេស។ សមភាពចំពោះមុខច្បាប់នៅក្នុងគោលការណ៍ដែលដីនៃច្បាប់នៅក្នុងគោលការណ៍ដែនដី នៃច្បាប់ព្រហ្មទណ្ឌ ៖

- ការអនុវត្តបទល្មើស ដែលបានប្រព្រឹត្តលើដែនដីកម្ពុជា សំដៅដល់គ្រប់ធាតុផ្សំនៃបទល្មើស ទាំងអស់ដែលបានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជាហើយជនល្មើសក៏ប្រព្រឹត្តបទល្មើសលើទឹកដីកម្ពុជាដែរ។
- ការអនុវត្តគ្រប់បទល្មើសទាំងអស់ និងគ្រប់បុគ្គលទាំងអស់ បទល្មើស ដែលចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា។

គោលការណ៍សញ្ជាតិ នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ក្នុងករណីដែលបទល្មើសបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាដោយឈរលើគោលការណ៍សញ្ជាតិ បទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីកម្ពុជា ដោយពលរដ្ឋខ្មែរទោះបីទទួលបានសញ្ជាតិខ្មែរក្រោយការប្រព្រឹត្តបទល្មើសក៏ដោយមាត្រា ១៩ បានចែងថា អនុវត្តចំពោះគ្រប់បទឧក្រិដ្ឋ និងចំពោះបទមជ្ឈិមក្នុងករណីដែនបទមជ្ឈិមនោះត្រូវបានផ្តន្ទាទោសផងដែរ ដោយច្បាប់នៃរដ្ឋបរទេសនោះ។

[8] មាត្រា ២ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

## ១. បទល្មើសប្រព្រឹត្ត ឬចាត់ថាប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា

ការអនុវត្តបទល្មើសដែលប្រព្រឹត្តលើដែនដីកម្ពុជា សំដៅដល់គ្រប់ធាតុផ្សំនៃបទល្មើសទាំងអស់ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនល្មើសក៏ប្រព្រឹត្តបទល្មើសលើទឹកដីកម្ពុជាដែរ។ ការអនុវត្តគ្រប់បទល្មើសទាំងអស់ និងគ្រប់បុគ្គលទាំងអស់បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

អំពើណាមួយនៃបទល្មើសបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ១៣ បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយ នៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍នៃភាពជាដែនដីរបស់ច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍ដែលច្បាប់ព្រហ្មទណ្ឌផ្តល់សមត្ថកិច្ចដល់តុលាការកម្ពុជា នៅពេលដែលបទល្មើសត្រូវបាន ឬសន្មតថាត្រូវបានប្រព្រឹត្តនៅលើដែនដីរបស់កម្ពុជា។ ដោយក្រមព្រហ្មទណ្ឌបានកំណត់ថា ក្នុងរឿងព្រហ្មទណ្ឌច្បាប់ព្រហ្មទណ្ឌត្រូវអនុវត្តទៅលើ ៖

- បទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តនៅលើដែនដីប្រទេសកម្ពុជា។ ដែនដីកម្ពុជារួមមានទាំងដែនគោក លំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដី នៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើស ដែលប្រព្រឹត្តនៅក្នុងនាវាមានសញ្ជាតិខ្មែរ ទោះបីស្ថិតនៅទីណាក៏ដោយ។
- នាវាបរទេស ដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យ ឬឱ្យចាប់នាវាតាម អំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។
- បទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានស្ថាន ដែលចុះបញ្ជីនៅប្រទេសកម្ពុជា ទោះបីនៅទីណាក៏ដោយ។

## ២. បទល្មើសប្រព្រឹត្តនៅក្រៅដែនដី នៃព្រះរាជាណាចក្រកម្ពុជា

គោលការណ៍បុគ្គលភាពសកម្ម គឺច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងមានសមត្ថកិច្ច ទោះជាបទល្មើស ត្រូវបានប្រព្រឹត្តនៅទីណាក៏ដោយឱ្យតែចារីជាពលរដ្ឋខ្មែរ។ នៅក្នុងមាត្រា ១៩ នៃក្រមព្រហ្មទណ្ឌបានចែងថា នៅក្នុងរឿងច្បាប់ព្រហ្មទណ្ឌកម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីកម្ពុជា។[9] ចំពោះបទមជ្ឈិម លុះត្រាតែអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។ ច្បាប់កម្ពុជាមានសមត្ថកិច្ចអនុវត្តក្នុងករណីដែលជនល្មើស ឬជនរងគ្រោះមានសញ្ជាតិជាខ្មែរកាលបើ បទល្មើសបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

[9] មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

- បទឧក្រិដ្ឋ ដែលមានជនរងគ្រោះជាជនជាតិខ្មែរមាត្រា ២០ ក្នុងរឿងព្រហ្មទណ្ឌច្បាប់កម្ពុជាត្រូវបាន អនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរនៅក្នុងពេល ដែលបទល្មើសត្រូវបាន ប្រព្រឹត្ត។[10]
- លក្ខខណ្ឌនៃការធ្វើបណ្តឹងចោទប្រកាន់មាត្រា ២១ ដំណើរការ នៃនីតិវិធីធ្វើឡើងតាមបណ្តឹង អយ្យការដែលការចោទប្រកាន់ត្រូវមានបណ្តឹងពីរជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការ របស់អាជ្ញាធរនៃប្រទេសដែលជាកន្លែងនៃអំពើនោះបានប្រព្រឹត្ត។[11]

## ៣. បត្យាប័ន

បត្យាប័ន ជាការបញ្ជូនជនល្មើសពីប្រទេសមួយទៅប្រទេសមួយទៀត ហើយបត្យាប័ននេះកើតមាន ឡើងលុះត្រាតែមានការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ។ ទន្ទឹមនឹងនេះការព្រមព្រៀងនេះ គឺពឹងផ្អែកទៅលើឆន្ទៈរបស់ រដ្ឋទទួលសំណើរក្នុងការផ្ទេរជនល្មើសឱ្យទៅរដ្ឋដាក់សំណើរ។ ចំពោះការផ្ទេរជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយត្រូវ ពឹងផ្អែកលើសន្ធិសញ្ញា ក៏ប៉ុន្តែសន្ធិសញ្ញាពុំមែនជាលក្ខខណ្ឌចាំបាច់សម្រាប់ការធ្វើបត្យាប័ននោះទេ វាគ្រាន់តែ ជាផ្នែកមួយដែលជួយសម្រួលដល់ការធ្វើបត្យាប័នប៉ុណ្ណោះ។ និយាយជារួមបត្យាប័នអាចធ្វើបានដោយមិន ចាំបាច់មានសន្ធិសញ្ញាដែរ។

[10] មាត្រា ២០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[11] មាត្រា ២១ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

# ជំពូកទី២

# ធាតុផ្សំសត្យានុម័ត

# ជំពូកទី២

# ធាតុផ្សំសត្យានុម័ត

ធាតុផ្សំសត្យានុម័ត ជាអង្គហេតុ ឬជាហេតុការទាំងឡាយណាដែលបង្កឱ្យកើតមាននូវអាក្បកិរិយាណាមួយ។ អង្គហេតុទាំងនេះច្រើនសន្ធឹកសន្ធាប់ណាស់អាចជាអំពើវិជ្ជមាន ជាអំពើអវិជ្ជមាន អំពើកើតឡើងភ្លាមៗ ឬអូសបន្លាយក្នុងពេលវេលា អំពើកើតឡើងម្តងម្កាល ឬជាទម្លាប់ អំពើធម្មតា ឬស្មុគស្មាញ។ បទល្មើសកើតឡើងតែក្នុងករណី ដែលមានអាកប្បកិរិយាជាសម្ភារៈសម្តែងចេញខាងក្រៅតែប៉ុណ្ណោះ អាកប្បកិរិយានេះទៀតសោតត្រូវបានហាមឃាត់ដោយច្បាប់ ពោលគឺច្បាប់បានបញ្ញត្តិទុក។ អំពើដែលស្តែងឱ្យឃើញយ៉ាងពិតប្រាកដពីបំណងក្នុងការប្រព្រឹត្តបទល្មើសមានដូចជា ៖ តាមរយៈកាយវិការ សំដី សំណេរ ឬអាកប្បកិរិយាសាមញ្ញណាមួយផ្សេងទៀត។

**ឧទាហរណ៍** ឈ្មោះ **ក** បានធ្វើសកម្មភាពលួចម៉ូតូហើយត្រូវបានមន្ត្រីនគរបាល ធ្វើការឃាត់ខ្លួននៅនឹងកន្លែងដែលខ្លួនបានប្រព្រឹត្ត។ **ឧទាហរណ៍នេះបញ្ជាក់ថា** សកម្មភាពដែលយើងកំពុងតែបកស្រាយនេះ គឺសំដៅដល់អំពើដែលឈ្មោះ **ក** បានធ្វើសកម្មភាពលួចម៉ូតូរបស់អ្នកដទៃនេះ។ សូមបញ្ជាក់ថា សកម្មភាព ឬអំពើដែលចាត់ទុកជាបទល្មើសបានលុះត្រាតែសកម្មភាព ឬអំពើនោះត្រូវបានច្បាប់ចាត់ទុកថាជាបទល្មើស មិនមែនបានន័យថា គ្រប់សកម្មភាពសុទ្ធតែជាបទល្មើសនោះឡើយ។

## ផ្នែកទី១ សញ្ញាណទូទៅ និងប្រភេទផ្សេងៗនៃអំពើដែលជាធាតុផ្សំសត្យានុម័ត

### ១. សញ្ញាណទូទៅ

ជាទូទៅអំពើមួយតែងផុសចេញពីគំនិតជាមុន គំនិត ឬបំណងក្នុងការប្រព្រឹត្តបទល្មើសមិននាំឱ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌឡើយ។ នេះជាវិធានដែលមានគោលបំណងការពារសិទ្ធិសេរីភាពរបស់បុគ្គលក្នុងការធ្វើសកម្មភាព ហើយម្យ៉ាងវិញទៀតគំនិតដែលមិនទាន់លេចចេញជារូបរាងមកខាងក្រៅផង ពុំនាំឱ្យមានការអន្តរាយដល់សង្គមទេ។

### ២. ប្រភេទផ្សេងៗ នៃអំពើដែលជាធាតុផ្សំសត្យានុម័ត

បទល្មើសត្រូវតែស្តែងឡើងដោយអំពើជាសម្ភារៈដែលគេអាចពិនិត្យឃើញបាន។ តាមអំពើសម្ភារៈ របស់បទល្មើសគេបែងចែករវាងបទល្មើសបានសម្រេចផល និងការប៉ុនប៉ង។ នៅពេលដែលបទល្មើសបានសម្រេចផល ពោលគឺបានឈានដល់គោលដៅចប់សព្វគ្រប់ ហើយចារីត្រូវតែផ្តន្ទាទោស ប៉ុន្តែអ្វីដែលចោទជាការលំបាកក្នុងការកំណត់ទណ្ឌកម្ម គឺនៅពេលដែលអំពើពុំទាន់ចប់សព្វគ្រប់នៅឡើយ។

## ផ្នែកទី២ ការប៉ុនប៉ង

អំពើល្មើសមួយអាចផ្តន្ទាទោសបាន ច្បាប់មិនតម្រូវឱ្យរងចាំរហូតដល់លទ្ធផលបានសម្រេចនោះទេ។ ដំណាក់កាល នៃការប្រព្រឹត្តបទល្មើសមានពីរសំខាន់ៗគឺ ៖

- ដំណាក់កាលខាងក្នុង សំដៅលើគំនិតប្រព្រឹត្តបទល្មើស ចំណង់ប្រព្រឹត្តបទល្មើស និងការសម្រេចថាប្រព្រឹត្តបទល្មើស ឬអាចនិយាយម្យ៉ាងទៀតថា ជាការសម្រេចចិត្ត ដែលនឹងធ្វើឱ្យគំនិតរបស់ខ្លួនបានទទួលផ្លែផ្កា។
- ដំណាក់កាលខាងក្រៅ ជាដំបូងចាប់ផ្តើមដោយការរៀបចំដូច ជាការសិក្សាទៅលើទីកន្លែងប្រព្រឹត្ត ឬការទិញអាវុធ បន្ទាប់មកឈានដល់ការប្រព្រឹត្តបទល្មើស ឬការប្រព្រឹត្ត និងចុងក្រោយបំផុត គឺជាលទ្ធផលជា ព្យសនកម្ម ដែលចារីប្រាថ្នាចង់បាន។

ប្រសិនបើការប្រព្រឹត្តបទល្មើស ឈានរហូតដល់ដំណាក់កាលចុងក្រោយ បទល្មើសជាបទល្មើសសម្រេចផល។ ប្រសិនបើការប្រព្រឹត្តត្រូវអាក់ខានទៅវិញ គឺជាការប៉ុនប៉ង។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់លាស់អំពីធាតុផ្សំ នៃការប៉ុនប៉ងមានទោស និងទណ្ឌកម្ម ដែលត្រូវអនុវត្តលើការប៉ុនប៉ងប្រព្រឹត្តបទល្មើស។

**ឧទាហរណ៍** ឈ្មោះ ខ បានធ្វើសកម្មភាពឆ្លុះសោម៉ូតូ ដែលចតទុកចោលមុខភោជនីយដ្ឋានមួយ។ ខណៈពេលដែលកំពុងតែឆ្លុះសោនោះត្រូវបានម្ចាស់ម៉ូតូមកទាន់ហើយចាប់ឃាត់ខ្លួនរួចបញ្ជូនទៅឱ្យមន្ត្រីនគរបាលដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។

**តាមឧទាហរណ៍នេះ** ឃើញថាឈ្មោះ ខ មានបំណងលួចម៉ូតូរបស់អ្នកដទៃ តែនៅពេលធ្វើសកម្មភាពមិនទាន់ទាំងលួចម៉ូតូបានផង ស្រាប់តែសកម្មភាពរបស់គាត់ត្រូវបានបញ្ឈប់ទៅវិញ។ ប៉ុន្តែការបញ្ឈប់នេះមិនមែនឈប់ដោយឆន្ទៈរបស់ខ្លួនទេ។ ពោលគឺត្រូវបានឈប់ដោយសកម្មភាពរបស់អ្នកដទៃ (ម្ចាស់ម៉ូតូ) ដែលមានអានុភាពរារាំង ដល់ការប្រព្រឹត្តបទល្មើសបានសម្រេច នេះហើយដែលបញ្ជាក់ពីការប៉ុនប៉ង ដែលជាសកម្មភាពរបស់ជនល្មើសក្នុងប្រព្រឹត្តបទល្មើសមិនបានសម្រេចមិនដល់គោលដៅ ហើយត្រូវបានរារាំងដោយព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ជនល្មើស ដោយសកម្មណាមួយរបស់អ្នកដទៃ ដែលមានអានុភាពធ្វើឱ្យអាក់ខានទៅដល់ការប្រព្រឹត្តបទល្មើស។ សកម្មភាពនេះហើយដែលចាត់ទុកជាការប៉ុនប៉ង តែផ្ទុយទៅវិញកាលបើជនល្មើសបានបញ្ឈប់នូវសកម្មភាពដោយខ្លួនឯងគេមិនចាត់ទុកថា ជាការប៉ុនប៉ងឡើយ។

**១. ធាតុផ្សំ នៃការប៉ុនប៉ងមានទោស**

មាត្រា ២៥ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌបានចាត់ទុកជាចារីចំពោះបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬច្បាប់បានចែងទុកបទមជ្ឈិម។

មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌការប៉ុនប៉ងក្នុងបទឧក្រិដ្ឋត្រូវទទួលការផ្តន្ទាទោស ចំណែកឯការប៉ុនប៉ងក្នុងបទមជ្ឈិមវិញទទួលការផ្តន្ទាទោសកាលបើច្បាប់បានចែង។ មាត្រា ២៧ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌក្នុងបទលហុពុំទទួលការផ្តន្ទាទោសទេ។ មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ចារីបានចាប់ផ្តើមអនុវត្តបទល្មើសមានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។[12] ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនវិញដោយស្ម័គ្រចិត្តទេតែត្រូវបានរាំងស្ទះ ឬអាក់ខានដោយសារឥទ្ធិពលនៃកាលៈទេសៈខាងក្រៅឆន្ទៈរបស់ចារី។

**ក. ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ**

ជាគោលការណ៍គ្រប់ការប៉ុនប៉ងសម្រាប់បទឧក្រិដ្ឋ គឺត្រូវបានចាត់ទុកថា ជាបទល្មើសនឹងត្រូវផ្តន្ទាទោសដូចជាការប្រព្រឹត្តបទល្មើសបានសម្រេចដែរ។ ទោះបីការប្រព្រឹត្តបទល្មើសនោះមិនបានសម្រេចក៏ដោយឱ្យតែមានការប៉ុនប៉ងចាត់ទុកជា បទល្មើសទាំងអស់។

**ឧទាហរណ៍** ឈ្មោះ **ក** មានគម្រោងដើម្បីនឹងសម្លាប់ឈ្មោះ **ខ** ខណៈពេលកំពុងតែធ្វើសកម្មភាពឈ្មោះ **ក** បានដកកាំភ្លើងបាញ់ទៅឈ្មោះ **ខ** ប៉ុន្តែសំណាងកាំភ្លើងនោះបាញ់មិនចេញបន្ទាប់មកឈ្មោះ **ក** ត្រូវមន្ត្រីនគរបាលចាប់ខ្លួនបាន។ តាមអង្គហេតុឈ្មោះ **ក** មានបំណងដើម្បីសម្លាប់ឈ្មោះ **ខ** តែការប្រព្រឹត្តបទលើសនេះមិនបានសម្រេចក៏ពិតមែនតែឈ្មោះ **ក** បានជាប់ចោទពីបទការប៉ុនប៉ង ប្រព្រឹត្តបទឃាតកម្មរួចស្រេចទៅហើយ។ មានន័យថា ច្បាប់ចាត់ទុកសកម្មភាពនៃការប៉ុនប៉ងនេះ ដូចជាការប្រព្រឹត្តបទល្មើសបានសម្រេចដែរ។ ដូច្នេះហើយទើបមានការដាក់ទោសទណ្ឌកម្មលើអំពើនេះទោះបីការប្រព្រឹត្តមិនទាន់បានសម្រេចក៏ដោយ។

**ខ. ការប៉ុនប៉ងក្នុងបទមជ្ឈិម**

ជាគោលការណ៍ សម្រាប់បទមជ្ឈិមវិញអាចត្រូវបានចោទប្រកាន់នឹងត្រូវផ្តន្ទាទោសទៅបានលុះត្រាតែច្បាប់បានកំណត់ទុកជាមុនអំពីការប៉ុនប៉ងទើបចាត់ទុកថា ជាបទល្មើស។ ផ្ទុយទៅវិញក្នុងករណីដែលច្បាប់មិនបានចែងអំពីការប៉ុនប៉ងទេការប៉ុនប៉ងមិនត្រូវបានចាត់ទុកថា ជាបទល្មើសឡើយ ទោះបីបុគ្គលបានប៉ុនប៉ង ក៏ដោយ ក៏មិនចាត់ទុកជាបទល្មើសដែរ ផ្សាភ្ជាប់និងគោលការណ៍នីត្យានុកូលភាព ឬករណីបុគ្គលបានប្រព្រឹត្តបទល្មើសមិនបានសម្រេចដោយបានបញ្ឈប់សកម្មភាព ដោយការស្មគ្រ័ចិត្តរបស់ខ្លួន សម្រាប់លក្ខខណ្ឌមួយចំនួន

[12] មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

នោះទង្វើនេះ មិនចាត់ទុកជាការប៉ុនប៉ងទេ។ ដូចនេះការប៉ុនប៉ងនឹងត្រូវចាត់ទុកជា បទល្មើសបានលុះត្រាច្បាប់បានចែងជាក់លាក់ពីទោសនៃការប៉ុនប៉ងនោះ។

**ឧទាហរណ៍ បទល្មើសសញ្ចារកម្ម** (មាត្រា ២៨៤ នៃក្រមព្រហ្មទណ្ឌ) ខ្លឹមសារនៃមាត្រានេះបានបង្ហាញថា កុំថាឡើយប្រព្រឹត្តបានសម្រេចសូម្បីតែបានប៉ុនប៉ងក៏ត្រូវមានទោសដែរ។[13] តាមមាត្រា ២៩៤ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងផ្នែកនេះត្រូវផ្តន្ទាទោសដូចគ្នា និងបទមជ្ឈិមខាងលើដែរ។[14]

**ឧទាហរណ៍ បទគំរាមកំហែងហែកកេរ្តិ៍** (មាត្រា ៣៧២ នៃក្រមព្រហ្មទណ្ឌ) ខ្លឹមសារនៃមាត្រានេះបានបង្ហាញថា អំពើគំរាមកំហែងហែកកេរ្តិ៍ជាអំពើប្រព្រឹត្តដោយគំរាមកំហែង ឬទម្លាក់កំហុសលើអំពើដែលនាំឱ្យប៉ះពាល់កិត្តិយស ឬការរាប់អានដើម្បីទទួលបាននូវហត្ថលេខា ឬស្នាមម្រាមដៃជាដើមនោះចាត់ទុកជា បទគំរាមកំហែងហែកកេរ្តិ៍។ បទមជ្ឈិមប្រភេទនេះ សូម្បីតែបានប៉ុនប៉ងក៏ត្រូវមានទោសដែរ[15] តាមមាត្រា ៣៧៥ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមមានចែងក្នុងផ្នែកនេះត្រូវផ្តន្ទាទោសដូចគ្នា និងបទមជ្ឈិមខាងលើដែរ។[16] ផ្ទុយទៅវិញការប៉ុនប៉ងនឹងមិនមានទោសឡើយប្រសិនបើច្បាប់មិនបាន ចែងពីទោសនៃការប៉ុនប៉ងទេ។

**ឧទាហរណ៍ បទស្រវឹងជាក់ស្តែង** (មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌ) បុគ្គលដែលស្ថិតនៅក្នុងភាពស្រវឹងយ៉ាងជាក់ស្តែងនៅលើផ្លូវសាធារណៈ។[17]

**ឧទាហរណ៍ បទទទួលផលចោរកម្ម** (មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ) ជាអំពើទទួល ឬលាក់បំបាំងរក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយដោយដឹងថា វត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬមជ្ឈិម។[18]

បទល្មើសទាំងពីរនេះជាប្រភេទនៃបទមជ្ឈិម ហើយការដាក់ទោសអាចនឹងប្រព្រឹត្តទៅបានលុះត្រាតែអំពើនោះប្រព្រឹត្តបានសម្រេចឬដល់គោលដៅ។ ផ្ទុយទៅវិញប្រសិនបើអំពើនោះប្រព្រឹត្តមិនបានសម្រេច ឬបានប៉ុនប៉ងនោះច្បាប់មិនចាត់ទុកថា វាជាបទល្មើសឡើយព្រោះតែច្បាប់មិនបានចែងពីទោសនៃការប៉ុនប៉ង នៃអំពើទាំងនោះ។

ជារួម សម្រាប់បទមជ្ឈិម ការប៉ុនប៉ងមានទោសលុះត្រាតែបទល្មើស ដែលត្រូវបានចោទប្រកាន់នោះមានចែងយ៉ាងជាក់លាក់ពីទោសនៃការប៉ុនប៉ងផ្ទុយទៅវិញករណីដែលបទល្មើស ត្រូវបានចោទប្រកាន់លើជន

---

[13] មាត្រា ២៨៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[14] មាត្រា ២៩៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[15] មាត្រា ៣៧២ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[16] មាត្រា ៣៧៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[17] មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[18] មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

នោះច្បាប់មិនបានចែងអំពីទោសនៃការប៉ុនប៉ងទេនោះ កាលបើជននោះប្រព្រឹត្តនូវការប៉ុនប៉ង ឬប្រព្រឹត្តមិនបានសម្រេច គឺមិនអាចត្រូវបានចាត់ទុកថា ជាបទល្មើសឡើយ។

### គ. ការប៉ុនប៉ងក្នុងបទលហុ

ចំពោះបទលហុ ក៏មានការប៉ុនប៉ងដែរ។ ជាគោលការណ៍ (មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ) ការប៉ុនប៉ងសម្រាប់បទលហុគ្មានទោសទេ។[19] ពោលគឺការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសឡើយ។ ព្រោះតែច្បាប់មិនបានចែងពីទោសនៃការប៉ុនប៉ងសម្រាប់បទលហុ។ ដូច្នេះគ្រប់បទលហុមិនមែនសុទ្ធតែជា បទល្មើសឡើយ។ គេមិនអាចដាក់ទណ្ឌកម្មលើអំពើនោះបានទេដោយសារមិនមែនជាបទល្មើស។

ការប៉ុនប៉ងត្រូវបានបែងចែកជាបីគឺ ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ចំពោះស្ថានភាពនៃការកំណត់ទោសវិញការប៉ុនប៉ងក្នុងបទឧក្រិដ្ឋគឺមានទោស ពោលគឺចាត់ទុកដូចជា ការប្រព្រឹត្តបទល្មើសបានសម្រេចដែរទោះបីអំពើ ដែលធ្វើនោះមិនបានសម្រេច ឬមិនដល់គោលដៅក៏ដោយ។ ដោយឡែកសម្រាប់បទមជ្ឈិមវិញត្រូវបែងចែកជាពីរគឺ ទី១ការប៉ុនប៉ងមានទោសលុះត្រាបទល្មើសដែល ត្រូវបានចោទប្រកាន់នោះច្បាប់បានចែងយ៉ាងជាក់លាក់អំពីទោសនៃការប៉ុនប៉ង ទើបការប៉ុនប៉ងនៃអំពើនោះត្រូវចាត់ទុកជាបទល្មើស ទើបអាចដាក់ទោស។ ផ្ទុយទៅវិញករណីអំពើដែលត្រូវបានចោទប្រកាន់លើជនល្មើស ច្បាប់មិនបានចែងពីទោស នៃការប៉ុនប៉ងទេគេមិនអាចដាក់ទណ្ឌកម្មលើអំពើនោះបានឡើយដោយសារតែវាមិនមែនជាបទល្មើស។ ការកំណត់យ៉ាងនេះ គឺកុំឱ្យផ្ទុយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស ព្រោះគេមិនអាចដាក់ទណ្ឌកម្មណាមួយ ដែលច្បាប់មិនបានចែងថា អំពើនោះជាបទល្មើសនោះឡើយករណីនេះអាចប្រព្រឹត្តទៅបានលុះត្រាតែមានច្បាប់ចែងទើបគេអាចដាក់ទណ្ឌកម្មបាន។ ដោយឡែកសម្រាប់បទលហុវិញ ការប៉ុនប៉ងក៏មានផងដែរ តែច្បាប់បានចែងថា ការប៉ុនប៉ងសម្រាប់បទលហុគ្មានទោសទេ។ ដូច្នេះគ្រប់ការប៉ុនប៉ងសម្រាប់បទលហុមិនត្រូវបានចាត់ទុកថាជាបទល្មើសឡើយ។

### ១.១. ការចាប់ផ្តើមអនុវត្ត និងការរាក់ខាននៅវិញដោយអឆន្ទៈ

ការអនុវត្តស្តែងឡើងតាមរយៈអំពើជាសម្ភារៈ កើតឡើងដោយចារីមានបំណងប្រព្រឹត្តបទល្មើស ដែលខ្លួនចង់សម្រេចផលឱ្យខានតែបានទោះជាក្នុងកាលៈទេសៈណាក៏ដោយ។ ការប្រព្រឹត្តបទល្មើសរមែងតែងបានចាប់ផ្តើមឡើងដោយសារការសម្រេចចិត្តនៅក្នុងគំនិត ដែលនៅដំណាក់កាលនេះមិនទាន់អាចត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់បានឡើយ។ នៅពេលដែលចារីបានសម្រេចចិត្តយ៉ាងមុតមាំថានឹងប្រព្រឹត្តបទល្មើសហើយចារីនឹងធ្វើការត្រៀមបម្រុង ដែលជាដំណាក់កាលទីពីរបន្ទាប់ពីបានសម្រេចចិត្តរួចហើយ។ កិច្ចការទាំងឡាយដែលធ្វើ

[19] មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ឡើងនៅក្នុងដំណាក់កាលត្រៀមបម្រុង ក៏ពុំទាន់អាចត្រូវផ្តន្ទាទោសបានការដាក់ទណ្ឌកម្មលើអំពើនេះទេ ទោះបីការប្រព្រឹត្តមិនទាន់បានសម្រេចក៏ដោយ។ ដើម្បីឱ្យការប៉ុនប៉ងមានទោសការអាក់ខានមិនបានសម្រេចបទល្មើសត្រូវបំពេញលក្ខខណ្ឌពីរយ៉ាង ៖

- ការអាក់ខានមិនបានប្រព្រឹត្តអំពើត្រូវកើតឡើងមុនពេល ដែលបទល្មើសបានសម្រេចផល។ ត្រង់ចំណុចនេះការអាក់ខានខុសពីការស្តាយក្រោយសកម្មភាពរបស់ជនល្មើស។
- ការអាក់ខានមិនត្រូវកើតចេញពីឆន្ទៈ របស់ជនល្មើសទេ។

## ២.ការផ្តើមគំនិត និងការសមគំនិត

ចំពោះជនទាំងឡាយណាដែលបានចូលរួមប្រព្រឹត្តបទល្មើសដោយមិនផ្ទាល់ ឬខ្លះៗតែប៉ុណ្ណោះគេអាចចាត់ទុកជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិត។ តាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល ៖

- ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា។
- បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់អំណោយដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេចឬបានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃបទ ឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[20]

ការសមគំនិតត្រូវបានបញ្ញត្តិនៅមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌថា ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណា ដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[21]

**ឧទាហរណ៍** ឈ្មោះ **ក** បានសន្យាផ្តល់ប្រាក់ចំនួន ២០ម៉ឺនរៀលឱ្យទៅឈ្មោះ **ខ** ប្រសិនបើឈ្មោះ **ខ** បានវាយលើឈ្មោះ **គ** ដែលមានគំនុំជាមួយឈ្មោះ **ក** ដោយហេតុចង់បានប្រាក់ចំនួន ២០ម៉ឺនរៀល ឈ្មោះ **ខ** បានវាយឈ្មោះ **គ** រហូតដល់រងរបួសជាទម្ងន់ ហើយត្រូវសាច់ញាតិបងប្អូនបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។ ក្រោយការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ទីបំផុតក៏ចាប់ឈ្មោះ **ខ** ដែលជាជនដៃដល់បាន។ ក្រោយការ

[20] មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[21] មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

សួរចម្លើយឈ្មោះ **ខ** បានសារភាពប្រាប់មន្ត្រីនគរបាលយុត្តិធម៌នូវគ្រប់រឿងរ៉ាវដែលខ្លួនបានដឹង។ ក្រោយមក ឈ្មោះ **ក** ដែលជា អ្នកផ្ដើមគំនិត ត្រូវមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួន ហើយត្រូវបានផ្ដន្ទាទោសតាមផ្លូវច្បាប់ពីបទហិង្សាក្នុងនាមជាអ្នកផ្ដើមគំនិតឱ្យប្រព្រឹត្តបទមជ្ឈិម។

**តាមអង្គហេតុឃើញថា** ឈ្មោះ **ខ** ដើរតួជាចារី ជាអ្នកធ្វើសកម្មភាពវាយទៅលើឈ្មោះ **គ** ដែលជាជនរងគ្រោះតាមបំណងរបស់ឈ្មោះ **ក** ជាថ្នូរនឹងប្រាក់ចំនួន ២០ម៉ឺនរៀល។ រីឯឈ្មោះ **ក** ជាអ្នកផ្ដើមគំនិតឱ្យមានការបង្កើតបទល្មើសទោះបីមិនបានប្រព្រឹត្តសកម្មភាពដោយខ្លួនឯងក៏ដោយប៉ុន្តែខ្លួនបានសន្យាថា នឹងឱ្យប្រាក់ចំនួន ២០ម៉ឺនរៀល បើឈ្មោះ **ខ** បានវាយឈ្មោះ **គ** ។ ដូចនេះឈ្មោះ **ក** និងឈ្មោះ **ខ** នឹងត្រូវបានផ្ដន្ទាទោសដូចគ្នាពីបទហិង្សាដោយចេតនា ក្នុងនាមជាអ្នកផ្ដើមគំនិត និងចារីក្នុងបទល្មើសតែមួយ។

**ឧទាហរណ៍** ក្រោយពីលួចម៉ូតូបានសម្រេចហើយឈ្មោះ **ខ** បានយកម៉ូតូទៅផ្ញើនៅផ្ទះរបស់ឈ្មោះ **ក** ជាមិត្តខ្លួន។ ឈ្មោះ **ក** ដឹងច្បាស់ថាម៉ូតូនេះគឺឈ្មោះ **ខ** បានលួចពីគេមកតែខ្លួននៅតែទទួលផ្ញើដោយមានចេតនាលាក់បាំង។ ក្រោយការស្រាវជ្រាវរបស់សមត្ថកិច្ចទីបំផុតឈ្មោះ **ខ** ត្រូវចាប់ខ្លួនបាន។

**វិភាគអង្គហេតុ** ឈ្មោះ **ខ** ជាចារីដែលបានប្រព្រឹត្តបទលួច (មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ) ដោយការដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃដោយទុច្ចរិតតាមរយៈអំពើលួច។[22] ចំណែកឈ្មោះ **ក** ថ្វីត្បិតតែខ្លួនមិនបានចូលរួមសកម្មភាពលួចមែនតែខ្លួនបានជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសតាមរយៈការជួយលាក់បាំងម៉ូតូដែលបានមកពីអំពើចោរកម្មដោយមានចេតនាព្រោះខ្លួនបានដឹងច្បាស់ថា ម៉ូតូនេះគឺបានមកពីអំពើលួចដែលប្រព្រឹត្តឡើងដោយឈ្មោះ **ខ** ដែលជាមិត្តខ្លួន។ កាលបើឈ្មោះ **ខ** ត្រូវផ្ដន្ទាទោសពីបទលួច ឈ្មោះ **ក** នឹងទទួលទោសពីបទសមគំនិតក្នុងអំពើលួចតាមរយៈការជួយសម្រួលដល់ការប្រព្រឹត្តបទល្មើស។

តាមឧទាហរណ៍ខាងលើ **អ្នកសមគំនិត** គឺជាជនដែលសម្រួលដោយចេតនាដល់ការសម្រេច ឬប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ ទោះបីនៅពេលចារីប្រព្រឹត្តបទល្មើសគ្មានវត្តមានរបស់អ្នកសមគំនិតនៅទីនោះក៏ដោយ ក៏អ្នកសមគំនិតនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ចំពោះករណីនេះ អ្នកសមគំនិតនឹងអាចត្រូវផ្ដន្ទាទោសទៅបានលុះត្រាតែចារីបានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមបានសម្រេច ឬក៏បានប៉ុនប៉ងចំពោះបទប្បញ្ញត្តិ ដែលច្បាប់ពិសេស និងច្បាប់ព្រហ្មទណ្ឌចែងទុក។

[22] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ចំពោះការផ្តន្ទាទោសវិញអ្នកសមគំនិត នឹងត្រូវទទួលទោសដូចជាចារីដែរទោះបីពេលធ្វើសកម្មភាពខ្លួនមិនបានចូលរួមដោយផ្ទាល់ជាមួយចារីក៏ដោយព្រោះតែអ្នកសមគំនិតបានជួយសម្រួលដោយចេតនា ឬផ្តល់ជាមធ្យោបាយដើម្បីឱ្យចារីប្រព្រឹត្តបទល្មើសបានសម្រេច ឬប៉ុនប៉ងដល់ការប្រព្រឹត្តបទល្មើស។

វាក្យសព្ទគតិយុត្តនៃនាមករណ៍របស់បុគ្គល ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដែលច្បាប់ពិសេស និងច្បាប់ទូទៅបានចែងទុក។ ក្នុងក្រមព្រហ្មទណ្ឌ បានចែងពីចារី សហចារី អ្នកសមគំនិត និងអ្នកផ្តើមគំនិតដែលមានខ្លឹមសារគតិយុត្តដូចបានបញ្ជាក់នេះ ដែលតម្រូវឱ្យអ្នកសិក្សាគប្បីស្វែងយល់ពីអត្ថន័យ នៃពាក្យទាំងអស់នេះឱ្យបានជាក់លាក់និងច្បាស់លាស់។[23] វាក្យសព្ទគតិយុត្តនេះ មានអត្ថន័យនិងលក្ខខណ្ឌគតិយុត្តខុសៗគ្នាដូចនេះអ្នកសិក្សាគប្បីស្វែងយល់នូវខ្លឹមសារទាំងនេះ ឱ្យបានជាក់លាក់ទើបយើងមានភាពងាយស្រួលក្នុងការសិក្សាមុខវិជ្ជានីតិព្រហ្មទណ្ឌនេះ។ ចំណែកនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌវិញវាក្យសព្ទគតិយុត្តគេមិនប្រើពាក្យដូចជាច្បាប់ព្រហ្មទណ្ឌទេ។ វាក្យសព្ទគតិយុត្តទាំងនោះមានជាអាទិ៍ ជនល្មើស ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន និងទណ្ឌិតជាដើម។

### ២.១. លក្ខខណ្ឌនៃការផ្តើមគំនិត និងការសមគំនិត

លក្ខខណ្ឌនៃការផ្តើមគំនិត និងសមគំនិតមាន ៣យ៉ាងគឺ ៖

- អំពើចម្បង មានទោស
- ធាតុផ្សំសត្យានុម័ត នៃការផ្តើមគំនិត និងការសមគំនិត
- ធាតុផ្សំអត្តនោម័ត នៃការផ្តើមគំនិត និងការសមគំនិត។

### ២.២. អំពើចម្បងមានទោស

មាត្រា ២៨ កថាខណ្ឌទី២ និងមាត្រា ២៩ កថាខណ្ឌទី២ បានកំណត់នូវលក្ខខណ្ឌ នៃការផ្តើមគំនិត និងការសមគំនិតអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច។ ឬទោះជាបានសម្រេចផល ឬត្រឹមតែជាការប៉ុនប៉ងក៏ដោយ។[24]

### ២.៣. ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការសមគំនិត

ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត និងការសមគំនិតចាំបាច់ត្រូវធ្វើការពិចារណាទៅលើធាតុផ្សំសត្យានុម័ត នៃការផ្តើមគំនិតដាច់ដោយឡែកពីធាតុផ្សំ នៃការសមគំនិត។ តាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌជាការផ្តល់ ជំនួយ ឬការឧបត្ថម្ភចំពោះការប្រព្រឹត្តបទល្មើសជាការរៀបចំ និងបង្កឱ្យមានភាពងាយស្រួល។

[23] សៀវភៅ នីតិព្រហ្មទណ្ឌ ទំព័រទី ៧៨ រៀបរៀងដោយ សាស្ត្រាចា អៀង សំណាង បោះពុម្ពលើកទី១ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៩

[24] មាត្រា ២៨ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ការផ្តល់មធ្យោ បាយផ្សេងៗ សម្រាប់ប្រព្រឹត្តបទល្មើសការផ្តល់អាវុធការផ្តល់រថយន្តដើម្បីសម្រួលដល់អំពើលួច។ តាមខ្លឹមសារនៃមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ធាតុផ្សំសត្យានុម័ត នៃការផ្តើមគំនិតមានសំខាន់ៗគឺ ៖ ការជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជាអ្នកផ្តើមគំនិតជាជន ដែលនៅពីក្រោយការប្រព្រឹត្តបទល្មើសជាអ្នកចាប់ផ្តើម ឱ្យមានការប្រព្រឹត្តបទល្មើស។ តាមក្រមព្រហ្មទណ្ឌការជម្រុញ នេះធ្វើឡើងតាមរយៈការណែនាំ ឬការបញ្ជា។

**២.៤. ធាតុផ្សំអត្តនោម័ត នៃការផ្តើមគំនិត និងការសមគំនិត**

ការផ្តើមគំនិត និងការសមគំនិតត្រូវកើតចេញពីចេតនាទុច្ចរិតរបស់អ្នកផ្តើមគំនិត និងអ្នកសមគំនិតក្នុងការជម្រុញ ឬបង្កឱ្យមានបទល្មើសកើតឡើង។ អ្នកផ្តើមគំនិត និងអ្នកសមគំនិតគឺជាជនដែលមានបំណងប្រព្រឹត្តអំពើផ្តើមគំនិត និងអំពើសមគំនិត ឬឱ្យច្បាស់ជាងនេះទៅទៀតគឺថា អ្នកផ្តើមគំនិត និងអ្នកសមគំនិតដឹងថាអំពើរបស់ចារីជាបទល្មើសហើយខ្លួននៅតែមានបំណងចង់ចូលរួមជាមួយចារីទៀត។ ដូចនេះប្រសិនបើការផ្តល់មធ្យោបាយ ឬការណែនាំដោយសុច្ចរិតទៅឱ្យជនម្នាក់ដែលក្រោយមកមធ្យោបាយ ឬការណែនាំនោះទៅប្រព្រឹត្តបទល្មើសគឺ ពុំមែនជាការផ្តើមគំនិត ឬជាការសមគំនិតដែលត្រូវទទួលការផ្តន្ទាទោសឡើយ។

ជាទូទៅចារីប្រព្រឹត្តបទល្មើសស្របតាមគំនិតដែលអ្នកផ្តើមគំនិត និងអ្នកសមគំនិតមានបំណងចូលរួមជាមួយគ្នាក៏ប៉ុន្តែបើចារីបែរជាប្រព្រឹត្តបទល្មើសដែល អ្នកផ្តើមគំនិត ឬអ្នកសមគំនិតមានបំណងចូលរួមជាមួយក្នុងសម្មតិកម្មបែបនេះត្រូវបែងចែកទៅតាមករណីពីរយ៉ាង ៖

១. បើភាពខុសគ្នារវាងបំណងរបស់អ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងអំពើដែលបានប្រព្រឹត្តពិតប្រាកដមានខ្លះៗតែប៉ុណ្ណោះ អ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅតែទទួលទោសដដែល ពោលគឺត្រូវតែផ្តន្ទាទោសទៅ តាមអំពើដែលចារីបានប្រព្រឹត្តពិតប្រាកដមែន។

២. បើភាពខុសគ្នាមានលក្ខណៈដាច់ស្រឡះតែម្តងរវាងបំណងរបស់អ្នកផ្តើមគំនិត ឬអ្នកសមគំនិត និងអំពើដែលបានប្រព្រឹត្តពិតប្រាកដដោយចារីអ្នកផ្តើមគំនិត ឬអ្នកសមគំនិតមិនអាចត្រូវទទួលរងការផ្តន្ទាទោស បានឡើយបានសេចក្តីថា ចារីប្រព្រឹត្តបទល្មើសដែលមិនពាក់ព័ន្ធនឹងបទល្មើសដែលអ្នកផ្តើមគំនិត ឬអ្នកសមគំនិតមានបំណងចង់ចូលរួមជាមួយនឹងចារីនោះទេ។

**២.៥. ការដាក់ទណ្ឌកម្មលើការផ្តើមគំនិត និងការសមគំនិត**

តាមកថាខណ្ឌចុងក្រោយនៃមាត្រា ២៨ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា អ្នកផ្តើមគំនិត និងអ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

តាមខ្លឹមសារនៃបទបញ្ញត្តិ នៃក្រមព្រហ្មទណ្ឌខាងលើឃើញថា អ្នកផ្តើមគំនិត និងអ្នកសមគំនិតត្រូវទទួលរងការផ្តន្ទាទោសដូចគ្នានឹងចារីដែរពោលគឺអ្នកផ្តើមគំនិត និងអ្នកសមគំនិតក៏ត្រូវទទួលរងនូវមូលទោស

និងទោសបន្ថែមដែលច្បាប់បានចែងសម្រាប់បទល្មើស ដែលជាអំពើចម្បងរបស់ចារីដែរ។ ការបញ្ញត្តិយ៉ាងដូច្នេះ មានន័យថា អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតត្រូវរួចខ្លួនទេ ក្នុងករណីដែលច្បាប់ពុំអាចផ្ដន្ទាទោសចារី ដោយសារតែមូលហេតុដូចជា ជនល្មើសបានរត់គេចខ្លួនបាត់ ឬជនល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែបានក្លាយខ្លួនជាមនុស្សវិកលចរិក។ អ្នកផ្ដើមគំនិត និងអ្នកសមគំនិតត្រូវតែទទួលការផ្ដន្ទាទោស ដោយច្បាប់បានចាត់ទុកដូចជាជននេះបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដែរ ពោលគឺតុលាការត្រូវសម្រេចដាក់ទោសអ្នកផ្ដើមគំនិត និងអ្នកសមគំនិតដោយគិតថាជននេះបានប្រព្រឹត្តអំពើជាសត្យានុម័តនៃបទល្មើសដោយផ្ទាល់ខ្លួន។ ក្រៅពីនេះតុលាការព្រហ្មទណ្ឌមានសេរីភាពពេញលេញ ក្នុងការសម្រួលទោសទៅតាមបុគ្គលិកលក្ខណៈរបស់អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត និងទៅតាមតួនាទីរបស់អ្នកទាំងនេះនៅក្នុងការប្រព្រឹត្តសកម្មភាពល្មើស។ ក្នុងន័យនេះពេលខ្លះអ្នកផ្ដើមគំនិតអាចនឹងត្រូវផ្ដន្ទាទោសធ្ងន់ធ្ងរជាងចារីទៅទៀតក៏មានដែរ។ ការបញ្ញត្តិយ៉ាងដូច្នេះពុំមែនមានន័យថា អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតត្រូវរួចខ្លួនក្នុងករណីដែលច្បាប់ពុំមានអាចផ្ដន្ទាទោសចារី ដោយសារជនមូលហេតុដូចជា ៖

ជនល្មើសបានរត់គេចខ្លួនបាត់ ឬជនល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែបានក្លាយខ្លួនជាមនុស្សវិកលចរិក។ អ្នកផ្ដើមគំនិត និងអ្នកសមគំនិតត្រូវតែទទួលការផ្ដន្ទាទោសដោយច្បាប់បានចាត់ទុកដូចជាជននេះបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដែរ ពោលគឺតុលាការត្រូវសម្រេចដាក់ទោសអ្នកផ្ដើមគំនិត និងអ្នកសមគំនិតដោយគិតថាជននេះបានប្រព្រឹត្តអំពើជាសត្យានុម័តនៃបទល្មើសដោយផ្ទាល់ខ្លួន។ ក្រៅពីនេះតុលាការព្រហ្មទណ្ឌមានគំនិត ឬអ្នកសមគំនិត និងទៅតាមតួនាទីរបស់អ្នកទាំងនេះនៅក្នុងការប្រព្រឹត្តសកម្មភាពល្មើស។ ក្នុងន័យនេះពេលខ្លះអ្នកផ្ដើមគំនិតអាចនឹងត្រូវផ្ដន្ទាទោសធ្ងន់ធ្ងរជាងចារីទៅទៀតក៏មានដែរ។ ការដាក់ទណ្ឌកម្មលើអ្នកផ្ដើមគំនិត និងអ្នកសមគំនិតអាចជួបប្រទះនឹងការលំបាកមួយចំនួនដែលត្រូវតែលើកយកមកពិនិត្យពិចារណាដូចខាងក្រោម ៖

បទល្មើសមួយចំនួនតម្រូវឱ្យចារីមានលក្ខណៈសម្បត្តិ ឬមុខងារជាក់ច្បាស់អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត។ អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទល្មើសប្រភេទនេះក៏ត្រូវផ្ដន្ទាទោសដែរទោះបីជាអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតពុំមានលក្ខណៈសម្បត្តិដែលច្បាប់តម្រូវឱ្យមានសម្រាប់ចារីក៏ដោយ។

ដូចគ្នានេះដែរ ប្រសិនបើចារីជាអនីតិជនដែលត្រូវទទួលបាននូវការបន្ថយមូលទោសលើបទល្មើស អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតមិនអាចទទួលប្រយោជន៍ពីការបន្ថយមូលទោសបែបនេះបានទេ ពីព្រោះថាចារីទទួលនូវផលប្រយោជន៍នេះដោយសារតែបុគ្គលិកលក្ខណៈផ្ទាល់របស់ចារីតែប៉ុណ្ណោះ។

# ជំពូកទី៣
# ធាតុផ្សំអត្តនោម័ត

# ជំពូកទី៣
# ធាតុផ្សំអត្តនោម័ត

ធាតុផ្សំអត្តនោម័ត ជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ អំពើសត្យានុម័តនៃបទល្មើសអាចនឹងត្រូវផ្តន្ទាទោសបានលុះត្រាតែចារីបានធ្វើសកម្មភាពដោយមានឆន្ទៈ ឬដោយដឹងថាបំពានច្បាប់ព្រហ្មទណ្ឌ។ ការកំណត់បទល្មើសតែងតែជាផ្នែកមួយនៃកំហុស ដែលកើតចេញពីទឹកចិត្តរបស់ចារី។ អំពើជាធាតុផ្សំសត្យានុម័តតែមួយពុំមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្កើតឱ្យបានជាបទល្មើសទេ។ ម្យ៉ាងទៀតអំពើសត្យានុម័ត ដែលឆ្លើយតបទៅនឹងនិយមន័យនៃបទល្មើសអាចនឹងត្រូវទទួលរងការផ្តន្ទាទោសបាន។

ដូចនេះដើម្បីបង្កើតឱ្យបានជាបទល្មើសចារីត្រូវតែប្រព្រឹត្តអំពើដោយមានកំហុស ដំបូងកំហុសអាចផ្អែកលើឆន្ទៈដែលមានទិសដៅច្បាស់លាស់ដោយសំដៅទៅរកគោលដៅខុសច្បាប់ណាមួយ ពោលគឺចារីពិតជាមានឆន្ទៈ និងដឹងពីលទ្ធផលខុសច្បាប់នៃអំពើរបស់ខ្លួនដែលគេហៅថា កំហុសចេតនា។ ក្នុងករណីខ្លះទៀតកំហុសសំដៅទៅលើស្ថានភាពដែលមិនអាចមានឆន្ទៈគ្រប់គ្រាន់ ឬការប្រុងប្រយ័ត្នគ្រប់គ្រាន់ដើម្បីជៀសវាងនូវលទ្ធផលខុសច្បាប់ដែលគេហៅថា កំហុសអចេតនា។

## ផ្នែកទី១ កំហុសចេតនា

មាត្រា ៤ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌចែងថា ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ហេតុនេះចេតនាគឺជា ធាតុផ្សំអត្តនោម័ត នៃបទល្មើសដោយចេតនា។[25]

ចេតនាប្រព្រឹត្តបទល្មើសសំដៅលើឆន្ទៈឆ្ពោះទៅរកការប្រព្រឹត្តបទល្មើស ដែលបានកំណត់ដោយច្បាប់។ មានចេតនានឹងប្រព្រឹត្តបទល្មើសកាលបើ ៖

- ចារីស្វែងរកលទ្ធផលខុសច្បាប់ពីអំពើរបស់ខ្លួន
- ចារីដឹងថាអំពើរបស់ខ្លួន នឹងផ្តល់នូវលទ្ធផលខុសច្បាប់នេះ

ចេតនាប្រព្រឹត្តបទល្មើសត្រូវរួមផ្សំដោយ ៖

- ចេតនាសម្រេចបទល្មើស គឺជាចេតនារបស់បុគ្គលម្នាក់ ដែលមានសេរីភាព និងមនសិការគ្រប់គ្រាន់ក្នុងការស្វែងរកលទ្ធផល ដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ ឬនិយាយម្យ៉ាងទៀតថាជាចេតនាចង់រំលោភច្បាប់ព្រហ្មទណ្ឌតែម្តង។ ដូចនេះចេតនាត្រូវផ្តើមចេញពីបុគ្គលម្នាក់ ដែលមានសេរីភាពពេញលេញ និង

[25] មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

មនសិការគ្រប់គ្រាន់ដឹងខុសត្រូវថាអំពើណាជាអំពើខុសច្បាប់ព្រហ្មទណ្ឌ ហើយនៅតែមានបំណង ប្រព្រឹត្តអំពើខុសច្បាប់នោះទៀត។

- ចេតនាប្រព្រឹត្តអំពើ ចារីត្រូវប្រព្រឹត្តអំពើដោយចេតនាបានន័យថា ដោយដឹងច្បាស់ពីអំពើរបស់ខ្លួន។

## ១. ប្រភេទផ្សេងៗ នៃចេតនាទុច្ចរិត

### ១.១. ចេតនាដោយចំពោះ

ចេតនាទុច្ចរិតដោយចំពោះ ជាកំហុសរបស់បុគ្គលម្នាក់ដោយក្នុងពេលប្រព្រឹត្តអំពើ ដែលបង្កគ្រោះថ្នាក់ដល់សង្គមជននេះបានដឹងជាក់ច្បាស់ថាអំពើរបស់ខ្លួនមានចរិតគ្រោះថ្នាក់ ហើយមើលឃើញច្បាស់ពិតប្រាកដនូវបច្ច័យគ្រោះថ្នាក់នៃអំពើរបស់ខ្លួនហើយចារីនៅតែចង់ឱ្យបច្ច័យនោះកើតឡើងទៀត។

### ១.២. ចេតនាដោយមិនចំពោះ

ចេតនាទុច្ចរិតមិនចំពោះគឺជាកំហុសរបស់បុគ្គលម្នាក់ដោយក្នុងពេលប្រព្រឹត្តបទល្មើសជននេះបានយល់ដឹងចរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួនដែរ តែខ្លួនពុំប៉ងប្រាថ្នាឱ្យបច្ច័យនោះកើតឡើងទេក៏ប៉ុន្តែអំពើនោះបានធ្វើឱ្យបច្ច័យណាមួយកើតឡើងទៅវិញ។ សម្រាប់ជនល្មើសលទ្ធផលនៃអំពើល្មើសមានលក្ខណៈបន្ទាប់បន្សំតែប៉ុណ្ណោះ ពីព្រោះថាអំពើរបស់ខ្លួនមានគោលដៅផ្សេងទៅវិញ។ ដោយសារតែព្រឹត្តិការណ៍ណាមួយនោះជនល្មើសបានធ្វើឱ្យកើតឡើងនូវព្យសនកម្មលើសពីអ្វីដែលខ្លួនបានគ្រោងទុកទៅទៀត។ ក្នុងករណីនេះអ្នកច្បាប់ខ្លះចាត់ទុកជាបទល្មើសដោយចេតនាដោយសារតែចារីមានចេតនាទុច្ចរិតមិនចំពោះក៏ប៉ុន្តែការកំណត់យ៉ាងដូចនេះហាក់ដូចជាធ្ងន់ធ្ងរពេកសម្រាប់ចារីដែលពុំមានចេតនាបង្កព្យសនកម្មនោះ។ ហេតុដូចនេះហើយទើបអ្នកនីតិបញ្ញត្តិបានកំណត់យក ព្យសនកម្មចុងក្រោយធ្វើជាមូលដ្ឋាននៃការកំណត់បទល្មើសជាក់លាក់ណាមួយទៅវិញ។

### ១.៣. ចេតនាទុច្ចរិតទូទៅ

ចេតនាទុច្ចរិតទូទៅ ជាចេតនារបស់ចារីក្នុងការប្រព្រឹត្តអំពើ ដែលខ្លួនបានដឹងថា ច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ចេតនាទុច្ចរិតទូទៅមាននៅក្នុងគ្រប់បទល្មើសទាំងអស់។ ចេតនាទុច្ចរិតទូទៅ គឺពុំសំដៅទៅលើចេតនាព្យាបាទណាមួយទេ គឺសំដៅទៅលើចេតនាបំពានច្បាប់ព្រហ្មទណ្ឌ ឬបំពានលើការហាមឃាត់ផ្នែកព្រហ្មទណ្ឌការបង្ហាញភស្តុតាងពីចេតនាទុច្ចរិតទូទៅរបស់ចារី គឺជាការបង្ហាញភស្តុតាងឱ្យបានឃើញពីឆន្ទៈ និងមនសិការ ដឹងខុសត្រូវពីលទ្ធផលខុសច្បាប់របស់ចារី ឬនិយាយឱ្យងាយយល់ គឺត្រូវតែបង្ហាញភស្តុតាងថាចារីចង់ប្រព្រឹត្តអំពើ ដែលខ្លួនដឹងថាច្បាប់ព្រហ្មទណ្ឌហាមឃាត់។

### ១.៤. ចេតនាទុច្ចរិតមិនច្បាស់លាស់

ចារីមានចេតនាចង់បាននូវព្យសនកម្មណាមួយ ដែលកើតចេញពីអំពើល្មើសរបស់ខ្លួនក៏ប៉ុន្តែចារីពុំបានស្គាល់ ឬដឹងមុនថានរណារងគ្រោះ នៃអំពើល្មើសរបស់ខ្លួនទេពេល គឺចារីមានចេតនាប្រព្រឹត្តបទល្មើសទៅលើជនដែលមិនអាចកំណត់ជាមុនបាន។

**ឧទាហរណ៍** ការដាក់គ្រាប់បែកបង្កប់ក្នុងសួនច្បារសាធារណៈដោយភេរវករម្នាក់។ ក្នុងករណីនេះជនល្មើសមិនបានដឹងថានរណា នឹងក្លាយជាជនរងគ្រោះនៅពេល ដែលគ្រាប់បែកនេះផ្ទុះឡើងទេហើយក៏មិនអាចដឹងមុនដែរថា នឹងធ្វើជនរងគ្រោះស្លាប់ ឬបាត់បង់ជីវិត ឬមួយគ្រាន់តែបណ្តាលឱ្យជនរងគ្រោះមានរបួសប៉ុណ្ណោះ ហេតុនេះជនល្មើសមានចេតនាទុច្ចរិតមិនច្បាស់លាស់។

### ១.៥. ចេតនាទុច្ចរិតពិសេស

បន្ថែមពីចេតនាទុច្ចរិតទូទៅអ្នកនីតិបញ្ញត្តិអាចបន្ថែមនូវចេតនាទុច្ចរិតពិសេសសម្រាប់បទល្មើសព្រហ្មទណ្ឌ ណាមួយ។ អ្នកនីតិបញ្ញត្តិពុំបានប្រើពាក្យចេតនាទុច្ចរិតពិសេសនៅក្នុងបញ្ញត្តិច្បាប់ឡើយក៏ប៉ុន្តែផ្តើមចេញពីអត្ថបទច្បាប់ដែលកំណត់បទល្មើសនីមួយៗអាចឱ្យគេយល់ពីបំណងរបស់អ្នកនីតិបញ្ញត្តិ ដែលទាមទារឱ្យរកភស្តុតាងអំពើចេតនាទុច្ចរិតពិសេសណាមួយរបស់ចារីដើម្បីឱ្យមានធាតុផ្សំ នៃបទល្មើសគ្រប់គ្រាន់។ សញ្ញាណនៃពាក្យចេតនាទុច្ចរិតពិសេសពុំត្រូវបានយល់ក្នុងន័យដូចគ្នាសម្រាប់អ្នកច្បាប់ទាំងអស់នោះទេ សម្រាប់អ្នកច្បាប់ខ្លះចេតនាទុច្ចរិតពិសេសគឺជាធាតុផ្សំផ្នែកបញ្ញាស្មារតី ដែលត្រូវបានកំណត់យ៉ាងជាក់ច្បាស់ ហើយសំដៅទៅលើចេតនាទទួលបាននូវលទ្ធផលជាក់លាក់ណាមួយ ដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ពេល គឺចារីចង់បាននូវលទ្ធផលពិសេសណាមួយសម្រាប់បទល្មើស ដែលខ្លួនប្រព្រឹត្ត។ ចេតនាទុច្ចរិតពិសេសសម្រាប់បទល្មើសណាមួយជាមូលហេតុនៃការប្រព្រឹត្តបទល្មើស ដែលអ្នកនីតិបញ្ញត្តិចាត់ទុកថា ជាធាតុផ្សំអត្តនោម័តសម្រាប់បទល្មើសនោះ។

### ១.៦. ចេតនាទុច្ចរិតធ្ងន់ធ្ងរ

មានពេលខ្លះអ្នកនីតិបញ្ញត្តិបានកំណត់យកមូលហេតុ នៃការប្រព្រឹត្តបទល្មើសមកធ្វើជាមូលហេតុនៃការកំណត់ទណ្ឌកម្មឱ្យកាន់តែធ្ងន់ធ្ងរ។ ក្នុងករណីនេះចារី មានចេតនាទុច្ចរិតធ្ងន់ធ្ងរដោយចារីមានចេតនាបង្កគ្រោះថ្នាក់យ៉ាងខ្លាំង និងធ្ងន់ធ្ងរដល់សង្គម។

**ឧទារហ៍ណ ៖ ការគិតទុកជាមុន** ស្តែងឱ្យឃើញនូវចេតនាទុច្ចរិតធ្ងន់ធ្ងរមួយមាត្រា ២០០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឱ្យនិយមន័យនៃការគិតទុកជាមុនថា ជាគម្រោងដែលបង្កើតឡើយមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ក្នុងករណីឃាតកម្មធ្វើឡើងដោយគិតទុកជាមុនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ការសម្លាប់មនុស្សដោយគិតទុកជាមុនត្រូវផ្តន្ទាទោសធ្ងន់ធ្ងរជាងការសម្លាប់មនុស្សដោយចេតនា

ដែលជាបទឃាតកម្មគិតទុកជាមុន។ ក្នុងអំពើសម្លាប់មនុស្សដោយចេតនាភ្លាមរបស់ចារីគេឱ្យឈ្មោះថាចេតនាទុច្ចរិតធម្មតា។[26]

គោលដៅប្រព្រឹត្តបទល្មើសស្តែងឱ្យឃើញពីចេតនាទុច្ចរិតធ្ងន់ធ្ងរមួយមាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហាពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម។[27]

**២. ភាពខុសគ្នារវាងចេតនាទុច្ចរិត និងមូលហេតុនៃការប្រព្រឹត្តបទល្មើស**

មូលហេតុនៃការប្រព្រឹត្តបទល្មើស គឺជាគំនិតផ្តួចផ្តើមក្នុងការប្រព្រឹត្តបទល្មើស និងជាកត្តាផ្លូវចិត្ត ដែលជម្រុញឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើស។ ខុសប្លែកពីចេតនាទុច្ចរិតដែលជាឆន្ទៈអរូបីមូលហេតុនៃការប្រព្រឹត្តបទល្មើសរមែងប្រែប្រួលទៅតាមចារីម្នាក់ៗដូចជា មានតម្រូវការផ្នែកសម្ភារៈ មានគំនិតគុំគួនសងសឹក មានការប្រច័ណ្ឌមានកំហឹង មានការអាក់អន់ចិត្ត និងមានសេចក្តីលោភលន់ជាដើម។ ចំណែកឯចេតនាទុច្ចរិត វិញមានលក្ខណៈដូចគ្នាសម្រាប់បទល្មើសណាមួយជាក់លាក់។ ចំពោះបទល្មើសឃាតកម្មចេតនាទុច្ចរិតសំដៅ លើចេតនាក្នុងការប្រព្រឹត្តអំពើដោយដឹងច្បាស់ថាច្បាប់បានហាមឃាត់ និងចេតនាចង់ធ្វើឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតទោះបីបទល្មើសប្រព្រឹត្តដោយនរណាក៏ដោយ ឬក្នុងកាលៈទេសៈណាក៏ដោយ។

មូលហេតុនៃការប្រព្រឹត្តបទល្មើសពុំមែនជាធាតុផ្សំអត្តនោម័តនៃបទល្មើសទេចំណែកឯចេតនាទុច្ចរិតវិញគឺជាធាតុផ្សំអត្តនោម័តនៃបទល្មើស ដែលពុំអាចខ្វះបានឡើយ។ ទោះបីជាមូលហេតុនៃការប្រព្រឹត្តបទល្មើសមិនត្រឹមត្រូវ ឬមួយក៏គួរឱ្យគោរពកោតសរសើរយ៉ាងណាក៏ដោយ ក៏ពុំអាចធ្វើឱ្យមានការលុបបំបាត់បទល្មើសចោលបានដែរ។

## ផ្នែកទី២ កំហុសអចេតនា

កំហុសអចេតនា គឺជាកំហុសដែលកើតឡើងពីការមិនអាចគ្រប់គ្រងឆន្ទៈរបស់ខ្លួនឯងបានមានន័យថាចារីមានបំណងធ្វើសកម្មភាពរបស់ខ្លួនក៏ប៉ុន្តែចារីពិតជាពុំមានឆន្ទៈ ឬពុំបានដឹងពីផលវិបាក ដែលកើតចេញពីអំពើរបស់ខ្លួនឡើយ។

បទល្មើសអចេតនា ធាតុផ្សំអត្តនោម័ត គឺសំដៅទៅលើកំហុសអចេតនាដែលពុំមែនជាចេតនាប្រព្រឹត្តបទល្មើសនោះតែចារីបានប្រព្រឹត្តខុស នឹងវិធានណាមួយដែលគ្រប់គ្រាន់បង្កើតបទល្មើស។ មានចែងក្នុងមាត្រា

[26] មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[27] មាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

៤ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌបានចែងថា ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។[28] ក្រមព្រហ្មទណ្ឌមិនបានផ្ដល់និយមន័យទៅលើកំហុសអចេតនាទេគ្រាន់តែរៀបរាប់ពីរបៀបនៃការសម្ដែងចេញនូវកំហុសអចេតនាតែប៉ុណ្ណោះ។ កំហុសអចេតនាគឺសំដៅទៅលើការមិនប្រុងប្រយ័ត្ន សំដៅទៅលើអំពើទាំងឡាយណាដែលបណ្ដាលមកពីការមិនប្រុងប្រៀបស្មារតីជាដើម។

## ១. ការខ្ជីខ្ជា

ការខ្ជីខ្ជា សំដៅលើការធ្វើការមិនម៉ត់ចត់ដូចជា ការបើកបរមិនគោរពផ្លាក់សញ្ញាចរាចរជាដើម។

**ឧទាហរណ៍** កម្មករម្នាក់បានឡើងជណ្ដើដោយកាន់ពូថៅនៅនឹងដៃជាមួយផងដោយម្មករនោះមិនបានកាន់ពូថៅឱ្យបានជាប់លាប់ទេ។ ស្រាបតែពូថៅនោះបានជ្រុះពីដៃកម្មករពីលើជណ្ដើរហើយបណ្ដាលឱ្យអ្នកថ្មើរជើងម្នាក់បានកំពុងតែដើរនៅពីក្រោមនោះបាត់បង់ជីវិតភ្លាមៗ។ នេះគឺជាភាពខ្ជីខ្ជារបស់កម្មរកនោះដោយធ្វើការមិនមានភាពប្រុងប្រយ័ត្នបណ្ដាលឱ្យមានអ្នកបាត់បង់ជីវិតដោយសារតែភាពខ្ជីខ្ជា របស់ខ្លួនដោយសារមិនម៉តចត់ និងមើលងាយលើស្ថានភាព។

**ឧទាហរណ៍** ការដ្ឋានសាងសង់អគារមួយកន្លែងបានរៀបចំកន្លែងការដ្ឋានរបស់ខ្លួនដោយមានស្ដង់ដារ និងត្រឹមត្រូវ និងមានដាក់ស្លាក់ហាមមិនឱ្យមកអង្គុយលេងពីក្រោមអគារកំពុងសាងសង់ ប៉ុន្តែស្រាប់តែមានមនុស្សមួយក្រុមបានមកអង្គុយលេងនៅពីក្រោយអគារនោះខណៈនោះស្រាប់តែមានដែកធ្លាក់មកពីលើបណ្ដាលឱ្យមានអ្នករងរបួស។ ករណីនេះគឺជាភាពខ្ជីខ្ជារបស់មនុស្សមួយក្រុម ដែលបានមកអង្គុយលេងនៅពីក្រោមអគារនោះមិនមែនជាការខ្ជីខ្ជារបស់ការដ្ឋានសាងសង់អគារឡើងដោយសារតែខាងការដ្ឋានសាងសង់បានរៀបចំកន្លែងសាងសង់របស់ខ្លួនមានស្តង់ដារត្រឹមត្រូវ និងមានដាក់ស្លាប់ហាមឃាត់ទៀតផង។

## ២. ការមិនប្រុងប្រយ័ត្ន

ការមិនប្រុងប្រយ័ត្ន សំដៅទៅលើអំពើទាំងឡាយណាដែលបណ្ដាលមកពីការមិនបានប្រុងស្មារតី ដោយការរើរវាយជាដើម។

**ឧទាហរណ៍** លោក **ក** បើកឡានទាំងភាពស្រវឹងជោគជាំ និងបើកឡានក្នុងល្បឿនលឿនមិនគោរពភ្លើងសញ្ញាច្បាប់ចរាចរណ៍ពេលកំពុងបើកបរ ខណៈភ្លើងសញ្ញាលោតពណ៌ក្រហម លោក **ក** បានបើកឡានឆ្លងកាត់ដោយមិនមើលភ្លើងសញ្ញា ដែលលោតពណ៌ក្រហមនោះបណ្ដាលឱ្យគាត់បានបើកឡានបុក លោក **ខ** ដែលបានដើរ

[28] មាត្រា ៤ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ឆ្លងកាត់ផ្លូវបង្កឱ្យលោក **ខ** រងគ្រោះថ្នាក់។ ការបើកបររបស់លោក **ក** បានបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ដោយសារតែភាពមិនប្រុងប្រយ័ត្នរបស់លោក **ក** និងភាពមិនប្រុងស្មារតីដែលបានបង្កព្យសនកម្មដល់លោក **ខ**។

### ៣. ការធ្វេសប្រហែស

ការធ្វេសប្រហែស មានមនសិការបានសេចក្តីថា អំពើរបស់ខ្លួនអាចបង្កឱ្យមានអន្តរាយដល់សង្គមតែចារីមាននៅប្រព្រឹត្តដោយប្រថុយប្រថានដោយគិត ឬសង្ឃឹមថាអំពើរបស់ខ្លួនមិនបង្កឱ្យមានការខូចខាតឡើយ។[29]

**ឧទាហរណ៍** អ្នកបោះវត្ថុមានទម្ងន់ធ្ងន់តាមបង្អួចផ្ទះ ប្រាកដជាដឹងជាមុនថាអំពើនោះអាចបង្កាគ្រោះថ្នាក់ដល់អ្នកដទៃដែលនៅក្រោមជាយថាហេតុតែខ្លួននៅតែប្រព្រឹត្តអំពើនោះទៀត ដោយសារការធ្វេសប្រហែសរបស់ខ្លួន។

### ៤. ការមិនគោរពកាតព្វកិច្ច ដែលច្បាប់តម្រូវ

ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ គឺជាការមិនប្រតិបត្តិតាមបទបញ្ជាទាំងឡាយ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័ន ឬសហគ្រាសណាមួយ ឬគឺជាការមិនប្រតិបត្តិតាមអ្វីដែលច្បាប់បានតម្រូវឱ្យធ្វើលិខិតបទដ្ឋានគិតយុត្តតម្រូវឱ្យមាន។ ហេតុនេះចាំបាច់ត្រូវមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយដែលជាមូលដ្ឋានឱ្យចារីបំពេញកាតព្វកិច្ចណាមួយ បើទោះបីជាកាតព្វកិច្ចនោះពុំមានលក្ខណៈជាកាតព្វកិច្ចព្រហ្មទណ្ឌក៏ដោយដូចជា ការមិនគោរពតាមក្បួនច្បាប់វេជ្ជសាស្ត្រជាដើម។

**ឧទាហរណ៍** កាលពីឆ្នាំ២០២០ មានហេតុការណ៍គ្រោះថ្នាក់មួយ បានកើតឡើងនៅម្តុំស្តាតអូឡាំពិក ដែលកើតឡើងដោយសារតែការធ្វេសប្រហែលរបស់អ្នកម៉ៅការសំណង់ និងជាងសំណង់ ក៏បានធ្វើឱ្យដែកជ្រុងប្រវែងជា ១ម៉ែត្រ ធ្លាក់ពីលើអគារកំពុងសាងសង់ត្រូវចំក្បាលស្ត្រីម្នាក់បណ្តាលឱ្យបែកលលាក្បាលស្លាប់ភ្លាមៗ។

ទង្វើនេះបង្ហាញថាទោះបីជាអ្នកម៉ៅការសំណង់ និងជាងសំណង់ ពុំមានចេតនាក្នុងការសម្លាប់ស្ត្រីម្នាក់នោះក៏ដោយ ប៉ុន្តែការខ្ជីខ្ជា ការធ្វេសប្រហែសរបស់ពួកគាត់ គឺបណ្តាលឱ្យមានមនុស្សស្លាប់បាត់បង់ជីវិត ដែលត្រូវផ្តន្ទាទោសតាមមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលមកឱ្យអ្នកដទៃស្លាប់ ៖

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬខ្ជីខ្ជា

២-ការបំពានលើកាតកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

ក្រៅពីបទល្មើស ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ក៏មានច្បាប់ផ្សេងទៀតបានចែងអំពីការផ្តន្ទាទោសនិងដាក់ពិន័យទៅលើជនដែលធ្វើឱ្យបុគ្គលដទៃស្លាប់ដោយធ្វេសប្រហែស ឬខ្វះការប្រុងប្រយ័ត្នជាអាទិ៍។

[29] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ មីន សំអុល ទំព័រទី២៦ បោះពុម្ពលើកទី១ នៅឆ្នាំ២០២០

ជាក់ស្តែង ករណីចរាចរណ៍ប្រសិនបើជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរព កាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឱ្យស្លាប់អ្នកដទៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១៥លានរៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែម មួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ។

សរុបជារួម បទល្មើសមនុស្សឃាតដោយអចេតនា ត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកឆ្នាំ២០១៥ ឬច្បាប់ពិសេសផ្សេងទៀត នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ញត្តិយ៉ាងច្បាស់ ក្នុងការផ្តន្ទាទោស និងដាក់ពិន័យចំពោះជនដែលបានប្រព្រឹត្តកំហុស ដែលកើតឡើងចេញពីការខ្ជីខ្ជា ការធ្វេស ប្រហែស ឬខ្វះការប្រុងប្រយ័ត្នរបស់ជននោះ។

## ផ្នែកទី៣. ការវាយតម្លៃកំហុសចេតនា និងកំហុសអចេតនា

សម្រាប់បទលហុជាច្រើន ចារីត្រូវបានសន្មតថាមានកំហុស នៅពេលដែលធាតុផ្សំសត្យានុម័តនៃបទ ល្មើសមានគ្រប់គ្រាន់។

**ឧទាហរណ៍** ប្រសិនបើរកឃើញថាបើកបរថយន្តមិនពាក់ខ្សែក្រវ៉ាត់ នោះចារីពិតជាបានប្រព្រឹត្តកំហុស មែនក្នុងករណីនេះហៅថា **កំហុសលហុ ឬកំហុសជាសម្ភារៈ**។ ហេតុដូច្នេះ ព្រះរាជអាជ្ញាពុំចាំបាច់ធ្វើការបង្ហាញ ភស្តុតាងពីកំហុសរបស់ចារីឡើយ ពីព្រោះគេសន្មតថាមានកំហុសនៅពេលដែលមានធាតុផ្សំសត្យានុម័តគ្រប់ គ្រាន់។

នៅក្នុងការវាយតម្លៃអំពីកំហុសរបស់ចារី គឺវាយតម្លៃអំពីធាតុផ្សំអត្តនោម័តនៃបទល្មើស ចៅក្រមមានភារ កិច្ចកំណត់អំពីស្ថានភាពស្មារតីរបស់ចារីនៅពេលប្រព្រឹត្តបទល្មើសទៅតាមរឿងក្តីនីមួយៗ។ ចារីអាចលើកសំអាង ពីការភាន់ច្រឡំរបស់ខ្លួន ចំពោះបទល្មើសដោយចេតនា ឬការប្រុងប្រយ័ត្នជាធម្មតារបស់ខ្លួនចំពោះបទល្មើស ដោយអចេតនា ដើម្បីបញ្ជាក់ពីអវត្តមាននៃធាតុផ្សំអត្តនោម័តនៃបទល្មើស។ ការភាន់ច្រឡំអាចជាការយល់ច្រឡំ របស់ជនល្មើសអំពីអត្ថន័យគតិយុត្តដែលហៅថា ការភាន់ច្រឡំពីច្បាប់ ឬជាការយល់ច្រឡំអំពីស្ថានភាពជាក់ ស្តែង នៃអំពើប្រព្រឹត្តរបស់ជនល្មើសដែលហៅថា ការភាន់ច្រឡំពីអំពើ ឬអង្គហេតុ។

### ១. ភាន់ច្រឡំអំពីច្បាប់

ការភាន់ច្រឡំពីច្បាប់ គឺជាការភាន់ច្រឡំលើវិធាច្បាប់ណាមួយមានន័យថា ចារីមានការយល់ច្រឡំទៅ លើអត្ថិភាព ឬអត្ថន័យនៃវិធានច្បាប់ណាមួយ។ ក្នុងករណីចារីយល់ច្រឡំពីចរិតផ្ទុយច្បាប់នៃអំពើរបស់ខ្លួន និយាយម្យ៉ាងទៀតថាចារីពុំបានដឹងថា ខ្លួនបំពានច្បាប់ទេចារីមានបំណងធ្វើអំពើដោយចេតនា។ ការភាន់ច្រឡំ អំពីច្បាប់មានរូបភាពយល់ច្រឡំថាអំពើរបស់ខ្លួនពុំមែនជា បទល្មើសតែច្បាប់ចាត់ទុកថាអំពើនេះជាបទល្មើស។

ការភាន់ច្រឡំអំពីច្បាប់ ពុំមែនជាមូលហេតុនាំឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះមានគោលការណ៍មួយកំណត់ថា "**គ្មាននរណាដែលមិនស្គាល់ ឬមិនស្គាល់ដឹងអំពីច្បាប់នោះឡើយ**"។[30]

**ឧទាហរណ៍** ភាន់ច្រឡំថាអំពើណាមួយពុំមែនជាបទល្មើសហើយក៏ប្រព្រឹត្តទៅ។ ប៉ុន្តែតាមច្បាប់បារាំងការភាន់ច្រឡំពីច្បាប់ខ្លះអាចឱ្យរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។

**ឧទាហរណ៍** សាងសង់លើដីដែលច្បាប់ហាមឃាត់ក្នុងការសាងសង់ ប៉ុន្តែអជ្ញាធរបានចេញច្បាប់អនុញ្ញាតឱ្យសាងសង់។

## ២. ភាន់ច្រឡំពីអំពើ ឬពីអង្គហេតុ

ការភាន់ពីអំពើ គឺជាការភាន់ច្រឡំរបស់បុគ្គលម្នាក់អំពីស្ថានភាពជាក់ស្តែងនៃអំពើរបស់ខ្លួន។ ការភាន់ច្រឡំពីអំពើដែលនាំឱ្យនាំឱ្យបាត់បង់នូវកំហុសរបស់ចារី មានលក្ខណៈពីរយ៉ាងគឺ ការភាន់ច្រឡំលើធាតុផ្សំនៃបទល្មើស និងការភាន់ច្រឡំដែលមិនអាចជៀសផុតបាន។

**ការភាន់ច្រឡំលើធាតុផ្សំនៃបទល្មើស** ការភាន់ច្រឡំលើធាតុផ្សំនៃបទល្មើស ក្នុងករណីជនណាម្នាក់បានប្រមូលសំលៀកបំពាក់របស់អ្នកដទៃទុក ដោយភាន់ច្រឡំស្មានតែជាសំលៀកបំពាក់របស់ខ្លួន។ ធាតុផ្សំអត្តនោម័តនៃអំពើលួច គឺជាការភាន់ច្រឡំអំពើដោយមានចេតនាដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃ ហេតុនេះប្រសិនបើចារីមានការភាន់ច្រឡំថា សំលៀកបំពាក់ដែលខ្លួនបានប្រមូលយកគឺជាទ្រព្យសម្បត្តិរបស់ខ្លួន គឺមានន័យថា ចារីពុំមានចេតនាយកទ្រព្យសម្បិត្តរបស់អ្នកដទៃទេ ក្នុងករណីនេះពុំមានធាតុផ្សំអត្តនោម័តទេ។

**ការភាន់ច្រឡំ ដែលមិនអាចជៀសផុតបាន** ការភាន់ច្រឡំ ដែលជាមូលហេតុនាំឱ្យបាត់បងនូវធាតុផ្សំអត្តនោម័តនៃបទល្មើសណាមួយ ចៅក្រមត្រូវពិនិត្យពិចារណាយទៅលើបញ្ញាស្មារតីរបស់ចារីស្ថានភាពចិត្តសាស្ត្រ រូបកាយរបស់ចារី នៅពេលណាចារីបានប្រព្រឹត្តបទល្មើសដើម្បីបញ្ជាក់ថា តើការភាន់ច្រឡំនោះគឺពិតជាការភាន់ច្រឡំដែលកើតឡើងដោយមិនអាចជៀសវាងបានឬយ៉ាងណា។

[30] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រចារ្យ មីន សំអុល ទំព័រទី២៨ បោះពុម្ពលើកទី១ នៅឆ្នាំ២០២០

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវប្រធានបទស្តីពី "ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ" រួចមកសបញ្ជាក់ឱ្យឃើញថាចំពោះការកំណត់បទល្មើសព្រហ្មទណ្ឌណាមួយគឺ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សានូវភាពសុខសុវត្ថិភាព និងស្ថេរភាពនយោបាយរបស់ប្រទេសជាតិ។ ដើម្បីកំណត់ថាជាបទល្មើសព្រហ្មទណ្ឌមួយបានគឺលុះត្រាតែមានធាតុផ្សំគ្រប់គ្រាន់នោះទើបអាចចាត់ទុកជាបទល្មើសមួយបាន។ ហើយចំពោះធាតុផ្សំបទល្មើសព្រហ្មទណ្ឌរួមមានដូចជា ៖

- ធាតុផ្សំនីត្យានុកូល គឺជាសំដៅលើបញ្ញត្តិច្បាប់ជាធរមាន ដែលចាត់ទុកថាអំពើណាមួយជាបទល្មើស និងច្បាប់កំណត់ឱ្យអំពើនោះត្រូវផ្តន្ទាទោសតាមច្បាប់។ ធាតុនីត្យានុកូលនៃបទល្មើស និងធាតុនីត្យានុកូលនៃទោសត្រូវតែ មានបញ្ញត្តិក្នុងច្បាប់ជាធរមាន។ ធាតុនីត្យានុកូលនៃបទល្មើសជាអំពើណាមួយដែលច្បាប់បញ្ញត្តិថាបទល្មើសជាធាតុផ្សំទាក់ទងនឹងច្បាប់។
- ធាតុផ្សំសត្យានុម័ត គឺជាអង្គហេតុ ឬជាហេតុការទាំងឡាយណាដែលបង្កឱ្យកើតមាននូវអាកប្បកិរិយាណាមួយ។ អង្គហេតុទាំងនេះច្រើនសន្ធឹកសន្ធាប់ណាស់អាចជាអំពើវិជ្ជមាន សកម្ម ជាអំពើអវិជ្ជមានអកម្ម អំពើកើតឡើងភ្លាមៗ ឬអូសបន្លាយក្នុងពេលវេលាអំពើកើតឡើងម្តងម្កាល ឬជាទម្លាប់អំពើធម្មតាស្មុគស្មាញ។ បទល្មើសកើតឡើងតែក្នុងករណីដែលមានអាកប្បកិរិយាជាសម្ភារៈសម្តែងចេញខាងក្រៅតែប៉ុណ្ណោះ អាកប្បកិរិយានេះទៀតសោតត្រូវបានហាមឃាត់ដោយច្បាប់ ពោលគឺច្បាប់បានបញ្ញត្តិទុក។
- ធាតុផ្សំអត្តនោម័ត គឺជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ អំពើសត្យានុម័តនៃបទល្មើសអាចនឹងត្រូវផ្តន្ទាទោសបាន លុះត្រាតែចារីបានធ្វើសកម្មភាពដោយមានឆន្ទៈ ឬដោយដឹងថាបំពានច្បាប់ព្រហ្មទណ្ឌ។ ការកំណត់បទល្មើស តែងតែជាផ្នែកមួយនៃកំហុស ដែលកើតចេញពីទឹកចិត្តរបស់ចារី។ អំពើជាធាតុផ្សំសត្យានុម័តតែមួយពុំមាន លក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតឱ្យបានជាបទល្មើសទេ។ ការកំណត់បទល្មើសតែងតែផ្អែកលើកំហុស ដែលកើតចេញពីទឹកចិត្តរបស់ចារីជាតុផ្សំអត្តនោម័តជាផ្នែកខាងក្នុងនៃបទល្មើស។

ផ្ទុយទៅវិញប្រសិនបើពុំមានធាតុផ្សំគ្រប់គ្រាន់នោះទេ នោះគេពុំអាចចាត់ទុកថាជាបទល្មើសមួយបានឡើយ ក្នុងចំណោមធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទាំងបីខាងលើ ប្រសិនបើខ្វះនូវធាតុផ្សំណាមួយនោះ គឺពុំអាចចាត់ទុក ជាបទល្មើសមួយបានទេ។ មួយវិញទៀតសោតទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើសក៏មានសារៈសំខាន់ណាស់ដែរ។ ក្នុងករណីនេះប្រសិនបើ គេពុំមានការបែងចែកធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌនោះទេ គឺមាន

លក្ខណងាយស្រួលក្នុងការចោទប្រកាន់បទល្មើស ដូច្នេះហើយទើបគោលការណ៍ច្បាប់ព្រហ្មទណ្ឌបញ្ញត្តិឡើងឱ្យមានភាពងាយស្រួលក្នុងការថាអំពើណាជាបទល្មើស ឬអំពើណាដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយសម្រាប់ប្រធានបទមួយនេះ គឺចង់បង្ហាញថា ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌយ៉ាងត្រឹមត្រូវតាមគោលការណ៍ច្បាប់ ជាពិសេសនោះអាចធានាឱ្យបានសុវត្ថិភាព និងស្ថេរភាពនយោបាយសង្គមជាតិទាំងមូល។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌរួចមកយើងសង្កេតឃើញថា ដើម្បីឱ្យការអនុវត្តបទល្មើសមួយបានត្រឹមត្រូវចាំបាច់ណាស់ត្រូវតែអនុវត្តទៅតាមនីតិវិធីដែលបាន កំណត់នៅក្នុងខ្លឹមសារច្បាប់។ នៅពេលដែលមានបទល្មើសមួយបានកើតឡើង ជនដែលប្រព្រឹត្តបទល្មើសត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ទោះស្ថិតនៅក្នុងឋានជាចារី ជាសហចារីជាអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិតក្ដី។ កាលបើមានធាតុផ្សំទាំងបីក្នុងនោះរួមមាន ធាតុផ្សំនីត្យានុកូលជាធាតុច្បាប់ ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តធាតុចេតនាប្រព្រឹត្តហើយជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

ជាការពិតណាស់ច្បាប់បានចែងយ៉ាងលំអិតអំពីបទល្មើសព្រហ្មទណ្ឌ និងទោសទៅលើជនដែលបានប្រព្រឹត្តបទល្មើស ដើម្បីធានាកុំឱ្យខូចសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬអំពើប្រឆាំង និងមនុស្សអំពើដែលប៉ះពាល់ នៃបូរណភាពនៃបុគ្គលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ សេរីភាព ឬសិទ្ធិរបស់មនុស្ស អំពើបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ លួច ឆក់ ប្លន់ជាដើម។ បើទោះបីជាច្បាប់បានចែងយ៉ាងលំអិតយ៉ាងណាក៏ដោយ អ្វីដែលសំខាន់គឺការអនុវត្តផ្ទាល់ដើម្បីធានាបានថាជនដែលបានប្រព្រឹត្ត គឺត្រូវទទួលទោសទៅតាមទំហំនៃអំពើរបស់ខ្លួន។ម្យ៉ាងវិញទៀតការប្រតិបត្តិរបស់ភ្នាក់ងារអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងតុលាការ ត្រូវតែធ្វើការពិនិត្យវិនិច្ឆ័យឱ្យបានត្រឹមត្រូវចំពោះការគោរពតាមច្បាប់ជាតិ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីធានាឱ្យការអនុវត្តច្បាប់របស់មន្ត្រីមានសមត្ថកិច្ចកាន់តែមានប្រសិទ្ធភាពនោះគឺត្រូវតែ ៖

- ចៅក្រមត្រូវតែរក្សាភាពមិនលំអៀង និងចៀសវាងការវិនិច្ឆ័យរឿងក្ដីមុនសេចក្ដីសម្រេច។
- ពង្រឹងការអនុវត្តនីតិវិធីនៅគ្រប់ដំណាក់កាល និងធានាការជំនុំជម្រះក្ដីដោយយុត្តិធម៌ដែលធ្វើឡើងដោយតុលាការមានសមត្ថកិច្ចឯករាជ្យ និងឥតលំអៀង។
- ពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ជាពិសេសចំពោះការឃាត់ខ្លួន ចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយ។
- មន្ត្រីសាធារណៈ រួមមានមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាត្រូវធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងនឹងភាពមាន ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទណាម្នាក់មុនពេលបើកកិច្ចជំនុំជម្រះក្ដីត្រូវបានបញ្ឈប់ជាស្ថាពរ។
- ពង្រឹងនឹងផ្សព្វផ្សាយច្បាប់ទៅឱ្យពលរដ្ឋ លើកកម្ពស់ការអានសៀវភៅ និងការចូលរួមនៅក្នុងកិច្ចការងារសង្គម។ ជារួមមកយើងមិនចង់ឃើញប្រទេសដែលមានច្បាប់ល្អ ហើយពលរដ្ឋប្រព្រឹត្តតែអំពើល្មើសនោះទេ ការយល់ដឹងរបស់ប្រជាពលរដ្ឋពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើន។

# ឯកសារយោង

# ឯកសារយោង

## ១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

## ២. ក្រម

- ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
- ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## ៣. ច្បាប់

- ច្បាប់ស្តីពីអនុវត្តក្រមរដ្ឋប្បវេណី បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ២១ក្រ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣។

## ៤. សន្ធិសញ្ញាអន្តរជាតិ

- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងក្រមព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលត្រូវបានផ្តល់សច្ចាប័នតាមច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០៨ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩។
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលត្រូវបានផ្តល់បច្ចាប័នតាមច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រកាសឱ្យប្រើសតាមព្រះរាជាក្រមលេខ នស/រកម/០៣០៥/០០៦ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥។
- កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ ដែលត្រូវបានផ្តល់សច្ចាប័នតាមច្បាប់ស្តីពីការអនុវម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េ ប្រកាសឱ្យប្រើតាមព្រះរាជាក្រមលេខ នស/រកម/០១១១/០០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១។

- សន្ធិសញ្ញាស្ដីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិចិន ដែលត្រូវបានផ្ដល់សច្ចាប័នតាមច្បាប់ស្ដីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ប្រកាសឱ្យប្រើតាមព្រះរាជាណាចក្រកម្ពុជាលេខ នស/រកម/០៧០០/០៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០។
- អនុសញ្ញាទីក្រុងវីយែន ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ ស្ដីពីទំនាក់ទំនងការទូត ដែលត្រូវបានព្រះរាជាណាចក្រកម្ពុជាផ្ដល់សច្ចាប័ននៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៦៥។
- កតិកាសញ្ញាអន្តរជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
- សច្ចាប័នតាមច្បាប់ស្ដីពីកាអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូម ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០២ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២។
- អនុសញ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦១ ស្ដីពីទំនាក់ទំនងកុងស៊ុល។

## ៥. សៀវភៅ និងមេរៀនសរសេរដោយសាស្ត្រាចារ្យ

- មេរៀនរបស់សាស្ត្រាចារ្យ **មីន សំអុល** មុខវិជ្ជានីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពនៅលើកទី១ នៅឆ្នាំ២០២០។
- សៀវភៅរៀបរៀងដោយដោយសាស្ត្រាចារ្យ **អៀង សំណាង** នីតិព្រហ្មទណ្ឌ បោះពុម្ពនៅលើកទី១ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
អធិការដ្ឋាននគរបាលខណ្ឌទួលគោក
ផែនការងារប្រឆាំងគ្រឿងញៀន

## កំណត់ហេតុស្តាប់ចម្លើយ

| | | | |
|---|---|---|---|
| នៅ | **អធិការដ្ឋាននគរបាលខណ្ឌទួលគោក** | | |
| ថ្ងៃ-ខែ-ឆ្នាំ | ថ្ងៃ សៅរ៍ ៧កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ | | |
| វេលាម៉ោង | ដប់មួយ និង សូន្យ នាទី | | |
| យើង | វរសេនីយ៍ទោ [redacted] | | |
| ឋានៈ | អធិការរងទទួលផែនការងារប្រឆាំងគ្រឿងញៀន | | |
| មន្ត្រីនគរបាលយុត្តិធម៌នៅ | **អធិការដ្ឋាននគរបាលខណ្ឌទួលគោក** | | |
| ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង | **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** | | |
| បានឃើញមាត្រា៨៦ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ | | | |
| អនុវត្តតាមបញ្ជាលោកព្រះរាជអាជ្ញា | [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ | | |
| ជំនួសដោយ | លោក | | |
| ចូលរួមដោយ | ១-លោក | វរសេនីយ៍ត្រី . [redacted] នាយផ្នែកប្រឆាំងគ្រឿងញៀន | |
| | ២-លោក | អនុសេនីយ៍ឯក . [redacted] នាយរងផ្នែក | |

**អ្នកបកប្រែភាសា**

| | | | |
|---|---|---|---|
| ឈ្មោះ(ខ្មែរ) | | ឈ្មោះ(ឡាតាំង) | |
| ភេទ | | ថ្ងៃ-ខែ-ឆ្នាំកំណើត | |
| មុខរបរ | | | |
| ជនជាតិ | | សញ្ជាតិ | |
| កម្រិតវប្បធម៌ | | | |
| លេខទូរស័ព្ទ | | | |
| អត្តសញ្ញាណប័ណ្ណលេខ | | | |
| លិខិតឆ្លងដែនលេខ | | | |
| ទីកន្លែងកំណើត | | | |
| ទីលំនៅបច្ចុប្បន្ន | | | |
| បានស្បថថា | | | |

[redacted]

## សាវតាជាតិ

| | | | | | | | |
|---|---|---|---|---|---|---|---|
| នាម និងគោត្តនាម(ខ្មែរ) | [redacted] | | | | | | |
| នាម និងគោត្តនាម(អក្សរឡាតាំង) | [redacted] | | | | | | |
| ឈ្មោះហៅក្រៅ | [redacted] | | | | | | |
| ភេទ | ប្រុស | | ថ្ងៃ-ខែ-ឆ្នាំកំណើត | | ២០០៦ | | |
| មុខរបរ | កម្មករធ្វើប្រហិត | | ប្រាក់ចំណូល/ខែ | | (គ្មាន) | | |
| ជនជាតិ | ខ្មែរ | | សញ្ជាតិ | | ខ្មែរ | | |
| អត្តសញ្ញាណប័ណ្ណលេខ | (គ្មាន) | | | | | | |
| កម្រិតវប្បធម៌ | ថ្នាក់ទី ១១ | | | | | | |
| លេខទូរស័ព្ទ | (គ្មាន) | | | | | | |
| លិខិតឆ្លងដែនលេខ | (គ្មាន) | | | | | | |
| ទីកន្លែងកំណើត | ខេត្តព្រៃវែង ។ | | | | | | |
| ទីលំនៅបច្ចុប្បន្ន | ផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ | | | | | | |
| ឪពុកឈ្មោះ | [redacted] | | អាយុ | | មុខរបរ | រត់ម៉ូតូឌុប | |
| ម្តាយឈ្មោះ | [redacted] | | អាយុ | | មុខរបរ | លក់ដូរ | |
| ប្តី/ប្រពន្ធឈ្មោះ | (គ្មាន) | | អាយុ | | មុខរបរ | | |
| កូនចំនួន | ០០ | នាក់ | ប្រុស | ០០ | ស្រី | ០០ | នាក់ |
| ប្រវត្តិទោសពីមុន | (គ្មាន) | | | | | | |

### ស្តាប់ចម្លើយ

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល១២:១០នាទីយប់រំលងអាធ្រាត្រ ក៏ស្រាប់តែមានជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ជនជាតិខ្មែរ បានខលទូរស័ព្ទមកឈ្មោះ [redacted] ហៅ ដារ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម ដោយបានពឹងឱ្យជួយទៅទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ខណៈនោះរូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ ដារ បានជិះម៉ូតូ០១គ្រឿងម៉ាក Honda DreamC125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៩ ពាក់ផ្លាកលេខ ភ្នំពេញ 1IR-8608 ជិះឌុបឈ្មោះ [redacted] ហៅ ដារ ចេញពីម្តុំ ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីទៅយកលុយចំនួន ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ពីបុរសជនជាតិចិននោះនៅម្តុំ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលណាពួកខ្ញុំទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ឱ្យជនជាតិចិនោះបានហើយ ជនជាតិចិនមិនស្គាល់ឈ្មោះ និងឱ្យថ្លៃឈ្នួល ចំនួន ១០០ដុល្លារ (មួយរយដុល្លារសហរដ្ឋអាមេរិច) ហើយរូបខ្ញុំនិងឈ្មោះ [redacted] ហៅ ដារ ចែកគ្នាក្នុងម្នាក់ ៥០ដុល្លារ (ហាសិបដុល្លារសហរដ្ឋអាមេរិច) ដោយរូបខ្ញុំបាទបានជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដារ ទៅទិញគ្រឿងញៀននៅក្នុងក្លឹប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទៅដល់រូបខ្ញុំបាទជាអ្នកដើរចូលក្នុងក្លឹបទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ពីបុរសមិនស្គាល់ឈ្មោះ:

(ពីររយដុល្លារសហរដ្ឋអាមេរិច) ពេលទិញរួចឈ្មោះ [redacted] ហៅ វណ្ណា យកម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ហុចមកឱ្យរូបខ្ញុំហើយរូបខ្ញុំបានលាក់ទុកគ្រឿងញៀននោះ នៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ រួចឈ្មោះ [redacted] ហៅ វណ្ណា បានជិះម៉ូតូឌុបរូបខ្ញុំក្នុងគោលបំណងយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ស្ថិតនៅ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលឈ្មោះ [redacted] ហៅ វណ្ណា ជិះម៉ូតូឌុបរូបខ្ញុំមកដល់ចំណុចផ្លូវលេខ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏ស្រាប់តែជួបកម្លាំងសមត្ថកិច្ចកំពុងអនុវត្តត្រួតពិនិត្យជាតិអាកុល បានធ្វើការត្រួតពិនិត្យ ភ្លាមនោះសមត្ថកិច្ចបានរកឃើញ ម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ដែលរូបខ្ញុំបាទបានលាក់ទុកនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ ខណៈនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនរូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ វណ្ណា មកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក តែម្តង ។ បញ្ជាក់ ៖ កន្លងមករូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ វណ្ណា ធ្លាប់បានទិញគ្រឿងញៀនទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ចំនួន០១លើកមកហើយ ដោយទទួលបានថ្លៃឈ្នួលចំនួន១០០ ដុល្លារ (មួយរយដុល្លារសហរដ្ឋអាមេរិច) ហើយពួកខ្ញុំចែកគ្នាក្នុង០១នាក់ ៥០ដុល្លារ (ហាសិបដុល្លារសហរដ្ឋអាមេរិច) ។

-រូបខ្ញុំបាទមិនដែលធ្លាប់ពន្ធនាគារ រឺមណ្ឌលកែប្រែទេ ។

-រូបខ្ញុំបាទមិនចេះប្រើប្រាស់ថ្នាំញៀនទេ ។

| | | | |
|---|---|---|---|
| ក្រោយពីអានដោយខ្លួនឯង ឬដោយមន្ត្រីនគរបាលយុត្តិធម៌រួចឈ្មោះ | [redacted] | | |
| ថាពិតជាត្រឹមត្រូវ និងមិនផ្លាស់ប្តូរចម្លើយ ហើយយល់ព្រមផ្តិមមេដៃស្តាំលើកំណត់ហេតុនេះជាមួយយើងនិងជំនួសការយើង ។ | | | |
| កំណត់ហេតុបានបញ្ចប់នៅវេលាម៉ោង | ដប់មួយ និង សូន្យ នាទី | នា-ថ្ងៃ-ខែ-ឆ្នាំ | ១៦-០៣-២០២៤ |

**អ្នកចូលរួម** | **ជំនួយការ** | **មន្ត្រីនគរបាលយុត្តិធម៌**

វរសេនីយ៍ត្រី. [redacted]

វរសេនីយ៍ទោ. [redacted]

**ស្នាមម្រាមដៃស្តាំសាមីខ្លួន**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ**
**អធិការដ្ឋាននគរបាលខណ្ឌទួលគោក**
*លេខ :.........០៤១..........................ព.ប.ក*

*ថ្ងៃ សៅរ៍ ៧ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤*

**<u>របាយការណ៍សំយោគ</u>**

**ស្តីពីរ៖ បទ (ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន)** បង្ក្រាបនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល០១:១០នាទីយប់រំលងអាធ្រាត្រ ប្រព្រឹត្តនៅចំណុច ផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**<u>គោរពជូន</u>**

**ឯកឧត្តម ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

*សូមជ្រាប ។*

**<u>តាមរយៈ</u>: លោក ឧត្តមសេនីយ៍ទោ ស្នងការរង ទទួលផែនការងារប្រឆាំងគ្រឿងញៀន**

**<u>កម្មវត្ថុ</u>** : បញ្ជូនសំណុំរឿងលេខ.០៤១.....ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វត្ថុតាង និងជនសង្ស័យ០២នាក់ក្នុងករណី៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ។

១.ឈ្មោះ [redacted] **ហៅ ដរ** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម មុខរបរ កម្មករធ្វើប្រហិត ស្នាក់នៅផ្ទះជួល ផ្លូវជាតិលេខ០៥ ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ អវិជ្ជមាន (គ្មានសារធាតុញៀន) ។

២.ឈ្មោះ [redacted] **ហៅ ចណ្ណា** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករធ្វើប្រហិត ស្នាក់នៅផ្ទះជួល ផ្លូវជាតិលេខ០៥ ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ អវិជ្ជមាន (គ្មានសារធាតុញៀន) ។

**<u>ឃាត់ខ្លួនជាក់ស្តែង ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង១០:០០នាទី</u>**

-បានទទួលការឯកភាពពីលោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**<u>យោង</u>** -របាយការណ៍បង្ក្រាបជាក់ស្តែងរបស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក។

-របាយការណ៍ស្តីពីការឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ ចុះថ្ងៃទី១៦-០៣-២០២៤ ។

-កំណត់ហេតុត្រួតពិនិត្យ និងបង្ក្រាបជាក់ស្តែង ចុះថ្ងៃទី១៦-០៣-២០២៤ ។

I-**ហេតុការណ៍** ៖

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល០១:១០នាទីយប់រំលងអាធ្រាត្រ កម្លាំងចម្រុះអនុវត្តត្រួតពិនិត្យជាតិអាកុល នៃអធិការដ្ឋាននគរបាលខណ្ឌទួលគោកបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ជាក់ស្តែង នៅចំណុចបណ្តោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានប្រទះឃើញជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម និងជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ បានជិះម៉ូតូចំនួន០១គ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២១ ពាក់ស្លាកលេខ ភ្នំពេញ 1-IR 8608 ដោយមានការសង្ស័យក៏បានធ្វើការឃាត់ខ្លួនត្រួតពិនិត្យឆែកឆេររកឃើញ (ម្សៅម៉ៃពណ៌សចំនួន០៤កញ្ចប់តូច និងម្សៅម៉ៃពណ៌កាហ្វេដាក់នៅក្នុងកញ្ចប់ពណ៌ក្រហមអក្សរ POSCHE ចំនួន០១កញ្ចប់រកឃើញនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំនៅជាប់ខ្លួនជនសង្ស័យឈ្មោះ [redacted] ភ្លាមនោះសមត្ថកិច្ចយើងបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ជាក់ស្តែង និងដកហូតវត្ថុតាងខាងលើ រួចបញ្ជូនមកកាន់អធិការដ្ឋាននគរបាលខណ្ឌទួលគោកធ្វើការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់ ។

បន្ទាប់ពីការឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ខាងលើ ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានចាត់មន្ត្រីជំនាញមកសហការធ្វើតេស្តិ៍ជំហានដំបូង ជាមួយមន្ត្រីជំនាញ នៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក ដោយមានការឯកភាពពីលោក [redacted] **ព្រះរាជអាជ្ញារង** នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយឲ្យយើងដកយកសំណាកក្រាមពណ៌សថ្លា ដែលសមត្ថកិច្ចបានចៀចយកចំនួនបន្តិច ដើម្បីធ្វើតេស្តជំហានដំបូង នៅចំពោះមុខជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម មុខរបរ កម្មករធ្វើប្រហិត ស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករធ្វើប្រហិត ស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយប្រើប្រាស់ឧបករណ៍ពិសោធន៍រកសញ្ញាណសារធាតុញៀនប្រភេទ MARGUIST TEST ៖ ជាលទ្ធផលសំណាកក្រាមពណ៌សចំនួន០៤កញ្ចប់តូច បានប្រតិកម្មចេញពណ៌លឿងទុំ ដែលមានតំរុយសង្ស័យ៖ *ជាសារធាតុញៀនប្រភេទកេតតាមីន* ដែលមានទម្ងន់១,៥៥ក្រាម (មួយកណ្តាក់សញ្ញាហាសិបប្រាំក្រាម) និងក្រាមពណ៌កាហ្វេចំនួន០១កញ្ចប់ធំល្មម *ជាសារធាតុញៀនប្រភេទអ៊ិចស្តាស៊ី* ដែលមានទម្ងន់ ១៤,៤៦ (ដប់បួនកណ្តាក់សញ្ញាសែសិបប្រាំមួយក្រាម) ។ បន្ទាប់មកកំលាំងសមត្ថកិច្ចជំនាញយើងក៏បានយកថង់សម្រាប់ច្រកគ្រឿងញៀន ចំនួន០៤កញ្ចប់តូច និងចំនួន០១កញ្ចប់ធំល្មម មកដាក់នៅក្នុងស្រោមសំបុត្រពណ៌សបិទជិត សម្រាប់បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមផ្លូវច្បាប់ ។

ជាមួយគ្នានេះដែរយើងបានយកទឹកនោមជនសង្ស័យចំនួន០២នាក់ខាងលើ យកមកធ្វើតេស្តិ៍ស្វែងរកសារធាតុញៀន ដោយប្រើប្រាស់ឧបករណ៍ប្រភេទ DIAGNOSTIC TEST (តេស្តិ៍រហ័សសម្រាប់ស្វែងរកសារធាតុញៀនក្នុងទឹកនោម) ដោយធ្វើតេស្តិ៍នៅចំពោះមុខជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម និងជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ដែលបញ្ជាក់យ៉ាងច្បាស់ថាជនសង្ស័យទាំងពីររូបនេះ ពិតជាពុំបានប្រើប្រាស់គ្រឿងញៀន ប្រភេទមេតំហ្វេតាមីនពិតប្រាកដមែន ។

| | | | | | | |
|---|---|---|---|---|---|---|
| ប្រពន្ធឈ្មោះ | **គ្មាន** | | អាយុ | | មុខរបរ | |
| កូនចំនួន | ប្រុស ០០ | នាក់ | ស្រី | ០០ | | នាក់ |
| **ប្រវត្តិទោសពីមុន** | (**គ្មាន**) | | | | | |

III-**ការស៊ើបអង្កេត** (ចម្លើយរបស់ជនសង្ស័យ)

- ចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ [redacted] **ហៅ ដារ** បានសារភាពថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២៤ វេលាម៉ោងប្រហែល១២:១០នាទីយប់រំលងអធ្រាត្រ ក៏ស្រាប់តែជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ជនជាតិខ្មែរ បានខលទូរស័ព្ទមករូបខ្ញុំដោយបានពឹងឱ្យរូបខ្ញុំទៅទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ខណៈនោះរូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ វណ្ណា ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ បានជិះម៉ូតូ០១គ្រឿង ម៉ាក Honda DreamC125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៩ ពាក់ផ្លាកលេខ ភ្នំពេញ 1IR-8608 ចេញពីម្តុំ ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីទៅយកលុយចំនួន ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ពីបុរសជនជាតិចិននោះនៅម្តុំ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលណារូបខ្ញុំទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ឱ្យជនជាតិចិនោះបានហើយ ជនជាតិចិនមិនស្គាល់ឈ្មោះ និងឱ្យថ្លៃឈ្នួលចំនួន ១០០ដុល្លារ (មួយរយដុល្លារសហរដ្ឋអាមេរិច) ហើយរូបខ្ញុំនិងឈ្មោះ [redacted] ហៅ វណ្ណា ចែកគ្នាក្នុងម្នាក់ ៥០ដុល្លារ (ហាសិបដុល្លារសហរដ្ឋអាមេរិច) ដោយឈ្មោះ [redacted] ហៅ វណ្ណា បានជិះម៉ូតូឌុបរូបខ្ញុំទៅទិញគ្រឿងញៀននៅក្នុង ក្លឹប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទៅដល់ឈ្មោះ [redacted] ហៅ វណ្ណា បានចូលក្នុងក្លឹបទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ពីបុរសមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ជនជាតិខ្មែរ ក្នុងតម្លៃ ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ពេលទិញរួចឈ្មោះ [redacted] ហៅ វណ្ណា យកម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ហុចមកឱ្យរូបខ្ញុំហើយរូបខ្ញុំបានលាក់ទុកគ្រឿងញៀននោះ នៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ រួចឈ្មោះ [redacted] ហៅ វណ្ណា បានជិះម៉ូតូឌុបរូបខ្ញុំក្នុងគោលបំណងយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ស្ថិតនៅ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលឈ្មោះ [redacted] ហៅ វណ្ណា ជិះម៉ូតូឌុបរូបខ្ញុំមកដល់ចំណុចផ្លូវលេខ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏ស្រាប់តែជួបកម្លាំងសមត្ថកិច្ចកំពុងអនុវត្តត្រួតពិនិត្យជាតិអាកុល បានធ្វើការត្រួតពិនិត្យ ភ្លាមនោះសមត្ថកិច្ចបានរកឃើញ ម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ដែលរូបខ្ញុំបាទបានលាក់ទុកនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ ខណៈនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនរូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ វណ្ណា មកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក តែម្តង ។

បញ្ជាក់ ៖ កន្លងមករូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ វណ្ណា ធ្លាប់បានទិញគ្រឿងញៀនទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ចំនួន០១លើកមកហើយ ដោយទទួលបានថ្លៃឈ្នួលចំនួន១០០ ដុល្លារ (មួយរយដុល្លារសហរដ្ឋអាមេរិច) ហើយពួកខ្ញុំចែកគ្នាក្នុង០១នាក់ ៥០ដុល្លារ (ហាសិបដុល្លារសហរដ្ឋអាមេរិច) ។

-រូបខ្ញុំបាទមិនដែលធ្លាប់ពន្ធនាគារ រឺមណ្ឌលកែប្រែទេ ។

-រូបខ្ញុំបាទមិនចេះប្រើប្រាស់ថ្នាំញៀនទេ ។

ចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ [redacted] **ហៅ ឧត្តរា** បានសារភាពថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល១២:១០នាទីយប់រំលងអាធ្រាត្រ ក៏ស្រាប់តែមានជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ជនជាតិខ្មែរ បានខលទូរស័ព្ទមកឈ្មោះ សុខ សីហា ហៅ ដរ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម ដោយបានពឹងឱ្យជួយទៅទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ខណៈនោះរូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ ដរ បានជិះម៉ូតូ០១គ្រឿងម៉ាក Honda DreamC125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៩ ពាក់ផ្លាកលេខភ្នំពេញ 1IR-8608 ជិះឌុបឈ្មោះ [redacted] ហៅ ដរ ចេញពីម្តុំ ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីទៅយកលុយចំនួន ២០០ដុល្លារ (ពីររយដុល្លារសហរដ្ឋអាមេរិច) ពីបុរសជនជាតិចិននោះនៅម្តុំ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលណាពួកខ្ញុំទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ឱ្យជនជាតិចិនោះបានហើយ ជនជាតិចិនមិនស្គាល់ឈ្មោះ និងឱ្យថ្លៃឈ្នួលចំនួន ១០០ដុល្លារ (មួយរយដុល្លារសហរដ្ឋអាមេរិច) ហើយរូបខ្ញុំនិងឈ្មោះ [redacted] ហៅ ដរ ចែកគ្នាក្នុងម្នាក់ ៥០ដុល្លារ (ហាសិបដុល្លារសហរដ្ឋអាមេរិច) ដោយរូបខ្ញុំបាទបានជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដរ ទៅទិញគ្រឿងញៀននៅក្នុង ក្លឹប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទៅដល់រូបខ្ញុំបាទជាអ្នកដើរចូលក្នុងក្លឹបទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ពីបុរសមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ជនជាតិខ្មែរ ក្នុងតម្លៃ ២០០ដុល្លារ(ពីររយដុល្លារសហរដ្ឋអាមេរិច) ពេលទិញរួចរូបខ្ញុំបាទបានយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ទៅហុច ឱ្យឈ្មោះ [redacted] ហៅ ដរ ហើយឈ្មោះ [redacted] ហៅ ដរ បានលាក់ទុកគ្រឿងញៀននោះ នៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ រួចរូបខ្ញុំបាទបានជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដរ ក្នុងគោលបំណងយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ស្ថិតនៅ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលរូបខ្ញុំបាទជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដរ មកដល់ចំណុចផ្លូវលេខ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏ស្រាប់តែជួបកម្លាំងសមត្ថកិច្ចកំពុងអនុវត្តត្រួតពិនិត្យជាតិអាកុល បានធ្វើការត្រួតពិនិត្យ ភ្លាមនោះសមត្ថកិច្ចបានរកឃើញ ម្សៅម៉ដ្ឋ ពណ៌ស ចំនួន០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន០១កញ្ចប់ម៉ាក (Porsche) ដែលឈ្មោះ [redacted] ហៅ ដរ បានលាក់ទុកនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ ខណៈនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនរូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ ដរ មកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក តែម្តង ។

បញ្ជាក់ ៖ កន្លងមករូបខ្ញុំបាទនិងឈ្មោះ [redacted] ហៅ ដរ ធ្លាប់បានទិញគ្រឿងញៀនទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ចំនួន០១លើកមកហើយ ដោយទទួលបានថ្លៃឈ្នួលចំនួន១០០ ដុល្លារ (មួយរយដុល្លារសហរដ្ឋអាមេរិច) ហើយពួកខ្ញុំចែកគ្នាក្នុង០១នាក់ ៥០ដុល្លារ (ហាសិបដុល្លារសហរដ្ឋអាមេរិច) ។

-រូបខ្ញុំបាទមិនដែលធ្លាប់ពន្ធនាគារ រឺមណ្ឌលកែប្រែទេ ។

-រូបខ្ញុំបាទមិនចេះប្រើប្រាស់ថ្នាំញៀនទេ ។

## IV -<u>**វត្ថុតាងគ្រឿងញៀនចាប់យក**</u>

-ម្សៅម៉ដ្ឋពណ៌សសង្ស័យថាមានតម្រុយជាគ្រឿងញៀនចំនួន០៤កញ្ចប់តូច ជាសារធាតុប្រភេទកេតតាមីនមានទម្ងន់១,៥៥ក្រាម (មួយកណ្តាក់សញ្ញាហាសិបប្រាំក្រាម) ។

1/6

...ក្រោមផ្ទុកលោកការហែលសង្ស័យថាមានតម្រុយជាគ្រឿងញៀនចំនួន០១កញ្ចប់ធំល្មម ជាសារធាតុប្រភេទអ៊ិចស្តាស៊ី ...ទម្ងន់១៤,៤៦ក្រាម (ដប់បួនក្បៀសសែសិបប្រាំមួយក្រាម) ។

1/31

V-**សំភារៈនិងមធ្យោបាយចាប់យក**

- ទូរស័ព្ទដៃចំនួន០១គ្រឿងម៉ាក IPHONE X ពណ៌ស ប្រើប្រាស់ស៊ីមលេខ 097 749 64 79 ។
- ម៉ូតូចំនួន០១គ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២១ ពាក់ស្លាកលេខ ភ្នំពេញ 1-IR 8608 ដែលមានលេខតួ និងលេខម៉ាស៊ីន 5602040 ។

VI-**ជូរម្រះយើងសន្និដ្ឋានថា៖** ជនសង្ស័យចំនួន០២នាក់ខាងលើៈ-១-ឈ្មោះ [redacted] ហៅ ដរ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម (ឃាត់ខ្លួនជាក់ស្តែង) និងទី២-ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួនជាក់ស្តែង) ពិតជាបានប្រព្រឹត្តបទល្មើស៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ យកទៅលក់ឲ្យបុរសពុំស្គាល់ឈ្មោះ អាយុប្រហែល២៥ឆ្នាំ ជនជាតិចិន (គេចខ្លួន) ប្រើប្រាស់តេឡេក្រាម TOM @TOM02050 នៅម្តុំសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពិតប្រាកដមែន ។ ចំណែកឯជនសង្ស័យពុំស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ជនជាតិខ្មែរ (គេចខ្លួន) ពិតជាបានប្រព្រឹត្តបទល្មើស៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** នៅចំណុចក្នុងក្លឹប TRUE FACE សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពិតប្រាកដមែន ។

VII-**ការសំណូមពរ៖** សូម ឯកឧត្តម ព្រះរាជអាជ្ញា មេត្តាទទួលយកសំណុំរឿងលេខ....០១១........ ជនសង្ស័យចំនួន០២នាក់ខាងលើ ឈ្មោះ [redacted] ហៅ ដរ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម (មានខ្លួន) និងឈ្មោះ [redacted] ហៅ វណ្ណា ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ (មានខ្លួន) ដើម្បីពិនិត្យ និងធ្វើការចោទប្រកាន់តាមផ្លូវច្បាប់ ចំណែកឯជនសង្ស័យពុំស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់គ្រឿងញៀន (គេចខ្លួន) និងជនសង្ស័យពុំស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ជនជាតិចិន (គេចខ្លួន) សូម **ឯកឧត្តម ព្រះរាជអាជ្ញា** មេត្តាចេញដីកាស្រាវជ្រាវរកសាវតាជាតិ ដើម្បីចាត់ការតាមផ្លូវច្បាប់ ។

សូម **ឯកឧត្តម ព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

លេខ:...៣៥៥.../៦៦

បានឃើញ និង បញ្ជូនមក

ឯកឧត្តម ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

មេត្តាជ្រាប និង ជួយចាត់ការតាមផ្លូវច្បាប់ ។

ថ្ងៃ សៅរ៍ ៧ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ , ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤

**ស្នងការរង**

**ទទួលផែនការងារប្រឆាំងគ្រឿងញៀន**

ឧត្តមសេនីយ៍ទោ [redacted]

**អធិការ**

វរសេនីយ៍ឯក. [redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

## <u>កំណត់ហេតុស្តាប់ចម្លើយ</u>

យោង ៖ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤
ថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ពុទ្ធស័ករាជ ពីរពាន់ប្រាំរយហុកសិបប្រាំពីរ
ត្រូវនឹងថ្ងៃទី ដប់ប្រាំបី ខែមីនា ឆ្នាំពីរពាន់ម្ភៃបួន វេលាម៉ោង ប្រាំបួន និង សាមសិប នាទី។

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក [redacted] ជាក្រឡាបញ្ជី។

មកបង្ហាញខ្លួននៅចំពោះមុខយើងជា ជនជាប់សង្ស័យដែលមានអត្តសញ្ញាណដូចខាងក្រោម៖

-នាមត្រកូល និងនាមខ្លួន [redacted] ហៅ ជរ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម សាសនាព្រះពុទ្ធ មុខរបរ កម្មករធ្វើប្រហិត ទីកន្លែងកំណើត ប្រទេសវៀតណាម មានទីលំនៅបច្ចុប្បន្នផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ឃាត់ខ្លួន)

យើងបានស្តាប់ឈ្មោះនេះ ហើយជននេះបានឆ្លើយប្រាប់យើងដូចខាងក្រោម ៖

-លោក ព្រះរាជអាជ្ញារង ប្រាប់សិទ្ធិបន្ថែម និងតាំងសួរសំណួរ ដល់ជនជាប់សង្ស័យ ។

ស/ឆ ៖ ចំពោះចម្លើយដែលខ្ញុំបានឆ្លើយនៅសមត្ថកិច្ច ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ខ្ញុំបាទសូមរក្សាទុកជាបានការដដែលពុំមានអ្វីកែប្រែឡើយ។

ស/ឆ ៖ កាលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០នាទី យប់រំលងអាធ្រាត្រ មានជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ឆ្នាំ ជនជាតិចិន បានទូរស័ព្ទមកខ្ញុំបាទឱ្យខ្ញុំបាទទិញគ្រឿងញៀន ចំនួន ០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ុង្វ ពណ៌កាហ្វេ ចំនួន ០១កញ្ចប់ ម៉ាក (Porsche) ក្នុងតម្លៃ ២០០$(ពីររយដុល្លារអាមេរិក) រួចខ្ញុំបាទបានទៅទិញថ្នាំញៀនជាមួយឈ្មោះ ថៃ វណ្ណា ដោយជិះម៉ូតូទីទិញនៅក្នុងក្លឹប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទិញបានហើយខ្ញុំបាទបានយកទៅឱ្យបុរសមិនស្គាល់ឈ្មោះ ជនជាតិចិន ភេទប្រុស ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលជិះដល់ចំណុចផ្លូវ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក៏ស្រាប់តែជួបនិងកម្លាំងសមត្ថកិច្ចកំពុងត្រួតពិនិត្យជាតិអាកុល បានធ្វើការពិនិត្យពួកខ្ញុំរកឃើញថ្នាំញៀនចំនួន ០៤កញ្ចប់ម៉ាក (K) និងម្សៅម៉ុង្វ ពណ៌កាហ្វេ ចំនួន ០១កញ្ចប់ ម៉ាក (Porsche) ដែលខ្ញុំបាទបានលាក់ទុកក្នុងហោប៉ៅ រួចបាននាំខ្លួនពួកខ្ញុំមកអធិការដ្ឋាននគរបាលខណ្ឌទួលគោកតែម្តង។

ស/ឆ ៖ កន្លងមកពេលយកថ្នាំញៀនទៅឱ្យជនជាតិចិន ភេទប្រុស អាយុប្រហែល ២៥ឆ្នាំ ចំនួន ០១លើកមកហើយ រួចបានប្រាក់ឈ្នួលចំនួន ១០០$ (មួយរយដុល្លារអាមេរិក) ហើយពួកខ្ញុំចែកគ្នាជាមួយឈ្មោះ [redacted] ម្នាក់ ៥០$(ហាសិបដុល្លារអាមេរិក) ។

ស/ឆ ៖ ខ្ញុំបាទសូមសំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្ញុំបាទផង។

បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង ប្រាំ នាទី នៅថ្ងៃខែឆ្នាំដដែល។

ឈប់សួរបានអានឱ្យស្តាប់ សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយៗ សុខចិត្តចុះហត្ថលេខា ឬ ផ្តិតស្រាមមេដៃជាមួយយើង។

| **អ្នកឆ្លើយ** | **ក្រឡាបញ្ជី** | **តំណាងអយ្យការ** |
|---|---|---|
| | [redacted] | [redacted] |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
***

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
លេខ: ១៧២៧អ.យ.ល

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤

-បានឃើញ របាយការណ៍លេខ ០២១ រ.ប.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថាមានតម្រុយសន្និតបានថា:

១-នាមត្រកូល និងនាមខ្លួន [redacted] ហៅ ដរ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម សាសនាព្រះពុទ្ធ មុខរបរ កម្មករធ្វើប្រហិត ទីកន្លែងកំណើត ប្រទេសវៀតណាម មានទីលំនៅបច្ចុប្បន្នផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ឃាត់ខ្លួន)

២-នាមត្រកូល និងនាមខ្លួន [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករធ្វើប្រហិត ទីកន្លែងកំណើត ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ឃាត់ខ្លួន)

៣-បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOMO2050 ជនជាតិចិន នៅម្តុំសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ (គេចខ្លួន)

៤-អញ្ញាត្តជន ។(គេចខ្លួន)

បានប្រព្រឹត្តអំពើដូចតទៅ៖

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០១ និង ១០នាទី យប់រំលងអាធ្រាត្រ កម្លាំងចម្រុះអនុវត្តគ្រួតពិនិត្យជាអាកុល នៃអធិការដ្ឋានខណ្ឌទួលគោកបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ ជាក់ស្ដែងនៅចំណុចបណ្ដោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានប្រទះជនសង្ស័យឈ្មោះ [redacted] ហៅ ដរ ភេទប្រុស និងឈ្មោះ [redacted] ហៅ វណ្ណា ភេទប្រុស បានជិះម៉ូតូឌុបឡា ០១គ្រឿង ម៉ាក HONDA DREAM ពាក់ស្លាកលេខ ភ្នំពេញ 1-IR 8608 ដោយមានការសង្ស័យក៏បានឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ ឆែកឆេរពិនិត្យកេឃើញថ្នាំជក់ចំនួន ០៤កញ្ចប់ម្សៅម៉ង្គម៉ាក (K) និងម្សៅម៉ង្គ ពណ៌កាហ្វេ ចំនួន ០១កញ្ចប់ ម៉ាក (Porsche) នៅក្នុងហោប៉ៅខាងក្រោយផ្នែកខាងស្ដាំរបស់ជនសង្ស័យឈ្មោះ [redacted] ហៅ ដរ ភេទប្រុស ភ្លាមនោះសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ ជាក់ស្ដែង និងដកហូតវត្ថុតាងខាងលើ បញ្ជូនមកកាន់អធិការដ្ឋាននគរបាលខណ្ឌទួលគោកតែម្ដង។

អំពើដែលជាបទល្មើស: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

អនុលោមតាមបញ្ញត្តិ មាត្រា៤៤និងមាត្រា១២៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**សម្រេច**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ស្នើសុំ ៖

១.ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ៖

ក-ឈ្មោះ [redacted] ហៅ ដរ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម ។(ឃាត់ខ្លួន)

ខ-ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ។ (ឃាត់ខ្លួន)

គ- ជនជាតិចិន ប្រើប្រាស់តេឡេក្រាម TOM@TOMO2050។ (គេចខ្លួន)

ឃ-អញ្ញាត្តជន ។(គេចខ្លួន)

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ [redacted] ហៅ ដរ ភេទប្រុស ,ឈ្មោះ [redacted] ភេទប្រុស , ជនជាតិចិន និងអញ្ញាត្តជន ដើម្បីបង្ការ ឬបញ្ឈប់បទល្មើសកុំអោយកើត ឡើងសារជាថ្មី និងធានាក្សា ជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ។

ថ្ងៃចន្ទ ៩កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ត្រីស៊ើបសួរ "ឈ"

សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨

ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤

សំណុំរឿងស៊ើបសួរលេខ ១២៥៦

ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤

# កំណត់ហេតុស្តីពី
# ការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣,១៤៤,២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃបួន ខែមីនា ថ្ងៃទីដប់ប្រាំបួន វេលាម៉ោងបីរសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមស៊ើបសួរ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក.................................................ជាអ្នកបកប្រែ។

បុគ្គលនៅចំពោះមុខយើងបានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជាតិនិតជន។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ជននេះ៖ ☐ ចេះនិយាយភាសាខ្មែរ ☐ ចេះអានអក្សរខ្មែរ ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ[1]៖ ☐ មិនចេះនិយាយភាសខ្មែរ ☐ មិនចេះអានអក្សរខ្មែរ ☐ មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងអត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ឈ្មោះនេះឱ្យដឹងយ៉ាង ច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ឈ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ ដែលនាំឱ្យមានការបង្ហាញខ្លួនជននេះនៅចំពោះមុខយើង ព្រមទាំងប្រាប់ជននេះឱ្យដឹងអំពីបទចោទប្រកាន់ចំពោះរឿងរ៉ាវដូចខាងក្រោម[2]។

ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងដែលយើងទើបនឹងរៀបរាប់ឱ្យជននេះដឹងយ៉ាងច្បាស់។

---

[1] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

[2] រឿងហេតុដែលចោទប្រកាន់ និងបទល្មើស

☐ លោក លោកស្រី.................................មេធាវី[3] នៃជនត្រូវចោទដែលត្រូវបានកោះ ហៅនៅថ្ងៃទី ......................................................ហើយដើម្បីឱ្យលោក-លោកស្រីមេធាវីអាចត្រៀមរៀបចំការពារក្ដីខ្លួនបាន។

☐ យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើស ពឹងពាក់ដោយខ្លួនឯង ឬអាចសុំឱ្យគេចាត់តាំងមេធាវីណាម្នាក់ឱ្យរូបគាត់។

☐ យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួន ឯងទេ មេធាវីមួយរូបនឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

ជននេះបានប្រកាសថា:

☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្ដល់ចម្លើយក៏បាន ឬ អាចធ្វើសេចក្ដីប្រកាសផ្សេងៗ ឬអាចឱ្យយើងសួរចម្លើយក៏បាន។

ជននេះបានប្រកាសប្រាប់ថា: ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាននៅពេលនេះដោយពុំចាំបាច់មានមេធាវីការពារសិទ្ធិឱ្យខ្ញុំបាទទេ។

លោក.លោកស្រីមេធាវី.................................................បានផ្ដល់សេចក្ដីកត់សម្គាល់ការពារថា:

..........................................................................................................................................

...............................................................។

☐ យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឱ្យស្ថិតនៅក្រោមការពិនិត្យ។

☐ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឱ្យដឹង។

☐ ចំពោះអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពី ឈ្មោះនៃ បទល្មើស:

ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការសុំឱ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើ ពាក្យប្ដឹងសុំមោឃភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្ដឹងឧទ្ធរណ៍តាម បញ្ញត្តិមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់ មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមានសំណើសុំ យើងនឹងចាត់តាំងមេធាវីមួយរូបជូន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់ មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឱ្យចាត់តាំងមេធាវីឱ្យ)។

ជនត្រូវចោទបានប្រកាសប្រាប់ថា:

☐ ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង

---

[3] ករណីមានមេធាវី

☐ ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឱ្យបិទការស៊ើបសួរបាននៅក្រោយពេល ផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចដាក់គាត់ឱ្យនៅក្រោមការ ត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់ឱ្យគាត់ដឹងអំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួន (ឱ្យនៅក្រៅឃុំ)

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា:

-គាត់ត្រូវប្រកាសប្រាប់ពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋាន របស់តតិយជនម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឱ្យគាត់ ប្រសិនបើគាត់អាចផ្ដល់ឱ្យ ភ្ជាមនូវការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់តតិយជននោះ

-អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ............................................

...................... ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោម:

អាសយដ្ឋាននេះជា ☐ អាសយដ្ឋានផ្ទាល់ខ្លួន

☐ អាសយដ្ឋានរបស់...................................................

☐ យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមថា:

-រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋានដែល បានប្រកាសប្រាប់ខាងលើដោយការប្រកាសជាថ្មី ឬ ដោយលិខិតអនុសិដ្ឋ។

-គ្រប់ការជូនដំណឹង ឬ ការឱ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋានដែលបាន ប្រកាសប្រាប់ ចុងក្រោយបង្អស់ ត្រូវចាត់ទុកថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ។

☐ យើងបានឱ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ ជាមួយយើង និងក្រឡាបញ្ជី។

☐ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី និងអ្នកបកប្រែ។[៤]

**ជនត្រូវចោទ** **មេធាវី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

[redacted] [redacted] [redacted]

[៤] គ្រប់ទំព័រត្រូវអនុវត្តតាមមាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ "ឈ"
សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤
សំណុំរឿងស៊ើបសួរលេខ ១២៥៦
ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤

## កំណត់ហេតុស្តីពី
## ការពិភាក្សាដេញដោលចំពោះមុខ[5]

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃបួន ខែមីនា ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោងបី និងសែសិបប្រាំនាទីរសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមស៊ើបសួរ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក............................................ជាអ្នកបកប្រែ។

ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២៤។

បានបង្ហាញខ្លួននៅមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជានីតិជន។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

☐ ជននេះប្រកាសប្រាប់ថា ចេះអាន និងចេះសរសេរអក្សរខ្មែរ

☐ ជននេះប្រកាសប្រាប់ថា មិនចេះអាន និងមិនចេះសរសេរអក្សរខ្មែរ

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤។

☐ ដោយមានវត្តមានលោក លោកស្រីមេធាវី............................ ដែលជនត្រូវចោទបានជ្រើសរើស ពឹងពាក់ដោយខ្លួនឯង ឬ ដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានមក បង្ហាញខ្លួននៅ

[5] កំណត់ហេតុនេះត្រូវធ្វើឡើងបន្តពីកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង (នៅក្នុងថ្ងៃតែមួយ)

ក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះ មើលសំណុំរឿង និងបានធ្វើទំនាក់ទំនង ដោយសេរីជាមួយនឹងជនត្រូវចោទនៅពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខយើង។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន។

☐ យើងបានប្រាប់ថាជនត្រូវចោទអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន។

☐ យើងក៏បញ្ជាក់ប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃនេះ។

☐ ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា ជនត្រូវចោទ មានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬពីមេធាវី តាមការចាត់តាំង។

ជនត្រូវចោទបានប្រកាសប្រាប់ថា:

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

☐ ខ្ញុំចង់បានជំនួយពីមេធាវី

☐ លោក លោកស្រីមេធាវី.................................ត្រូវបានជូនដំណឹងដោយ........................
...........អាចពិគ្រោះមើលសំណុំរឿងដែលទុកឱ្យគាត់ពិនិត្យ និងអាចសន្ទនា ដោយសេរីជាមួយកូនក្ដីរបស់គាត់។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន:

☐ ត្រូវបានធ្វើ

☐ ត្រូវបានលើកទៅថ្ងៃទី..............ខែ............ឆ្នាំ.............តាមសំណូមពររបស់.......................
.......................................................................................។

តំណាងអយ្យការបានបង្ហាញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម: ស្នើសុំឱ្យចៅក្រមស៊ើបសួរ ដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

ជនត្រូវចោទបានបង្ហាញសេចក្ដីសង្កេតរបស់ខ្លួនដូចខាងក្រោម: ខ្ញុំបាទសុំឱ្យតុលាការកុំឃុំខ្លួនខ្ញុំបាទអី។

លោក មេធាវី ...................... បានបង្ហាញសេចក្ដីសន្និដ្ឋានការពារកូនក្ដីរបស់ ខ្លួនដូចខាងក្រោម:
..........................................................................................................។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងនឹងសម្រេចចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួននៅថ្ងៃនេះ ។

☐ យើងបានឱ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្ដិតម្រាមដៃលើកំណត់ហេតុនេះ។

☐ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី។

☐ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី និងអ្នកបកប្រែ។[6]

**ជនត្រូវចោទ មេធាវី តំណាងអយ្យការ ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

[6] គ្រប់ចំណុចត្រូវអនុវត្តតាមមាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**មន្ទីរស៊ើបសួរ "ល"**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤
សំណុំរឿងស៊ើបសួរលេខ ១២៥៦
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

## កំណត់ហេតុស្តីពី
## <u>ការសួរចម្លើយជនត្រូវចោទ</u>

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃបួន ខែមីនា ថ្ងៃទីដប់ប្រាំបួន វេលាម៉ោងបីរសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមស៊ើបសួរ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក..............................................ជាអ្នកបកប្រែ។

បានបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម:

ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជាទីតិជន។

ជននេះ៖ ☐ ចេះនិយាយភាសាខ្មែរ ☐ ចេះអានអក្សរខ្មែរ ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ[7]៖ ☐ មិនចេះនិយាយភាសាខ្មែរ ☐មិនចេះអានអក្សរខ្មែរ ☐ មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងអត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាងច្បាស់អំពី រឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤។

យើងបានសួរ និងស្តាប់ចម្លើយឈ្មោះនេះដូចខាងក្រោមថា៖

ចៅក្រមប្រាប់សិទ្ធិ និងបទចោទប្រកាន់ដល់ជនត្រូវចោទ។

ស.អ៖ ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបានដោយមិនចាំបាច់មានមេធាវីការពារសិទ្ធិឱ្យខ្ញុំបាទទេ។

ស.អ៖ ខ្ញុំបាទសុំរក្សាចម្លើយដែលខ្ញុំបាទបានឆ្លើយនៅចំពោះសមត្ថកិច្ច និងនៅដំណាក់កាលអយ្យការទុកជាបានការដដែល ព្រោះចម្លើយនោះជាចម្លើយដែលខ្ញុំបាទឆ្លើយដោយខ្លួនឯង ដោយពុំមានអ្វីកែប្រែ ឬបន្ថែមនោះទេ។

---

[7] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

ស.ឆ៖ សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែលម៉ោង ១២ និង ១០នាទី នៅចំណុចខណ្ឌទួលគោក រាជធានីភ្នំពេញ(មិនស្គាល់ទីកន្លែងច្បាស់) ពេលខ្ញុំបាទកំពុងជិះម៉ូតូម៉ាក ហុងដាដ្រីម ឆ្នាំ២០២១ ជាកម្មសិទ្ធិរបស់ពូឈ្មោះ [redacted] ជាមួយឈ្មោះ [redacted] ក្នុងគោលបំណងយកថ្នាំញៀន(មិនស្គាល់ម៉ាក)ទៅឱ្យម៉ូយនៅខុនដូរមិនស្គាល់ឈ្មោះម្តុំសែនសុខ ចំនួន៤កញ្ចប់ ប៉ុន្តែខ្ញុំបាទមិនដឹងតម្លៃប៉ុន្មាន ហើយក៏មិនស្គាល់ម៉ាកដែរ ព្រោះខ្ញុំបាទជាអ្នកជួយយកឱ្យគេ។ ចំពោះអ្នកដែលប្រើខ្ញុំបាទយកថ្នាំញៀនទៅឱ្យគេនោះខ្ញុំបាទមិនស្គាល់ឈ្មោះទេ ដោយគាត់មកក្នុងភូមិខ្ញុំបាទយូរៗម្តង ហើយចំពោះថ្លៃឈ្នួលដែលខ្ញុំជួយយកថ្នាំញៀនឱ្យគេនេះ គឺបានចំនួន៣ម៉ឺនរៀលចែកគ្នាពីរនាក់ឈ្មោះ [redacted] ក្នុងម្នាក់បានប្រាក់ចំនួន ១៥០០០រៀល ដោយលុយថ្លៃឈ្នួលនេះខ្ញុំបាទបានទទួលរួចហើយ។

ស.ឆ៖ អ្នកដែលប្រើខ្ញុំបាទឱ្យយកថ្នាំញៀនទៅឱ្យគេ គឺខ្ញុំបាទមិនស្គាល់ឈ្មោះ ហើយក៏មិនស្គាល់ទីលំនៅដែរ គ្រាន់តែមានភិនភាគ ជាមនុស្សប្រុស ខ្ពស់ ស្គម សម្បុរស្រអែម ជនជាតិខ្មែរ អាយុប្រហែលជាង២០ឆ្នាំ។

ស.ឆ៖ ខ្ញុំបាទធ្លាប់យកថ្នាំញៀនទៅឱ្យគេតាមការប្រើរបស់មនុស្សប្រុសខាងលើនេះបានចំនួន២ដងហើយ ដោយលើកទី១ឱ្យខ្ញុំបាទបានប្រាក់ឈ្នួល៤ម៉ឺនរៀល ហើយចែកជាមួយឈ្មោះ [redacted] ម្នាក់បាន២ម៉ឺនរៀល ចំណែកលើកទី២ គឺថ្ងៃដែលសមត្ថកិច្ចចាប់បាននេះឯង។

ស.ឆ៖ ក្រៅពីមនុស្សប្រុសខាងលើប្រើខ្ញុំបាទឱ្យយកថ្នាំញៀនទៅឱ្យគេ ខ្ញុំបាទមិនដែលជួយយកឱ្យអ្នកណានោះទេ ហើយខ្ញុំបាទក៏មិនធ្លាប់ទិញលក់ដូរយកលុយខ្លួនឯងនោះដែរ ម្យ៉ាងទៀតខ្ញុំបាទក៏មិនចេះប្រើប្រាស់ថ្នាំញៀនដែរ។

ស.ឆ៖ នៅពេលខ្ញុំបាទយកថ្នាំញៀនទៅឱ្យគេ ក្រៅពីទៅជាមួយឈ្មោះ [redacted] ខ្ញុំបាទមិនដែលទៅជាមួយអ្នកផ្សេងនោះទេ ហើយឈ្មោះ [redacted] ក៏បានដឹងដែរថាយកថ្នាំញៀនទៅឱ្យគេ។

ស.ឆ៖ ខ្ញុំបាទសូមបញ្ជាក់ថា ខ្ញុំបាទមិនដែលមានទំនាក់ទំនងប្រើប្រាស់តេឡេក្រាមជាមួយគណនីឈ្មោះ TOM@TOM2050 ដែលជាជនជាតិចិននោះទេ។

ស.ឆ៖ ពេលដែលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទនិងឈ្មោះ [redacted] គឺថ្នាំញៀនចំនួន៤កញ្ចប់នៅលើខ្លួនរបស់ឈ្មោះ [redacted]

ស.ឆ៖ ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទដកហូតបានម៉ូតូចំនួន១គ្រឿងម៉ាក ហុងដាដ្រីម ពណ៌ខ្មៅ ផលិតឆ្នាំ ២០២១ មិនចាំផ្លាកលេខ និងថ្នាំញៀនចំនួន៤កញ្ចប់ ក្រៅពីនោះមិនមានដកហូតអ្វីផ្សេងទៀតទេ។

ស.ឆ៖ ខ្ញុំបាទសំណូមពរសុំឱ្យតុលាការជួយបន្ធូបន្ថយទោសឱ្យខ្ញុំបាទផង។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង បី និងសែសិបនាទីរសៀល នាថ្ងៃខែឆ្នាំដូចខាងលើ។

☐ យើងបានឱ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូល ក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា លើកំណត់ហេតុនេះ។

☐ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ជាមួយយើង និងក្រឡាបញ្ជី។

☐ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និង បានចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី និងអ្នកបកប្រែ។ ៦

ជនត្រូវចោទ | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ

[redacted] | [redacted] | [redacted]

1/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**មន្ទីរស៊ើបសួរ "ល"**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤
សំណុំរឿងស៊ើបសួរលេខ ១២៥៦
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

## កំណត់ហេតុស្តីពី
## ការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣,១៤៤,២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃបួន ខែមីនា ថ្ងៃទីដប់ប្រាំបួន វេលាម៉ោងបី និងសែសិបប្អូននាទីរសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមស៊ើបសួរ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក..............................................ជាអ្នកបកប្រែ។

បុគ្គលនៅចំពោះមុខយើងបានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ [redacted] ហៅ ផវ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជានីតិជន។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ជននេះ៖ ☐ ចេះនិយាយភាសាខ្មែរ ☐ ចេះអានអក្សរខ្មែរ ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ[1]៖ ☐ មិនចេះនិយាយភាសខ្មែរ ☐ មិនចេះអានអក្សរខ្មែរ ☐ មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងអត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ឈ្មោះនេះឱ្យដឹងយ៉ាង ច្បាស់អំពីរឿងក្តីដែលព្រះរាជអាជ្ញាប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ ដែលនាំឱ្យមានការបង្ហាញខ្លួនជននេះនៅចំពោះមុខយើង ព្រមទាំងប្រាប់ជននេះឱ្យដឹងអំពីបទចោទប្រកាន់ចំពោះរឿងក្តីដូចខាងក្រោម[2]។

ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

---

[1] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

[2] រឿងហេតុដែលចោទប្រកាន់ និងបទល្មើស

យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងដែលយើងទើបនឹងរៀបរាប់ឱ្យជននេះដឹងយ៉ាងច្បាស់។

☐លោក លោកស្រី....................................មេធាវី[3] នៃជនត្រូវចោទដែលត្រូវបានកោះ ហៅនៅថ្ងៃទី ..................................................ហើយដើម្បីឱ្យលោក-លោកស្រីមេធាវីអាចត្រៀមរៀបចំការពារកូនក្ដីខ្លួនបាន។

☐ យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើស ពឹងពាក់ដោយខ្លួនឯង ឬអាចសុំឱ្យគេចាត់តាំងមេធាវីណាម្នាក់ឱ្យរូបគាត់។

☐យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួន ឯងទេ មេធាវីមួយរូបនឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

ជននេះបានប្រកាសថា:

☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្ដល់ចម្លើយក៏បាន ឬ អាចធ្វើសេចក្ដីប្រកាសផ្សេងៗ ឬអាចឱ្យយើងសួរចម្លើយក៏បាន។

ជននេះបានប្រកាសប្រាប់ថា: ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាននៅពេលនេះដោយពុំចាំបាច់មានមេធាវីការពារសិទ្ធិឱ្យខ្ញុំបាទទេ។

លោក.លោកស្រីមេធាវី..................................................បានផ្ដល់សេចក្ដីកត់សម្គាល់ការពារថា:

..................................................................................................................................................

....................................................................................។

☐ យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឱ្យស្ថិតនៅក្រោមការពិនិត្យ។

☐ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឱ្យដឹង។

☐ ចំពោះអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពី ឈ្មោះនៃ បទល្មើស:

ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការសុំឱ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើ ពាក្យប្ដឹងសុំមោឃភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្ដឹងឧទ្ធរណ៍តាម បញ្ញត្តិមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់ មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមានសំណើសុំ យើងនឹងចាត់តាំងមេធាវីមួយរូបជូន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់ មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឱ្យចាត់តាំងមេធាវីឱ្យ)។

[3] ករណីមានមេធាវី

ជនត្រូវចោទបានប្រកាសប្រាប់ថា:

☐ ខ្ញុំជ្រើសរើសពីងពាក់មេធាវីដោយខ្លួនឯង

☐ ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឱ្យបិទការស៊ើបសួរបាននៅក្រោយពេល ផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចដាក់គាត់ឱ្យនៅក្រោមការ ត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់ឱ្យគាត់នឹងអំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួន (ឱ្យនៅក្រៅឃុំ)

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា:

-គាត់ត្រូវប្រកាសប្រាប់ពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋាន របស់តតិយជនម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឱ្យគាត់ ប្រសិនបើគាត់អាចផ្ដល់ឱ្យ ភ្ជាមនូវការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់តតិយជននោះ

-អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ............................................

...................... ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោម:

អាសយដ្ឋាននេះជា ☐ អាសយដ្ឋានផ្ទាល់ខ្លួន

☐ អាសយដ្ឋានរបស់...................................................

☐ យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមថា:

-រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់យើងគ្រប់ការផ្លាស់ប្ដូរអាសយដ្ឋានដែល បានប្រកាសប្រាប់ខាងលើដោយការប្រកាសជាថ្មី ឬ ដោយលិខិតអនុសិដ្ឋ។

-គ្រប់ការជូនដំណឹង ឬ ការឱ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋានដែលបាន ប្រកាសប្រាប់ ចុងក្រោយបង្អស់ ត្រូវចាត់ទុកថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ។

☐ យើងបានឱ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្ដិតស្រាមដៃ ជាមួយយើង និងក្រឡាបញ្ជី។

☐ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្ដិតស្រាមដៃជាមួយយើង និងក្រឡាបញ្ជី និងអ្នកបកប្រែ។[4]

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
| --- | --- | --- | --- |
| [redacted] | | [redacted] | [redacted] |

[4] គ្រប់ទំព័រត្រូវអនុវត្តតាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

5

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ "ល"
សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤
សំណុំរឿងស៊ើបសួរលេខ ១២៥៦
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

## កំណត់ហេតុស្តីពី
## ការពិភាក្សាដេញដោលចំពោះមុខ[5]

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃបួន ខែមីនា ថ្ងៃទីដប់ប្រាំបួន វេលាម៉ោងបួន និងដប់ប្រាំនាទីរសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមស៊ើបសួរ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក.................................................ជាអ្នកបកប្រែ។

ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២៤។

បានបង្ហាញខ្លួននៅមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ [redacted] ហៅ ផវ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិវៀតណាម មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជាតិតិជន។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

☐ ជននេះប្រកាសប្រាប់ថា ចេះអាន និងចេះសរសេរអក្សរខ្មែរ

☐ ជននេះប្រកាសប្រាប់ថា មិនចេះអាន និងមិនចេះសរសេរអក្សរខ្មែរ

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤។

☐ ដោយមានវត្តមានលោក លោកស្រីមេធាវី.......................... ដែលជនត្រូវចោទបានជ្រើសរើស ពឹងពាក់ដោយខ្លួនឯង ឬ ដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានមក បង្ហាញខ្លួននៅ

[5] កំណត់ហេតុនេះត្រូវធ្វើឡើងបន្តពីកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង (នៅក្នុងថ្ងៃតែមួយ)

ក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះ មើលសំណុំរឿង និងបានធ្វើទំនាក់ទំនង ដោយសេរីជាមួយនឹងជនត្រូវចោទនៅពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខយើង។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន។

☐ យើងបានប្រាប់ថាជនត្រូវចោទអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន។

☐ យើងក៏បញ្ជាក់ប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃនេះ។

☐ ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា ជនត្រូវចោទ មានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬពីមេធាវី តាមការចាត់តាំង។

ជនត្រូវចោទបានប្រកាសប្រាប់ថា:

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

☐ ខ្ញុំចង់បានជំនួយពីមេធាវី

☐ លោក លោកស្រីមេធាវី.......................................ត្រូវបានជូនដំណឹងដោយ...........................
............អាចពិគ្រោះមើលសំណុំរឿងដែលទុកឱ្យគាត់ពិនិត្យ និងអាចសន្ទនា ដោយសេរីជាមួយកូនក្ដីរបស់គាត់។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន:

☐ ត្រូវបានធ្វើ

☐ ត្រូវបានលើកទៅថ្ងៃទី...............ខែ.............ឆ្នាំ.............តាមសំណូមពររបស់........................
...........................................................................................។

តំណាងអយ្យការបានបង្ហាញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម: ស្នើសុំឱ្យចៅក្រមស៊ើបសួរ ដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

ជនត្រូវចោទបានបង្ហាញសេចក្ដីសង្កេតរបស់ខ្លួនដូចខាងក្រោម: ខ្ញុំបាទសុំឱ្យតុលាការកុំឃុំខ្លួនខ្ញុំបាទអី។

លោក មេធាវី ....................... បានបង្ហាញសេចក្ដីសន្និដ្ឋានការពារកូនក្ដីរបស់ ខ្លួនដូចខាងក្រោម:
..................................................................................................................។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងនឹងសម្រេចចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួននៅថ្ងៃនេះ ។

☐ យើងបានឱ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្ដិតម្រាមដៃលើកំណត់ហេតុនេះ។

☐ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី។

☐ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី និងអ្នកបកប្រែ។[6]

**ជនត្រូវចោទ** **មេធាវី** **តំណាងអយ្យការ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

[redacted] [redacted] [redacted]

៦ គ្រប់ទំព័រត្រូវអនុវត្តតាមមាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ "ល"
លេខ ២១៤១..., "ល" ដ.ក.ស

# ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី

-បានឃើញ មាត្រា ២០៦ មាត្រា ២១៩ មាត្រា ២២០ មាត្រា ២២១ និងមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១២៥៦ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹង:

-នាមត្រកូល និងនាមខ្លួន [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជាទីតិជន។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង

-បានឃើញ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ និងការកត់សម្គាល់របស់ភាគី

## I-ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១-នៅក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ត្រូវចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជាបទល្មើសមជ្ឈិម។

២-ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

សង្ខេបអង្គហេតុនៃរឿង៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០១ និង ១០នាទី យប់រំលងអាធ្រាត្រ កម្លាំងចម្រុះអនុវត្តត្រួតពិនិត្យជាអាកុល នៃអធិការដ្ឋានខណ្ឌទួលគោកបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ ជាក់ស្ដែងនៅចំណុចបណ្ដោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានប្រទះជនសង្ស័យឈ្មោះ [redacted] ហៅ ដរ ភេទប្រុស និងឈ្មោះ [redacted] ហៅ វណ្ណា ភេទប្រុស បានជិះម៉ូតូឌុបគ្នា ០១គ្រឿង ម៉ាក HONDA DREAM ពាក់ស្លាកលេខ ភ្នំពេញ 1IR-8608 ដោយមានការសង្ស័យក៏បានឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ តែការពិនិត្យរក

[illegible] (K) [illegible] (Porsche) [illegible]
ខាងក្រោយផ្នែកខាងស្តាំរបស់ជនសង្ស័យឈ្មោះ [redacted] ហៅ [illegible] ភេទប្រុស ភ្លាមនោះសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ ដាក់ស្លែក និងដកហូតវត្ថុតាងខាងលើ បញ្ជូនមកកាន់អធិការដ្ឋាន នគរបាលខណ្ឌទួលគោកតែម្តង។

៣-តំណាងអយ្យការបានស្នើសុំឱ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ដោយហេតុថាដើម្បី៖

៣.១-បញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។

៣.២-ធានារក្សាជនត្រូវចោទទុកជូនតុលាការតាមនីតិវិធី។

៤-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ បានបង្ហាញសេចក្តីសង្ខេបរបស់ខ្លួនថា៖ ស្នើសុំទៅចៅក្រមស៊ើបសួរមេត្តាឱ្យខ្ញុំបាទត្រឡប់ទៅផ្ទះវិញ។

## II-**សំអាងហេតុនៃសេចក្តីសម្រេច**

៥-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ត្រូវចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ០១ (មួយ) ឆ្នាំ (មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦-ការឃុំខ្លួនជនត្រូវចោទចាំបាច់គឺ៖

៦.១-ដើម្បីបញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី បើទុកជនត្រូវចោទឱ្យនៅក្រៅឃុំ ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសសារជាថ្មី។

៦.២-ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត បើមិនឃុំខ្លួនជនត្រូវចោទ ជនត្រូវចោទអាចនឹងផ្តល់ព័ត៌មានដល់បក្ខពួកផ្សេងទៀតដែលនៅខាងក្រៅ និងមិនទាន់ត្រូវបានចាត់ការតាមនីតិវិធី។

៦.៣-ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ដោយហេតុថា បើទុកជនត្រូវចោទឱ្យនៅក្រៅឃុំ ជនត្រូវចោទអាចនឹងរត់គេចខ្លួន។

៧-ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានលក្ខណៈតឹងរឹង និងមានប្រសិទ្ធិភាពអាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយចុងក្រោយតែមួយគត់ដើម្បីសម្រេចបាននូវគោលដៅខាងលើ។

**<u>ហេតុដូច្នេះសម្រេច</u>**

-ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ជាបណ្តោះអាសន្នរយៈពេលអតិបរមា ០៤ (បួន) ខែ។

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី** — **ចៅក្រមស៊ើបសួរ**

[redacted] — [redacted]

ជាន់ទី៣ បន្ទប់ "ល"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ "ល"

លេខ ២៧២៤ "ល" ដ.ឃ.ដ

## ដីកាបង្គាប់ឱ្យឃុំខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា២០៦, ២១៩, ២២០, ២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១២៥៦ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹង:

-នាមត្រកូល និងនាមខ្លួន [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជាតិជន។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៧១១១.. "ល" ដ.ព.ស ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤។

### បង្គាប់

១-ឱ្យភ្នាក់ងារមានសមត្ថកិច្ច នៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ទៅ **ពន្ធនាគាររាជធានីភ្នំពេញ** (PJ) ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់។

២-ឱ្យ **ប្រធានពន្ធនាគាររាជធានីភ្នំពេញ** (PJ) ទទួល និងឃុំខ្លួន ជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣-ឱ្យគ្រប់ភ្នាក់ងារ នៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៤

ចៅក្រមស៊ើបសួរ

[redacted]

19.03.24

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

[redacted]
បន្ទប់ "ល" ជាន់ទី៣

សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ "ល"
លេខ: ៤២០..... "ល" ព្រ.ទ

**លិខិតជូនដំណឹង ឬ ជូនព័ត៌មាន[១]**
**ដល់តំណាងអយ្យការ ស្តីពីការបិទការស៊ើបសួរ**

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម០៨០៧ /០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤។

សូមជម្រាបមកលោក[២] ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ។

ត្បិត[៣]សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ ដែលមានជនត្រូវចោទ៖

១.ឈ្មោះ [redacted] ហៅ ដរ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិវៀតណាម

២.ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ ឆ្នាំ ជនជាតិខ្មែរ

ដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវ ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

នោះយើងបានសម្រេច[៤] បិទការស៊ើបសួរ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤
**ចៅក្រមស៊ើបសួរ**

[redacted]

**យោបល់តំណាងអយ្យការ**

.................................................................................

.................................................................................

រាជធានីភ្នំពេញ, ថ្ងៃទី....១០.... ខែ.....៦..... ឆ្នាំ២០២៤
**តំណាងអយ្យការ**

[redacted]
ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

[redacted]
បន្ទប់ "ល" ជាន់ទី៣

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ "ល"

លេខៈ..៤២៩៨......"ល"ព្រ.ម

# ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦៨ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២២៨ អ.យ.ណ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១២៥៦ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ដែលទាក់ទងនឹង៖

## ជនត្រូវចោទ

១.ឈ្មោះ [redacted] ហៅ ផវ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិវៀតណាម មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើតនៅ ប្រទេសវៀតណាម មានទីលំនៅបច្ចុប្បន្នផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

២.ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករធ្វើប្រហិត ទីកន្លែងកំណើត ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្នផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

ដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវ ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ឬផ្តល់យោបល់ទៅតាមនីតិវិធី។

ថ្ងៃ.[illegible]...[illegible]...ខែជេស្ឋ ឆ្នាំរោង ព.ស ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី.[illegible] ខែមិថុនា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវ
ក្រឡាបញ្ជី

[redacted]

ចៅក្រមស៊ើបសួរ

[redacted]

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
លេខ...3116...........អ.យ.ល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>**ដីកាសន្និដ្ឋានស្ថាពរ**</u>

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: **១៧៦៨** ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤
-បានឃើញសំណុំរឿងស៊ើបសួរលេខ: **១២៥៦** ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤
-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១២២៨ អ.យ.ល** ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤
-បានឃើញលិខិតជូនព័ត៌មានបិទការស៊ើបសួរលេខ: **៤២០ "ល" ព្រ.១** ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤
-បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យលេខ: **៤២៩ "ល" ព្រ.១** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤

**ក្រោយពីបានពិនិត្យឯកសារខាងលើឃើញថា:**

១-នាមត្រកូល និងនាមខ្លួន [redacted] <u>ហៅ</u> **ដរ** ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិវៀតណាម សាសនាព្រះពុទ្ធ មុខរបរ កម្មករធ្វើប្រហិត ទីកន្លែងកំណើត ប្រទេសវៀតណាម មានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ឃាត់ខ្លួន) ។

២-នាមត្រកូល និងនាមខ្លួន [redacted] ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករធ្វើប្រហិត ទីកន្លែងកំណើត ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះជួល ភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ឃាត់ខ្លួន) ។

៣- **បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOMO២០៥០** ជនជាតិចិន នៅម្តុំសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ (គេចខ្លួន) ។

៤- **អញ្ញាតជន** (គេចខ្លួន) ។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចតាមបណ្ដោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា **៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។**

**អង្គហេតុ ៖** កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០១ និង ១០ នាទី យប់រំលងអាធ្រាត្រ កម្លាំងចម្រុះអ:
វត្តត្រួតពិនិត្យជាតិអាកុល នៃអធិការដ្ឋាននគរបាលខណ្ឌទួលគោកបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០២ នាក់ ជាក់ស្តែ
នៅចំណុចបណ្ដោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនសង្ស័យឈ្មោ
[redacted] <u>ហៅ</u> **ដរ** ភេទប្រុស និងឈ្មោះ [redacted] ភេទប្រុស បានជិះម៉ូតូឌុបគ្នា ០១ គ្រឿងម៉ាក HONDA DREA
ពាក់ផ្លាកលេខ ភ្នំពេញ ១IR-៨៦០៨ ដោយមានការសង្ស័យក៏បានឆែកឆេរពិនិត្យរក ឃើញថ្នាំញៀនចំនួន ០៤ កញ្ចប់ម្សៅម៉ដ្ឋម៉
(K) និងម្សៅម៉ដ្ឋពណ៌កាហ្វេចំនួន ០១ កញ្ចប់ម៉ាក (Porsche) នៅក្នុងហោប៉ៅខាង ក្រោយផ្នែកខាងស្តាំរបស់ជនសង្ស័យឈ្

[redacted] ហៅ **ផវ** ភេទប្រុស ភ្លាមនោះសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ០២ នាក់ជាក់ស្តែង និងដកហូតវត្ថុតាងខាងលើបញ្ជូនមកកាន់អធិការដ្ឋាននគរបាលខណ្ឌទួលគោក តែម្តង ។

**បានឃើញចំណាត់ការនៅដំណាក់កាលនគរបាលយុត្តិធម៌៖**

-កំណត់ហេតុចម្លើយជនសង្ស័យឈ្មោះ [redacted] ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បានឆ្លើយថា: កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០ នាទី យប់រំលងអាធ្រាត្រ ក៏ស្រាប់តែជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ បានខលទូរស័ព្ទមកខ្លួនដោយបានពឹងខ្លួនទៅទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០ $ (ពីររយ) ដុល្លារអាមេរិក ខណៈនោះខ្លួន និងឈ្មោះ [redacted] ហៅ **វណ្ណា** ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ បានជិះម៉ូតូ ០១ គ្រឿងម៉ាក HONDA DREAM ពាក់ផ្លាកលេខ ភ្នំពេញ ១IR-៨៦០៨ ចេញពីម្តុំភូមិ១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីទៅយកលុយចំនួន ២០០ $ (ពីររយ) ដុល្លារអាមេរិក ពីបុរសជនជាតិចិននោះ នៅម្តុំសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលណាខ្លួនទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ឱ្យជនជាតិចិននោះបានហើយ ជនជាតិចិនមិនស្គាល់ឈ្មោះ និងឱ្យថ្លៃឈ្នួលចំនួន ១០០ $ (មួយរយ) ដុល្លារអាមេរិក ហើយខ្លួននិងឈ្មោះ [redacted] ហៅ **វណ្ណា** ចែកគ្នាក្នុងម្នាក់ ៥០ $ (ហាសិប) ដុល្លារអាមេរិក ដោយឈ្មោះ [redacted] ហៅ **វណ្ណា** បានជិះម៉ូតូឌុបខ្លួនទៅទិញគ្រឿងញៀននៅក្នុងក្លឹប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទៅដល់ឈ្មោះ [redacted] ហៅ **វណ្ណា** បានចូលក្នុងក្លឹបទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ពីបុរសមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ៣២ ឆ្នាំ ជនជាតិខ្មែរ ក្នុងតម្លៃ ២០០ $ (ពីររយ) ដុល្លារអាមេរិក ពេលទិញរួចឈ្មោះ [redacted] ហៅ **វណ្ណា** យកម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ហុចមកឱ្យខ្លួនហើយខ្លួនបានលាក់ទុកគ្រឿងញៀននោះនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ រួចឈ្មោះ [redacted] ហៅ **វណ្ណា** បានជិះម៉ូតូឌុបខ្លួនក្នុងគោលបំណងយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ស្ថិតនៅ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលឈ្មោះ [redacted] ហៅ **វណ្ណា** ជិះម៉ូតូឌុបខ្លួនមកដល់ចំណុចផ្លូវលេខ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏ស្រាប់តែជួបកម្លាំងសមត្ថកិច្ចកំពុងអនុវត្តត្រួតពិនិត្យជាតិអាកុល បានធ្វើការត្រួតពិនិត្យ ភ្លាមនោះសមត្ថកិច្ចបានរកឃើញ ម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ដែលខ្លួនបានលាក់ទុកនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ ខណៈនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួន និងឈ្មោះ [redacted] ហៅ **វណ្ណា** មកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក តែម្តង ។ កន្លងមកខ្លួននិងឈ្មោះ [redacted] ហៅ **វណ្ណា** ធ្លាប់បានទិញគ្រឿងញៀនទៅឱ្យជនជាតិចិន មិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ ចំនួន ០១ លើកមកហើយ ដោយទទួលបានថ្លៃឈ្នួលចំនួន ១០០$ (មួយរយ) ដុល្លារអាមេរិក ហើយពួកខ្លួនចែកគ្នាក្នុង ០១ នាក់ ៥០ $ (ហាសិប) ដុល្លារអាមេរិក ។

-កំណត់ហេតុចម្លើយជនសង្ស័យឈ្មោះ [redacted] ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បានឆ្លើយថា: កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០ នាទី យប់រំលងអាធ្រាត្រ ក៏ស្រាប់តែជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ បានខលទូរស័ព្ទមកឈ្មោះ [redacted] ហៅ **ផវ** ភេទប្រុស អាយុ ១៨ ឆ្នាំ ដោយបានពឹងឱ្យទៅទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០$ (ពីររយ) ដុល្លារអាមេរិក ខណៈនោះខ្លួន និងឈ្មោះ [redacted] ហៅ **ផវ** បានជិះម៉ូតូ ០១ គ្រឿងម៉ាក HONDA DREAM C១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៩ ពាក់ផ្លាកលេខ ភ្នំពេញ ១IR-៨៦០៨ ជិះឌុបឈ្មោះ [redacted] ហៅ **ផវ** ដើម្បីទៅយកលុយចំនួន ២០០ $ (ពីររយ) ដុល្លារអាមេរិក ពីបុរសជនជាតិចិននោះនៅម្តុំសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ពេលណាខ្លួនទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ឱ្យជនជាតិចិននោះបានហើយ ជនជាតិចិនមិនស្គាល់ឈ្មោះ និងឱ្យថ្លៃឈ្នួលចំនួន ១០០ $ (មួយរយ) ដុល្លារអាមេរិក ហើយខ្លួននិងឈ្មោះ [redacted] ហៅ ដារ ចែកគ្នាក្នុងម្នាក់ ៥០ $ (ហាសិប) ដុល្លារអាមេរិក ដោយខ្លួនបានជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដារ ទៅទិញគ្រឿងញៀននៅក្នុងក្លិប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទៅដល់ខ្លួនបានចូលក្នុងក្លិបទិញម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ពីបុរសមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ៣២ ឆ្នាំ ជនជាតិខ្មែរ ក្នុងតម្លៃ ២០០ $ (ពីររយ) ដុល្លារអាមេរិក ពេលទិញរួចខ្លួនបានយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ទៅហុចឱ្យឈ្មោះ [redacted] ហៅ ដារ ហើយឈ្មោះ [redacted] ហៅ ដារ បានលាក់ទុកគ្រឿងញៀននោះនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ រួចខ្លួនបានជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដារ ក្នុងគោលបំណងយកម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ទៅឱ្យជនជាតិចិនមិនស្គាល់ឈ្មោះ ស្ថិតនៅ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលខ្លួនជិះម៉ូតូឌុបឈ្មោះ [redacted] ហៅ ដារ មកដល់ចំណុចផ្លូវលេខ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក៏ស្រាប់តែជួបកម្លាំងសមត្ថកិច្ចកំពុងអនុវត្តត្រួតពិនិត្យជាតិអាល់កុល បានធ្វើការត្រួតពិនិត្យ ភ្លាមនោះសមត្ថកិច្ចបានរកឃើញ ម្សៅម៉ដ្ឋ ពណ៌ស ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ដែលឈ្មោះ [redacted] ហៅ ដារ បានលាក់ទុកនៅក្នុងហោប៉ៅខោខាងក្រោយផ្នែកខាងស្តាំ ខណៈនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួន និងឈ្មោះ [redacted] ហៅ ដារ មកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក តែម្តង ។ កន្លងមកខ្លួននិងឈ្មោះ [redacted] ហៅ ដារ ធ្លាប់បានទិញគ្រឿងញៀនទៅឱ្យជនជាតិចិន មិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ ចំនួន ០១ លើកមកហើយ ដោយទទួល បានថ្លៃឈ្នួលចំនួន ១០០ $ (មួយរយ) ដុល្លារអាមេរិក ហើយពួកខ្លួនចែកគ្នាក្នុង ០១ នាក់ ៥០ $ (ហាសិប) ដុល្លារអាមេរិក ។

**បានឃើញចំណាត់ការនៅដំណាក់កាលអយ្យការៈ**

-កំណត់ហេតុសួរចម្លើយជនសង្ស័យឈ្មោះ [redacted] ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ បានឆ្លើយថាៈ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ច ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ខ្លួនសុំរក្សាទុកជាបានការដដែលពុំមានអ្វីកែប្រែឡើយ ។ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០ នាទី យប់រំលងអាធ្រាត្រមានជនជាតិចិនមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ ជនជាតិចិន បានទូរស័ព្ទមកខ្លួនឱ្យខ្លួនទិញគ្រឿងញៀនចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០ $ (ពីររយ) ដុល្លារអាមេរិក រួចខ្លួនបានទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] ដោយជិះម៉ូតូទៅទិញនៅក្នុងក្លិប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទិញបានហើយខ្លួនបានយកទៅឱ្យបុរសមិនស្គាល់ឈ្មោះ ជនជាតិចិន ភេទប្រុស ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលជិះដល់ចំណុចផ្លូវ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក៏ស្រាប់តែជួបនិងកម្លាំងសមត្ថកិច្ចកំពុងត្រួតពិនិត្យជាតិអាកុល បានធ្វើការពិនិត្យពួកខ្លួនរកឃើញថ្នាំញៀនចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ដ្ឋ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ដែលខ្លួនបានលាក់ទុកក្នុងហោប៉ៅរួចបាននាំពួកខ្លួនមកអធិការដ្ឋាននគរបាលខណ្ឌទួលគោកតែម្តង ។ កន្លងមកពេលយកថ្នាំញៀនទៅឱ្យជនជាតិចិន ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ ចំនួន ០១ លើក មកហើយ រួចបានប្រាក់ឈ្នួលចំនួន ១០០ $ (មួយរយ) ដុល្លារអាមេរិក ហើយពួកខ្លួនចែកគ្នាជាមួយឈ្មោះ [redacted] ម្នាក់ ៥០ $ (ហាសិប) ដុល្លារអាមេរិក ។

-កំណត់ហេតុសួរចម្លើយជនសង្ស័យឈ្មោះ [redacted] ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ បានឆ្លើយថាៈ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ច ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ខ្លួនសុំរក្សាទុកជាបានការដដែលពុំមានអ្វីកែប្រែឡើយ ។ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០ នាទី យប់រំលងអាធ្រាត្រមានជនជាតិចិន

មិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ ជនជាតិចិន បានទូរស័ព្ទមកឈ្មោះ [redacted] ឱ្យទិញគ្រឿងញៀន ចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ង់ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ក្នុងតម្លៃ ២០០ $ (ពីររយ) ដុល្លារអាមេរិក រួចខ្លួនបានទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] ដោយជិះម៉ូតូទៅទិញនៅក្នុងក្លិប True Face សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលទិញបានហើយខ្លួនបានឱបឈ្មោះ [redacted] យកទៅឱ្យបុរសមិនស្គាល់ឈ្មោះ ជនជាតិចិន ភេទប្រុស ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះពេលជិះដល់ចំណុចផ្លូវ២៨៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក៏ស្រាប់តែជួបនិងកម្លាំងសមត្ថកិច្ចកំពុងត្រួតពិនិត្យជាតិអាកុល បានធ្វើការពិនិត្យពួកខ្លួនរកឃើញថ្នាំញៀនចំនួន ០៤ កញ្ចប់ម៉ាក (K) និងម្សៅម៉ង់ ពណ៌កាហ្វេ ចំនួន ០១ កញ្ចប់ម៉ាក (Porsche) ដែលឈ្មោះ [redacted] បានលាក់ទុកក្នុងហោប៉ៅរួចបាននាំពួកខ្លួនមកអធិការដ្ឋាន នគរបាលខណ្ឌទួលគោកតែម្តង ។ កន្លងមកពេលយកថ្នាំញៀនទៅឱ្យជនជាតិចិន ភេទប្រុស អាយុប្រហែល ២៥ ឆ្នាំ ចំនួន ០១ លើក មកហើយ រួចបានប្រាក់ឈ្នួលចំនួន ១០០ $ (មួយរយ) ដុល្លារអាមេរិក ហើយពួកខ្លួនចែកគ្នាជាមួយឈ្មោះ [redacted] ម្នាក់ ៥០ $ (ហាសិប) ដុល្លារអាមេរិក ។ ចំពោះម៉ូតូម៉ាក HONDA DREAM ពាក់ផ្លាកលេខ ភ្នំពេញ ១IR-៨៦០៨ ជាម៉ូតូរបស់ខ្លួន ។

**បានឃើញចំណាត់ការនៅដំណាក់កាលចៅក្រមស៊ើបសួរ៖**

-កំណត់ហេតុស្តួរចម្លើយជនត្រូវចោទឈ្មោះ [redacted] ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ បានឆ្លើយថា: ខ្លួនសុំរក្សាចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខសមត្ថកិច្ច និងនៅដំណាក់កាលអយ្យការទុកជាបានការដដែល ព្រោះចម្លើយនោះជាចម្លើយដែលខ្លួនឆ្លើយដោយខ្លួនឯង ដោយពុំមានអ្វីកែប្រែ ឬបន្ថែមនោះទេ ។ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០ នាទី នៅចំណុចម្តុំទួលគោក រាជធានីភ្នំពេញ (មិនស្គាល់ទីកន្លែងច្បាស់) ពេលខ្លួនកំពុងជិះម៉ូតូម៉ាក ហុងដាឌ្រីម ឆ្នាំ២០២១ ជាកម្មសិទ្ធិរបស់ពូឈ្មោះ [redacted] ជាមួយឈ្មោះ [redacted] ក្នុងគោលបំណងយកថ្នាំញៀន (មិនស្គាល់ម៉ាក) ឱ្យទៅម៉ូយនៅខុនដូរមិនស្គាល់ឈ្មោះម្តុំសែនសុខ ចំនួន ០៤ កញ្ចប់ ប៉ុន្តែខ្លួនមិនដឹងតម្លៃប៉ុន្មាន ហើយក៏មិនស្គាល់ម៉ាកដែរ ព្រោះខ្លួនជាអ្នកជួយយកឱ្យគេ ។ ចំពោះអ្នកដែលប្រើខ្លួនយកថ្នាំញៀនទៅឱ្យគេនោះខ្លួនមិនស្គាល់ឈ្មោះទេ ដោយគាត់មកក្នុងភូមិខ្លួនយូរៗម្តង ហើយចំពោះថ្លៃឈ្នួលដែលខ្លួនជួយយកថ្នាំញៀនឱ្យគេនោះ គឺបានចំនួន ៣០០០០ ៛ (បីម៉ឺន) រៀល ចែកគ្នាពីរនាក់ឈ្មោះ [redacted] ក្នុងម្នាក់បានប្រាក់ចំនួន ១៥០០០ ៛ (មួយម៉ឺនប្រាំពាន់) រៀល ដោយលុយថ្លៃឈ្នួលនេះខ្លួនបានទទួលរួចហើយ ។ អ្នកដែលប្រើខ្លួនឱ្យយកថ្នាំញៀនទៅឱ្យគេ គឺខ្លួនមិនស្គាល់ឈ្មោះ ហើយក៏មិនស្គាល់ទីលំនៅដែរ គ្រាន់តែមានភិនភាគ ជាមនុស្សប្រុស ខ្ពស់ ស្គមសម្បុរស្រអែម ជនជាតិខ្មែរ អាយុប្រហែលជាង ២០ ឆ្នាំ ។ ខ្លួនធ្លាប់យកថ្នាំញៀនទៅឱ្យគេតាមការប្រើរបស់មនុស្សប្រុសខាងលើនេះបានចំនួន ០២ ដងហើយ ដោយលើកទី០១ ឱ្យខ្លួនបានប្រាប់ឈ្នួល ៤០០០០ ៛ (បួនម៉ឺន) រៀល ហើយចែកជាមួយឈ្មោះ [redacted] ម្នាក់បាន ២០០០០ ៛ (ពីរម៉ឺន) រៀល ចំណែកលើកទី០២ គឺថ្ងៃដែលសមត្ថកិច្ចចាប់បាននេះឯង ។ ក្រៅពីមនុស្សប្រុសខាងលើប្រើខ្លួនឱ្យយកថ្នាំញៀនទៅឱ្យគេ ខ្លួនមិនដែលជួយយកឱ្យអ្នកណានោះទេ ហើយខ្លួនក៏មិនធ្លាប់ទិញលក់ដូរឃ្លាំកលុយខ្លួនឯងនោះដែរ ម្យ៉ាងទៀតខ្លួនក៏មិនចេះប្រើប្រាស់ថ្នាំញៀនដែរ ។ នៅពេលខ្លួនយកថ្នាំញៀនទៅឱ្យគេ ក្រៅពីទៅជាមួយឈ្មោះ [redacted] ខ្លួនមិនដែលទៅជាមួយអ្នកផ្សេងនោះទេ ហើយឈ្មោះ [redacted] ក៏បានដឹងដែរថាយកថ្នាំញៀនទៅឱ្យគេ ។ ខ្លួនសូមបញ្ជាក់ថាខ្លួនមិនដែលមានទំនាក់ទំនងប្រើប្រាស់តេឡេក្រាមជាមួយគណនីឈ្មោះ TOM@TOM២០៥០ ដែលជាជនជាតិចិននោះទេ ។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួននិងឈ្មោះ [redacted] គឺថ្នាំញៀនចំនួន ០៤ កញ្ចប់នៅលើខ្លួនរបស់ឈ្មោះ [redacted]។

-កំណត់ហេតុស្តួរចម្លើយជនត្រូវចោទឈ្មោះ [redacted] ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ បានឆ្លើយថា: ខ្លួនជាជនជាតិវៀតណាម ប៉ុន្តែខ្លួនកើតនៅប្រទេសខ្មែរ ចេះនិយាយ និងស្តាប់ភាសាខ្មែរបាន គ្រាន់តែមិនចេះអាន និងសរសេរភាសាខ្មែរ ដោយសារខ្លួនរៀនបានត្រឹមថ្នាក់ទី៣ ហើយបច្ចុប្បន្ននេះខ្លួនមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនោះទេ ។ ខ្លួនសុំរក្សាចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខសមត្ថកិច្ច និងនៅដំណាក់កាលអយ្យការទុកជាបានការដដែល

ព្រោះចម្លើយនោះជាចម្លើយដែលខ្លួនឆ្លើយដោយខ្លួនឯង ដោយពុំមានអ្វីកែប្រែ ឬបន្ថែមនោះទេ ។ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ១២ និង ១០ នាទី នៅចំណុចម្តុំទួលគោក រាជធានីភ្នំពេញ (មិនស្គាល់ទីកន្លែងច្បាស់) ពេលខ្លួនកំពុងជិះម៉ូតូម៉ាក ហុងដាឌ្រីម ឆ្នាំ២០២១ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ជាមួយឈ្មោះ [redacted] ក្នុងគោលបំណងយកថ្នាំញៀនប្រភេទខេ ឱ្យទៅម៉ូយនៅខុនដូរមិនស្គាល់ឈ្មោះម្តុំសែនសុខ ចំនួន ០៤ កញ្ចប់ ប៉ុន្តែខ្លួនមិនដឹងតម្លៃប៉ុន្មានព្រោះខ្លួនជាអ្នកជួយយកឱ្យគេ ។ ចំពោះអ្នកដែលប្រើខ្លួនយកថ្នាំញៀនទៅឱ្យគេនោះខ្លួនមិនស្គាល់ឈ្មោះទេ ដោយគាត់មកក្នុងភូមិខ្លួនយូរៗម្តង ហើយចំពោះថ្លៃឈ្នួលដែលខ្លួនជួយយកថ្នាំញៀនឱ្យគេនោះ គឺបានចំនួន ៣០០០០ ៛ (បីម៉ឺន) រៀល ចែកគ្នាពីរនាក់ឈ្មោះ [redacted] ក្នុងម្នាក់បានប្រាក់ចំនួន ១៥០០០ ៛ (មួយម៉ឺនប្រាំពាន់) រៀល ដោយលុយថ្លៃឈ្នួលនេះខ្លួនបានទទួលរួចហើយ ។ អ្នកដែលប្រើខ្លួនឱ្យយកថ្នាំ ញៀនទៅឱ្យគេ គឺខ្លួនមិនស្គាល់ឈ្មោះ ហើយក៏មិនស្គាល់ទីលំនៅដែរ គ្រាន់តែមានភិនភាគ ជាមនុស្សប្រុស ខ្ពស់ ស្គម សម្បុរស្រអែម ជនជាតិចិន អាយុប្រហែលជា ២៥ ទៅ ២៦ ឆ្នាំ មិនចេះនិយាយខ្មែរទេ ពេលដែលប្រើខ្លួនយកថ្នាំញៀនទៅឱ្យគេម្តងៗ គឺមានអ្នកបកប្រែចិនឱ្យ ហើយខ្លួនក៏មិនស្គាល់ឈ្មោះ ទីលំនៅរបស់អ្នកបកប្រែចិននោះដែរ គ្រាន់តែដឹងថាអ្នកបកប្រែចិននោះជាមនុស្សប្រុស អាយុប្រហែលជាង ២០ ឆ្នាំ ជនជាតិខ្មែរ ។ ខ្លួនធ្លាប់យកថ្នាំញៀនទៅឱ្យគេតាមការប្រើរបស់មនុស្សប្រុស ខាងលើនេះបានចំនួន ០២ ដងហើយ ដោយលើកទី០១ ឱ្យខ្លួនបានប្រាប់ឈ្នួល ៣០០០០ ៛ (បីម៉ឺន) រៀល ហើយចែក ជាមួយឈ្មោះ [redacted] ម្នាក់បាន ១៥០០០៛ (មួយម៉ឺនប្រាំពាន់) រៀល ចំណែកលើកទី០២ គឺថ្ងៃដែលសមត្ថកិច្ចចាប់បាននេះឯង ។ ក្រៅពីមនុស្សប្រុសខាងលើប្រើខ្លួនឱ្យយកថ្នាំញៀនទៅឱ្យគេ ខ្លួនមិនដែលជួយយកឱ្យអ្នកណានោះទេ ហើយខ្លួនក៏មិនធ្លាប់ទិញលក់ដូរយកលុយខ្លួនឯងនោះដែរ ម្យ៉ាងទៀតខ្លួនក៏មិនចេះប្រើប្រាស់ថ្នាំញៀនដែរ ។ នៅពេលខ្លួនយកថ្នាំញៀនទៅឱ្យគេ ក្រៅពីទៅជាមួយឈ្មោះ [redacted] ខ្លួនមិនដែលទៅជាមួយអ្នកផ្សេងនោះទេ ហើយឈ្មោះ [redacted] ក៏បានដឹងដែរថាយកថ្នាំញៀនទៅឱ្យគេ ។ ខ្លួនសូមបញ្ជាក់ថាខ្លួនមិនដែលមានទំនាក់ទំនងប្រើប្រាស់តេឡេក្រាមជាមួយគណនីឈ្មោះ TOM@TOM២០៥០ ដែលជាជនជាតិចិននោះទេ ។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួន និងឈ្មោះ [redacted] គឺថ្នាំញៀនចំនួន ០៤ កញ្ចប់នៅលើខ្លួនរបស់ខ្លួន ។

-ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ **២១១០ «ល» ផ.ព.ស** ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ **២៧២៣ «ល» ផ.យ.ផ** ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ **២១១១ «ល» ផ.ព.ស** ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ **២៧២៤ «ល» ផ.យ.ផ** ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខៈ **២០២ "ល" ព្រ.១** ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-របាយការណ៍លេខៈ **២៨/២៤** ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលបឹងកក់ទី១ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-លិខិតជូនដំណឹងស្តីពីការឃុំខ្លួនជនជាតិវៀតណាមលេខៈ **១២៩៥ រ.ប** ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-កំណត់ហេតុបើក និងបិទកញ្ចប់សំណាងវត្ថុតាង ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាចាត់តាំងអ្នកជំនាញលេខៈ **៣៣០ "ល" ព្រ.១** ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ សាលា ដំបូងរាជធានីភ្នំពេញ ។

-សំណើរសុំរំលឹកដីកាចាត់តាំងអ្នកជំនាញលេខ: **២២៨៦ រ.ប** ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង ។

**យល់ឃើញថា**

-កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ នៅចំណុច តាមបណ្តោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពិតជាមានអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តដោយជនត្រូវចោទ១.ឈ្មោះ [redacted] ហៅ **ជរ** ភេទប្រុស អាយុ ១៨ ឆ្នាំ ២.ឈ្មោះ **ថៃ វណ្ណា** ភេទប្រុស អាយុ ១៨ ឆ្នាំ ៣. ជនជាតិចិន ប្រើប្រាស់តេឡេក្រាម TOM@TOM២០៥០ និង៤. **អញ្ញាតជន** ពិតប្រាកដមែន។

-ផ្អែកតាមរបាយការណ៍លេខ: **០២១ រ.ប.ក** ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ធៀបនឹងចម្លើយសារភាពរបស់ជនត្រូវចោទ និងឯកសារភស្តុតាងនានាក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នា ដែលបញ្ជាក់ថាជនត្រូវចោទ១.ឈ្មោះ [redacted] ហៅ **ជរ** ភេទប្រុស អាយុ ១៨ ឆ្នាំ ២.ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ ឆ្នាំ ៣. បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOM២០៥០ និង៤. **អញ្ញាតជន** ពិតជាបានប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទ១.ឈ្មោះ [redacted] ហៅ **ជរ** ភេទប្រុស អាយុ ១៨ ឆ្នាំ ២.ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ ឆ្នាំ ៣. បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOM២០៥០ និង៤. **អញ្ញាតជន** គឺជាអំពើល្មើសច្បាប់ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គមយ៉ាងធ្ងន់ធ្ងរ ។

-ជនត្រូវចោទ១.ឈ្មោះ [redacted] ហៅ **ជរ** ភេទប្រុស អាយុ ១៨ ឆ្នាំ ២.ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ ឆ្នាំ ៣. បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOM២០៥០ និង៤. **អញ្ញាតជន** គឺជានីតិជនមានស្មារតី និងលក្ខណ សម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ [redacted] ហៅ **ជរ** ភេទប្រុស អាយុ ១៨ ឆ្នាំ និងជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ ឆ្នាំ ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច តាមបណ្តោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា ៤០ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

-ដោយឡែកជនត្រូវចោទ **បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOM២០៥០** និង **អញ្ញាតជន** គ្មានអត្តសញ្ញាណគ្រប់គ្រាន់គប្បីលើកលែងចោទប្រកាន់តាមបញ្ញត្តិមាត្រា **២៤៧** នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ហេតុដូច្នេះ**

**ប្តឹងសុំចៅក្រមស៊ើបសួរសម្រេច៖**

**១-បញ្ជូនជនត្រូវចោទ ៖**

ក-ឈ្មោះ **សុខ សីហា** ហៅ **ជរ** ភេទប្រុស អាយុ ១៨ ឆ្នាំ (ក្នុងឃុំ)

ខ-ឈ្មោះ **ថៃ វណ្ណា** ភេទប្រុស អាយុ ១៨ ឆ្នាំ (ក្នុងឃុំ) ។

***ទៅជំនុំជម្រះ*** ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច តាមបណ្តោយផ្លូវលេខ២៨ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ តាមបញ្ញ មាត្រា ៤០ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។/

ខ-លើកលែងចោទប្រកាន់ ៖

គ- **បុរសមិនស្គាល់ឈ្មោះ ប្រើប្រាស់តេឡេក្រាម TOM@TOMO២០៥០** (គេចខ្លួន)

ឃ-**អញ្ញាតជន** (គេចខ្លួន) ។

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច តាមបណ្តោយផ្លូវលេខ២៨៩ ក្រុមទី៣៤ ភូមិ១០ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ តាមបញ្ញត្តិមាត្រា ៤០ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

៣-រក្សាជនត្រូវចោទឈ្មោះ [redacted] <u>ហៅ</u> **ផរ** ភេទប្រុស អាយុ ១៨ ឆ្នាំ និងជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ ឆ្នាំ ឱ្យជាប់ឃុំបណ្តោះអាសន្នរហូតដល់ ពេលសវនាការតាមបញ្ញត្តិមាត្រា **២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**។

ថ្ងៃ...ច័ន្ទ...១០រោច......... ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៤

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង